# ចិត្តវិទ្យាអប់រំ១
# ( ឆ្នាំទី១ ឆមាសទី១ )



**រៀបរៀងដោយៈ** គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយៈ

**"មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍"**

**២០២២**

**គណៈកម្មការនិពន្ធ៖**

១. លោកស្រី ហ៊ូ សៅម៉ូលីន

២. លោកស្រី អ៊ុំ សៅរីយ៍

**គណៈកម្មការរចនាទំព័រ៖** លោកស្រី សំបាត់ អ៊ាត លោកស្រី ឈុំ ពៅ

**គណៈកម្មការត្រួតពិនិត្យ៖**

១. លោកបណ្ឌិត សាំង មាសសួន

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣%នៅឆ្នាំ២០០៤មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើងដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក និងតំបន់រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជាឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវ ជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគ ទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ជាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ចតាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក

សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិក និងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរ និងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស

និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា។

2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និង និស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ។

3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន។

4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន។

5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ។

6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែ ច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា“មូលនិធិ ស.គ.ន” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃ

ការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បាន សម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ ( Digitalization for IR.4.0 ) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា **(Text book)** ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធាន

សិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់

## នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថា ជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា ឡើយ។

# អារម្ភកថា

ដំណើរការនៃការរៀបចំសៀវភៅចិត្តវិទ្យាអប់រំ១ សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា និងកម្រិតមូលដ្ឋាន (ឯកទេសទូទៅ) ថ្នាក់បរិញ្ញាបត្រ (១២+៤)ឆ្នាំទី១ឆមាសទី១ត្រូវបានរៀបចំឡើងដោយក្រុម គ្រូឧទ្ទេសមុខវិជ្ជាចិត្តវិទ្យា នៃដេប៉ាតឺម៉ង់គរុកោសល្យនៅក្នុងមហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យ នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ក្រោមការគាំទ្រដោយ មូលនិធិការស្រាវជ្រាវគំនិតច្នៃប្រឌិត និងនវានុវត្តន៍។ សៀវភៅនេះគឺជាស្នាដៃដំបូង ដែលក្រុមនាងខ្ញុំសូមទទួលស្គាល់ថា ការយល់ដឹងអំពីកិច្ចការចងក្រងសៀវភៅនេះនៅមានកម្រិតនៅឡើយ ប៉ុន្តែដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់គ្រូឧទ្ទេស និងគរុនិស្សិតដែលចាំបាច់ត្រូវមានឯកសារសម្រាប់បង្រៀន និងរៀន ទើបជំរុញឱ្យក្រុមនាងខ្ញុំខិតខំ ផលិតឯកសារនេះឡើងដោយផ្អែក លើឯកសារពិគ្រោះមួយចំនួនដូចជា សៀវភៅកម្មវិធីសិក្សាលម្អិត និងកិច្ចតែងការបង្រៀន សម្រាប់បណ្តុះបណ្តាល គ្រូបង្រៀនកម្រិតបឋមសិក្សានិងកម្រិតមូលដ្ឋាន សៀវភៅIntroduction Psychology រួមជាមួយ នឹងបទពិសោធន៍បង្រៀនផ្ទាល់មកចងក្រងជាឯកសារ សម្រាប់ជាប្រយោជន៍ក្នុងការបង្រៀន និងរៀន ដើម្បីលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនដែលឈានមុខគេនៅសតវត្សទី២១ស្របតាមចក្ខុវិស័យរបស់វិទ្យាស្ថាន។

គោលដៅសំខាន់នៃសៀវភៅនេះ គឺដើម្បីជួយគ្រូឧទ្ទេសនិងគរុនិស្សិតឱ្យបានយល់ដឹងពីទ្រឹស្តីចិត្តវិទ្យាអប់រំ១ ដែលផ្តោតលើខ្លឹមសារដូចជា ចំណងក្តីស្រឡាញ់រវាងឪពុកម្តាយជាមួយកូនៗ របៀបដែលកុមារស្មានទៅលើលក្ខខណ្ឌចិត្តរបស់អ្នកដទៃ ដំណាក់កាលអភិវឌ្ឍសីលធម៌និងចិត្តរំភើប យុទ្ធវិធីក្នុងការមើលពណ៌ ចំណាំងភ័ន្តច្រឡំ ប្រត្យក្សារម្មណ៍ពីជម្រៅនិងចម្ងាយ ការអភិវឌ្ឍពុទ្ធិ ការយល់ដឹងអំពីរបៀបរៀននិងលំនឹក ការជំរុញលើកទឹកចិត្ត វិធីសាស្ត្របង្រៀន ព្រមទាំងឥទ្ធិពលនៃការរំពឹងទុករបស់គ្រូ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀននិងរៀន។ ជាងនេះទៅទៀតការយល់ដឹងនូវខ្លឹមសារទាំងនេះជាប្រយោជន៍ដ៏សំខាន់ក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈ និងបញ្ញាញាណរបស់មនុស្សសម្រាប់កសាងគ្រួសារ សាលារៀន និងសង្គម។

ជាទីបញ្ចប់ក្រុមការងាររបស់នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ដែលបានចំណាយធនធាន ព្រមទាំងកម្លាំងកាយចិត្ត បញ្ញាស្មារតី និងផ្តល់ឱកាសក្នុងការរៀបចំឯកសារដ៏មានសារៈសំខាន់មួយនេះឱ្យចេញជារូបរាងឡើង។

# សេចក្ដីថ្លែងអំណរគុណ

ជាការពិតសៀវភៅ «ចិត្តវិទ្យាអប់រំ១» ដែលលេចចេញជារូបរាងនៅពេលនេះគឺបានកើតឡើងពីការខិតខំ និងយកចិត្តទុកដាក់ចូលរួមពីភាគី និងស្ថាប័នពាក់ព័ន្ធជាច្រើន។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ភាគី និងស្ថាប័នពាក់ព័ន្ធទាំងអស់ដូចជា ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ក្រសួងអប់រំ យុវជន និងកីឡាឱ្យបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ហៅកាត់ថា «មូលនិធិ ស.គ.ន»។

- ក្រសួងអប់រំ យុវជន និងកីឡាដែលបានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា «មូលនិធិ ស.គ.ន» ដើម្បីរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។

- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

- ឯកឧត្តមបណ្ឌិត/ឯកឧត្តមវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលបានចាត់តាំងជាគណៈកម្មការនិពន្ធចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- នាយកដ្ឋានបណ្ដុះបណ្ដាលដែលបានចាត់តាំងជាគណៈកម្មការនិពន្ធ និងគណៈកម្មការត្រួតពិនិត្យ លើស្នាដៃនៃការចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- លោកប្រធាន នាយកដ្ឋានបណ្ដុះបណ្ដាលដែលព្រមព្រៀងទទួលសិទ្ធិជាតំណាងអ្នករៀបរៀងក្នុងការចាត់ចែង និងសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងកិច្ចដំណើការទូទាត់ថវិកាតាមរយៈការស្នើសុំ និងទទួលថវិកា បោះពុម្ព និងផ្សព្វផ្សាយបន្តនូវស្នាដៃរៀបរៀង និពន្ធ និងកែលម្អរបស់អ្នករៀបរៀងក្នុងការរៀន និងបង្រៀនក្នុងគ្រឹះស្ថានសិក្សា និងប្រគល់សិទ្ធិស្របតាមការកំណត់នៃកិច្ចព្រមព្រៀង ស្ដីពីការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សា ក្រោមការគាំទ្រនៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។

- គ្រូឧទ្ទេសមុខវិជ្ជាចិត្តវិទ្យា នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលបានផ្តល់មតិកែលម្អលើខ្លឹមសារ នៃមេរៀននីមួយៗឱ្យកាន់តែមានភាពសុក្រឹត និងមានលក្ខណៈវិទ្យាសាស្ត្រ។

នាងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់សិស្ស និស្សិត នៅកម្រិតវិទ្យាល័យ និងឧត្តមសិក្សា។

# ការបរិយាយលើមុខវិជ្ជា

សៀវភៅចិត្តវិទ្យាអប់រំ១ បានពន្លេចចេញនូវខ្លឹមសារគោលចំនួន១១មេរៀនដែលមានដូចជា៖

១. សេចក្តីផ្តើមនៃចិត្តវិទ្យាអប់រំ១ បានផ្តល់នូវទស្សនៈរួម ដែលផ្តោតលើគោលបំណងដើម្បីឱ្យគ្រូបង្រៀនបានអនុវត្តចំណេះដឹងថ្មីៗនៅក្នុងថ្នាក់រៀនប្រកបដោយភាពប៉ិនប្រសប់និងរស់រវើក ជាពិសេសបានបង្ហាញនូវអត្ថន័យ និងចំណុចសំខាន់ៗនៃចរិតលក្ខណៈល្អរបស់គ្រូបង្រៀនដែលត្រូវប្រកាន់ខ្ជាប់អំពីតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

២. ការអភិវឌ្ឍសង្គម១ ដែលផ្តោតលើមេរៀន ចំណងក្តីស្រឡាញ់រវាងឪពុកម្តាយជាមួយកូនៗពិសេស អំពីឥទ្ធិពលនៃចំណងក្តីស្រឡាញ់ ដែលជួយឱ្យគ្រូបង្រៀនបានស្វែងយល់អំពីប្រភេទនៃចំណងក្តីស្រឡាញ់ដែលកុមារ ទទួលបានពីឪពុកម្តាយ ឬអ្នកថែទាំរបស់ពួកគេតាំងពីទារកមកម្ល៉េះ។ ជាងនេះ ទៅទៀតលោកគ្រូ អ្នកគ្រូ នឹងស្វែងយល់បន្ថែមអំពី ការអភិវឌ្ឍសង្គម ដូចជាទំនាក់ទំនងអន្តរបុគ្គល។

៣. មេរៀនទី៣រៀបរាប់អំពីការអភិវឌ្ឍសង្គម២។ ទ្រឹស្តីចិត្តបានលើកឡើងអំពីបញ្ញត្តិរបស់ខ្លួនរួមបញ្ចូលនឹងការដែលជួយគ្រូបង្រៀនអាចកំណត់បាន អំពីរបៀបដែលកុមារស្មានទៅលើលក្ខខណ្ឌចិត្តរបស់អ្នកដទៃតាមរយៈទ្រឹស្តីនៃចិត្តនិងបន្តការចូលរួមលើកកម្ពស់ ឱ្យមានទម្លាប់យកទ្រឹស្តីនៃចិត្តទៅប្រើប្រាស់នៅក្នុងការបង្រៀនរបស់ខ្លួនជាប្រចាំ។

៤. មេរៀនទី៤ ពណ៌នាអំពីការអភិវឌ្ឍចិត្តរំភើប និងសីលធម៌ គឺមានបំណងឱ្យលោកគ្រូ អ្នកគ្រូអាចធ្វើការពន្យល់ អំពីការអភិវឌ្ឍចិត្តរំភើបរបស់កុមារថែម ទាំងស្វែងយល់ទ្រឹស្តីនេះដោយផ្អែកលើដំណាក់កាលអភិវឌ្ឍសីលធម៌ តាមរយៈការសិក្សារបស់លោក Kohlberg។

៥. ខ្លឹមសារនៃមេរៀនទី៥ ឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍប្រត្យក្សារម្មណ៍របស់កុមាររួមជាមួយនឹងការជួយដល់គ្រូបង្រៀន ឱ្យប្រើប្រាស់នូវសម្ភារៈឧបទ្ទេសដើម្បីជួយសិស្សឱ្យមានបំណិននៅក្នុងការមើលពណ៌ និងលាយពណ៌ជាពិសេសមេរៀននេះជួយគ្រូ និងសិស្សអាចគ្រប់គ្រងចំណាំងក័ន្តប្រឡំបានល្អប្រសើរ។

៦. មេរៀនទី៦បានលើកឡើង អំពីការអភិវឌ្ឍពុទ្ធិដោយបានធ្វើការពណ៌នានិងពន្យល់ទ្រឹស្តីនៃការអភិវឌ្ឍពុទ្ធិដោយផ្អែកលើការសិក្សារបស់លោក Piaget។ មេរៀននេះជួយគ្រូឱ្យទទួលបាននូវវិធីសាស្ត្របង្រៀនល្អៗ ក្នុងការជួយសិស្សឱ្យមានបំណិនក្នុងការគិតចំពោះពិភពនៅជុំវិញខ្លួនរបស់ពួកគេ។

៧. មេរៀនទី៧ផ្តោតលើ ដំណើរនៃការរៀនរបស់សិស្សដែលផ្តើមចេញពីទ្រឹស្តីជាមូលដ្ឋាននៃការបង្រៀននិងរៀន តាមរយៈអ្នកប្រាជ្ញ២រូបគឺ លោក Ivan Pavlov និងលោក Burrhus Frederic Skinner យោងតាមការដាក់លក្ខខណ្ឌបុរាណ ការដាក់លក្ខខណ្ឌប្រតិបត្តិ និងការសិក្សាតាមរយៈការសង្កេតដែលបានប្រើប្រាស់យ៉ាងសម្បូរបែបនៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។

៨. មេរៀនទី៨ បង្ហាញអំពីលំនឹក ដែលជាលំនាំមួយដ៏ចាំបាច់នៅក្នុងដំណើរការរៀនរបស់សិស្ស រួមនឹងវិធីសាស្ត្របង្កើនភាពចងចាំ ជាពិសេសគឺការប្រើប្រាស់ច្បាប់ទាំង៣នៃការរក្សាលំនឹកនៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។

៩. មេរៀនទី៩ ផ្តោតលើការជំរុញលើកទឹកចិត្ត ដែលជាចលករសំខាន់ក្នុងដំណើរការបង្រៀន និងរៀន ក្នុងនោះដែរលោកគ្រូ អ្នកគ្រូអាចបង្កើនការប្រើប្រាស់នូវប្រភេទទាំង២នៃការជំរុញលើកទឹកចិត្ត និងវិធីដែលជួយលោកអ្នកបង្កើននូវការជំរុញលើកទឹកចិត្តដល់សិស្សផងដែរ។

១០. មេរៀនទី១០ ផ្តោតលើវិធីសាស្ត្របង្រៀនទាំង៥ រួមនិងការញែកភាពខ្លាំង និងចំណុចខ្វះខាតនៃវិធីសាស្ត្របង្រៀននីមួយៗ ដើម្បីជួយលោកគ្រូ អ្នកគ្រូក្នុងការជ្រើសរើស និងប្រើប្រាស់វិធីទាំងនោះឱ្យសមស្របតាមលក្ខខណ្ឌរបស់សិស្ស ប្រកបដោយបរិយាប័ន្ន។

១១. មេរៀនទី១១ គឺជាមេរៀនចុងក្រោយដែលលើកឡើងអំពីឥទ្ធិពលនៃការរំពឹងទុករបស់គ្រូ ដែលមានទំនាក់ទំនង និងផលប៉ះពាល់ទៅលើលទ្ធផលនៃការសិក្សារបស់សិស្សចេញពីទិដ្ឋភាពនៃចិត្តវិទ្យា។ ខ្លឹមសារមេរៀននេះក៏បានជួយលោកគ្រូ អ្នកគ្រូឱ្យឆ្លុះបញ្ចាំងពីការរំពឹងទុកជាវិជ្ជមាននិងអវិជ្ជមាននៅក្នុងទិដ្ឋភាពក្នុងការបង្រៀន និងរៀន ហើយរិះរកវិធីសាស្ត្រនានាក្នុងការច្នៃប្រឌិតយកការរំពឹងទុកជាវិជ្ជមានមកប្រើប្រាស់នៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។

# មូលន័យសង្ខេប

សៀវភៅចិត្តវិទ្យាអប់រំ១នេះត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀននិងរៀនរបស់គ្រូឧទ្ទេសនិងគរុនិស្សិត ឆ្នាំទី១ ឆមាសទី១។ សៀវភៅនេះមានមេរៀនសរុបទាំងអស់១១មេរៀន ដែលរួមមាន សេចក្តីផ្តើមនៃចិត្តវិទ្យាអប់រំ១ ការអភិវឌ្ឍសង្គម១គឺចំណងក្តីស្រឡាញ់រវាងឪពុកម្តាយជាមួយកូន ការអភិវឌ្ឍសង្គម២ ទ្រឹស្តីចិត្ត ការអភិវឌ្ឍចិត្តរំភើប និងសីលធម៌ ការអភិវឌ្ឍប្រត្យក្សារម្មណ៍របស់កុមារ ការអភិវឌ្ឍពុទ្ធិ ដំណើរ(លំនាំ)នៃការរៀនរបស់សិស្ស លំនឹក ការជំរុញលើកទឹកចិត្ត វិធីសាស្ត្របង្រៀនទាំង៥ (ការរៀនជាក្រុមធំ ក្រុមតូច ការរៀនតាមបែបដោះស្រាយបញ្ហា ការៀនតាមបែបស្វែងរក ការរៀនតាមបែបជីកស(Jigsaw Technique)) និងឥទ្ធិពលនៃការរំពឹងទុករបស់គ្រូដែល

មេរៀនទាំងនេះ បានផ្តល់នូវចំណេះដឹង ជាមូលដ្ឋាននៃចិត្តវិទ្យាអប់រំ១និងជំនាញនានាក្នុងការដោះ

ស្រាយការលំបាកនៃការបង្រៀននៅក្នុងថ្នាក់រៀន។ ចំណងក្តីស្រឡាញ់ជាទ្រឹស្តីដែលបង្ហាញពីទំនាក់ទំនងជិតស្និទ្ធរវាងកូននិងឪពុកម្តាយឬអ្នកមើលថែ។ ការសិក្សាអំពីទ្រឹស្តីនៃចិត្តអាចចាត់ទុកជាជំនាញមួយរបស់កុមារក្នុងការអភិវឌ្ឍសមត្ថភាពស្វែងយល់ពីគំនិតរបស់កុមារដទៃទៀត។ ការអភិវឌ្ឍចិត្តរំភើប និងសីលធម៌តាមរយៈទ្រឹស្តីរបស់ចិត្តវិទូអាចឱ្យយើងធ្វើការឆ្លុះបញ្ចាំងទៅលើការឆ្លើយតបផ្លូវចិត្តរបស់បុគ្គលម្នាក់ៗ។ ជាពិសេស តាមរយៈទ្រឹស្តីរបស់ Kohlberg(1958) ដែលមានឥទ្ធិពលទៅលើការរីកចម្រើនផ្នែកសីលធម៌សង្គម។ ប្រត្យក្សារម្មណ៍រួមចំណែកអាចឱ្យយើងធ្វើការសម្រេចចិត្តលើអ្វីៗគ្រប់យ៉ាង ដោយផ្អែកលើអត្ថន័យនៃវត្ថុ ឬបាតុភូត ដើម្បីតម្រង់ទៅរកគោលបំណងជាក់លាក់មួយដែលស្របតាមតថភាពបរានុម័ត។ ការអភិវឌ្ឍពុទ្ធិដោយយោងតាមទ្រឹស្តីរបស់ចិត្តវិទូលោក Jean Piaget(1952) ផ្តោតលើការអភិវឌ្ឍការយល់ដឹង នៅក្នុងការផ្លាស់ប្តូរពីដំណាក់កាលមួយទៅដំណាក់កាលមួយរបស់កុមារ។ តាមរយៈទ្រឹស្តីនៃការរៀន ស្តីពីការដាក់លក្ខខណ្ឌបុរាណ លក្ខខណ្ឌប្រតិបត្តិ និងការរៀនតាម

រយៈការសង្កេតក្នុងដំណើរការបង្រៀន និងរៀនជាកត្តាជំរុញការរៀនសូត្រឱ្យសម្រេចគោលដៅ។លំនឹកមានតួនាទីយ៉ាងសំខាន់ នៅក្នុងជីវភាពរស់នៅជាពិសេសការបង្រៀននិងរៀន។ បើគ្មានលំនឹកទេ នោះយើងម្នាក់ៗក៏គ្មានបទពិសោធន៍ដែរ។ ការហ្វឹកហាត់សិស្សឱ្យមានលំនឹកល្អ គឺជាភារៈកិច្ចសំខាន់របស់គ្រូ។ ការជំរុញលើកទឹកចិត្តមានតួនាទីសំខាន់ក្នុងដំណើរការបង្រៀននិងរៀន ហើយវាក៏ជាតម្រូវការផ្លូវចិត្តជាមូលដ្ឋានផងដែរជាពិសេសជួយ ឱ្យសិស្សអាចកំណត់បាននូវដែនកំណត់ផ្ទាល់ខ្លួនទាក់ទងនឹងការលើកទឹកចិត្តពីខាងក្នុងនិងខាងក្រៅ។ វិធីសាស្ត្របង្រៀនអាចចាត់ជាកញ្ចក់ឆ្លុះបញ្ចាំងទៅលើទិដ្ឋភាពជាក់ស្តែងក្នុង ការបង្រៀននិងរៀន ដើម្បីទទួលបានគុណភាពនិងប្រសិទ្ធិភាពតាមរយៈការ

បង្ហាញចេញនូវលក្ខណៈសម្បត្តិនៃវិធីសាស្ត្រនីមួយៗ។ ឥទ្ធិពលនៃការរំពឹងទុករបស់គ្រូចំពោះសិស្ស មានសារៈសំខាន់ នៅពេលដែលគ្រូរំពឹងថា សិស្សនឹងបង្ហាញការអភិវឌ្ឍ ផ្នែកបញ្ញាស្មារតីកាន់តែល្អ ប្រសើរចំពោះការរៀនសូត្ររបស់ពួកគេ។

# តារាងរូបភាព


*រូបភាព 1៖វដ្តរបស់បាតុភូត ..........................................................................................2*

*រូបភាព 2៖ចិត្តវិទ្យាមានលក្ខណៈជាវិទ្យាសាស្រ្ត ....................................................................3*

*រូបភាព 3៖(Atkinson and Hilgards introduction to psychology, 16 edition) ....................9*

*រូបភាព 4៖បំណងក្តីស្រឡាញ់ដែលស្វែងរកសុវត្ថិភាព (Securely attached)........................... 11*

*រូបភាព 5៖បំណងក្តីស្រឡាញ់ដែលមិនទាមទារសុវត្ថិភាព(Insecurely Attached: Avoidant) .... 12*

*រូបភាព 6៖បំណងក្តីស្រឡាញ់ដែលមិនច្បាស់លាស់ (Ambivalent) ....................................... 13*

*រូបភាព 7៖ទាក់ទងទ្រឹស្តីចិត្ត.......................................................................................... 16*

*រូបភាព 8៖ការពិសោធស្តគ្រោប់ជំនឿខុសរបស់កុមារទៅលើក្មេងអាយុ៥ឆ្នាំ និង៣ឆ្នាំ................... 18*

*រូបភាព 9៖ការសម្តែងតួ ដោយ Sally and Anne Task......................................................... 18*

*រូបភាព 10៖ទំនាស់សីលធម៌ (Moral Dilemma) ...............................................................27*

*រូបភាព 11៖ជម្លោះរបស់សិស្សនៅក្នុងសាលារៀន..............................................................28*

*រូបភាព 12៖ Fin (ការស្តាប់បង្គាប់ និងការដាក់ទណ្ឌកម្ម) ......................................................28*

*រូបភាព 13៖ Fin (ការស្តាប់បង្គាប់ និងការដាក់ទណ្ឌកម្ម) ......................................................29*

*រូបភាព 14៖ Betty(ភាពស្របគ្នារវាងបុគ្គលនិងការអនុលោមតាមគ្នា) .....................................30*

*រូបភាព 15៖ច្បាប់និងការរក្សាសណ្តាប់សង្គម(Authority and Maintaining Social Order) ....... 31*

*រូបភាព 16៖ Jess(កិច្ចព្រមព្រៀងក្នុងសង្គម )Social Contract............................................ 31*

រូបភាព 17៖(គោលការណ៍សីលធម៌សកល )Universal Ethical Principles........................... 32

រូបភាព 18៖ Fin and Maryសីលធម៌សាមញ្ញ (Pre Conventional Morality) ......................... 33

រូបភាព 19៖ Betty and Teacherសីលធម៌ធម្មតា (Conventional Moral) ............................. 33

រូបភាព 20៖ Jessy and នាយក សីលធម៌កម្រិតខ្ពស់ (Post Conventional........................... 34

រូបភាព 21៖រូបភាពបំភ័ន្ត .................................................................................. 37

រូបភាព 22៖ក្រឡាអុក A and B មួយណាភ្លឺជាង ........................................................... 38

រូបភាព 23៖ក្រឡាអុកA និងក្រឡាអុកB មានពន្លឺស្មើគ្នា......................................................... 38

រូបភាព 24៖ការលាយបន្ថែមពណ៌ឱ្យកាន់តែស្រាល ក្រហម បៃតង ខៀវ (Additive color mixture) ........................................................................................................... 40

រូបភាព 25៖ការលាយបន្ថយពណ៌ឱ្យពណ៌កាន់តែដិត ចាស់ឬខ្មៅ Cyan Magenta Yellow(Subtractive mixture) ........................................................................... 41

រូបភាព 26៖ទំហំ (Relative size) ........................................................................ 42

រូបភាព 27៖ទីតាំង (Interposition)....................................................................... 42

រូបភាព 28៖៖កម្ពស់ (Relative height) ................................................................... 43

រូបភាព 29៖ការមើលចម្ងាយ(Perspective) ................................................................ 43

រូបភាព 30៖ស្រមោល និង ម្លប់(Shadow and Shading)................................................... 44

រូបភាព 31៖ដំណាក់កាលទី១ចលនាអារម្មណ៍ទទួល (Sensorimotor) .................................. 47

រូបភាព 32៖ដំណាក់កាលទី២ បុរេប្រតិបត្តិការ (Preoperational) ........................................ 49

រូបភាព 33៖ដំណាក់កាលទី៣ ប្រតិបត្តិការជាក់លាក់ឬរូបីយ៍ (Concrete operational) ............ 49

រូបភាព 34៖ប្រតិបត្តិការជាទម្រង់ ឬអរូបីយ៍ (Formal operational)......................................50
រូបភាព 35៖ដំណាក់កាលអភិវឌ្ឍទាំង៤ ........................................................................51
រូបភាព 36៖លក្ខខណ្ឌបុរាណ (Classical Conditioning) Ivan Pavlov.................................54
រូបភាព 37៖លក្ខខណ្ឌបុរាណ(ការពិសោធរវាងមនុស្ស និងក្រួចឆ្មារ)........................................57
រូបភាព 38៖ការជំរុញមានលក្ខខណ្ឌ និង ប្រតិកម្មមានលក្ខខណ្ឌ.............................................57
រូបភាព 39៖លំនឹកនីយកម្ម ......................................................................................64
រូបភាព 40៖**ការរក្សាទុកព័ត៌មាន Encode**..........................................................................65
រូបភាព 41៖ការនឹកឃើញព័ត៌មានឡើងវិញ Storage ..........................................................65
រូបភាព 42៖ការរក្សាទុកដោយឥន្ទ្រីយារម្មណ៍ (sensory ......................................................66
រូបភាព 43៖ការរក្សាទុករយៈពេលខ្លី (short term memory)...............................................67
រូបភាព 44៖ការរក្សាទុករយៈពេលវែង (long term store)...................................................68
រូបភាព 45៖ការជំរុញលើកទឹកចិត្ត.................................................................................72
រូបភាព 46៖តម្រូវការ Maslow.....................................................................................73
រូបភាព 47៖គំរូមួយអំពីកម្លាំងជំរុញជាមូលដ្ឋាន .................................................................74
រូបភាព 48៖ការជំរុញលើកទឹកចិត្តខាងក្នុង និងការការជំរុញលើកទឹកចិត្តខាងក្រៅ.......................74
រូបភាព 49៖ករណីសិក្សាដែលទាក់ទងនិងការគូររូប ............................................................76
រូបភាព 50៖ការជំរុញទឹកចិត្តខាងក្នុង.............................................................................76
រូបភាព 51៖ការសិក្សានៅក្នុងថ្នាក់ទាំងមូល (whole-class learning) ...................................81

រូបភាព 52៖ការសិក្សាក្រុមតូច (Small-group learning) ....................................................82

រូបភាព 53៖ការសិក្សាតាមបែបដោះស្រាយបញ្ហា(project-based learning)............................84

រូបភាព 54៖ការសិក្សាតាមបែបស្វែងរក (Discovery learning) ............................................85

រូបភាព 55៖ការបែងចែកក្រុមតាមរបៀបជីកស (Jigsaw technique)....................................86

រូបភាព 56៖ឥទ្ធិពលនៃការរំពឹងទុក.........................................................................................89

រូបភាព 57៖ឥទ្ធិពលនៃការរំពឹងទុកវិជ្ជមាន (រវាងគ្រូនិងសិស្ស)...............................................90

រូបភាព 58៖ឥទ្ធិពលនៃការរំពឹងទុកវិជ្ជមាន (រវាងគ្រូនិងសិស្ស)............................................... 91

រូបភាព 59៖ផ្ដឥទ្ធិពលនៃការរំពឹងទុកអវិជ្ជមានន (Golem effect)...........................................92

រូបភាព 60៖ឥទ្ធិពលនៃការរំពឹងទុកអវិជ្ជមាន (រវាងគ្រូនិងសិស្ស) ............................................93

# មាតិកា


បុព្វកថា ........................................ i

សេចក្តីបញ្ជាក់ ........................................ vii

អារម្ភកថា ........................................ viii

សេចក្តីថ្លែងអំណរគុណ ........................................ ix

ការបរិយាយលើមុខវិជ្ជា ........................................ xi

មូលន័យសង្ខេប ........................................ xiii

តារាងរូបភាព ........................................ i

មាតិកា ........................................ i

មេរៀនទី១ សេចក្តីផ្តើមនៃចិត្តវិទ្យា ........................................ 1

( Introduction to Psychology ) ........................................ 1

១.១ វត្ថុបំណង ........................................ 1

១.២ សេចក្តីផ្តើម ........................................ 1

១.៣ ខ្លឹមសារ ........................................ 1

១.៣.១ បញ្ញត្តិចិត្តវិទ្យា ........................................ 1

១.៣.២ ចិត្តវិទ្យាក្លាយជាវិទ្យាសាស្ត្រ ........................................ 2

១.៣.៣ មែកធាងនៃចិត្តវិទ្យា ........................................ 3

១.៣.៤ ចិត្តវិទ្យាអប់រំជាអ្វី? ....................................................................................4

១.៣.៥ អត្ថប្រយោជន៍នៃចិត្តវិទ្យាអប់រំ .......................................................................6

១.៤ សន្និដ្ឋាន ..........................................................................................................6

មេរៀនទី២ ការអភិវឌ្ឍសង្គម១៖ ចំណងក្តីស្រឡាញ់...................................................8

(Attachment) ......................................................................................................8

២.១ វត្ថុបំណង.........................................................................................................8

២.២ សេចក្តីផ្តើម .....................................................................................................8

២.៣ ខ្លឹមសារ...........................................................................................................8

២.៣.១ បញ្ញត្តិនៃចំណងក្តីស្រឡាញ់...............................................................................8

២.៣.២ ប្រភេទនៃចំណងក្តីស្រឡាញ់ ............................................................................. 11

២.៤ សន្និដ្ឋាន ........................................................................................................ 13

មេរៀនទី៣ ការអភិវឌ្ឍសង្គម២ ៖ ទ្រឹស្តីចិត្ត ............................................................ 15

(Theory of Mind) ............................................................................................... 15

៣.១ វត្ថុបំណង....................................................................................................... 15

៣.២ សេចក្តីផ្តើម ................................................................................................... 15

៣.៣ ខ្លឹមសារ......................................................................................................... 16

៣.៣.១ បញ្ញត្តិ ៖ តើទ្រឹស្តីនៃចិត្តជាអ្វី? ......................................................................... 16

៣.៣.២ ដំណាក់កាលអភិវឌ្ឍទ្រឹស្តីនៃចិត្ត ...................................................................... 19

៣.៤ សន្និដ្ឋាន ....................................................................................................20

មេរៀនទី៤ ការអភិវឌ្ឍចិត្តរំភើប និងសីលធម៌ ....................................................................22

( Development of Emotion and Morality ) ........................................................................22

៤.១ វត្ថុបំណង ..........................................................................................................22

៤.២ សេចក្តីផ្តើម.........................................................................................................22

៤.៣ ខ្លឹមសារ .............................................................................................................22

៤.៣.១ បញ្ញត្តិ ..........................................................................................................22

៤.៣.២ .ធាតុផ្សំនៃភាពវៃឆ្លាតខាងអារម្មណ៍រួមមាន៖....................................................24

៤.៣.៣ ដំណើរការនៃចិត្តរំភើប ( The Process of Emotion )........................................24

៤.៣.៤. ការអភិវឌ្ឍចិត្តរំភើបរបស់ទារក ឬកុមារ ( The Emotional Development in Childhood ) ..........................................................................................................25

៤.៣.៥.តើសីលធម៌ជាអ្វី? ..............................................................................................25

៤.៤ សន្និដ្ឋាន ..........................................................................................................34

មេរៀនទី៥ ការអភិវឌ្ឍប្រក្យក្សារម្មណ៍.........................................................................37

( Development of Perception ) ........................................................................................37

៥.១ វត្ថុបំណង ..........................................................................................................37

៥.២ សេចក្តីផ្តើម.........................................................................................................37

៥.៣ ខ្លឹមសារ .............................................................................................................37

៥.៣.១ បញ្ញត្តិ ..........................................................................................................37

៥.៣.២ តើប្រត្យក្សារម្មណ៍បង្កើតឡើងដើម្បីអ្វី ? 39

៥.៣.៣ មុខងារនៃប្រត្យក្សារម្មណ៍ 39

៥.៣.៤ ការរៀនមើលពណ៌ 40

៥.៣. ៥ ប្រត្យក្សារម្មណ៍នៃការដឹងពីចម្ងាយ ឬ ញាណដឹងពីចម្ងាយ 41

( Monocular Cues ) 41

៥.៤ សន្និដ្ឋាន 44

មេរៀនទី៦ ការអភិវឌ្ឍពុទ្ធិ 46

( Cognitive Development ) 46

៦.១ វត្ថុបំណង 46

៦.២ សេចក្តីផ្តើម 46

៦.៣ ខ្លឹមសារ 47

៦.៣.១ បញ្ញត្តិ ៖ ការអភិវឌ្ឍពុទ្ធិ( ការយល់ដឹង ) 47

៦.៣.២ លក្ខណៈពិសេសនៃដំណាក់កាលអភិវឌ្ឍពុទ្ធិ តាមទ្រឹស្តីលោក Piaget 47

៦.៣.៣ ដំណាក់កាលអភិវឌ្ឍពុទ្ធិទាំង៤ 47

៦.៤ សន្និដ្ឋាន 52

មេរៀនទី៧ ដំណើរការរៀន 53

( Learning Process ) 53

៧.១ វត្ថុបំណង 53

៧.២ សេចក្ដីផ្ដើម ....................................................................................................53

៧.៣ ខ្លឹមសារ ..........................................................................................................54

៧.៣.១ លក្ខខណ្ឌបុរាណក្នុងការអភិវឌ្ឍការសិក្សារបស់សិស្ស........................................54

(Classical Conditioning in student learning development) ................................54

៧.៣.២ លក្ខខណ្ឌប្រតិបត្តិក្នុងការអភិវឌ្ឍការសិក្សារបស់សិស្ស......................................58

(Instrumental/Operant Conditioning in student learning development).............58

៧.៣.៣ ការរៀនតាមរយៈការសង្កេត (Observational learning) ....................................60

៧.៤ សន្និដ្ឋាន ........................................................................................................ 61

មេរៀនទី៨ លំនឹក ....................................................................................................62

(Memory) ...............................................................................................................62

៨.១ វត្ថុបំណង ........................................................................................................62

៨.២ សេចក្ដីផ្ដើម....................................................................................................62

៨..៣ ខ្លឹមសារ ........................................................................................................63

៨.៣.១ បញ្ញត្តិ ..........................................................................................................63

៨.៣.២ លំនាំលំនឹក ..................................................................................................63

៨.៣.៣ ការរក្សាទុកលំនឹក៖.........................................................................................66

៨.៤ ការរក្សាទុកលំនឹកដោយប្រើល្បិចចងចាំ (chunking)..................................................69

៨.៥ សន្និដ្ឋាន ........................................................................................................70

មេរៀនទី៩ ការជំរុញលើកទឹកចិត្ត (Motivation) .......... 71
៩.១ វត្ថុបំណង .......... 71
៩.២ សេចក្តីផ្តើម .......... 71
៩.៣ ខ្លឹមសារ .......... 71
៩.៣.១. បញ្ញត្តិ ៖ តើអ្វីជាការជំរុញលើកទឹកចិត្ត? .......... 71
៩.៣.២ ប្រភេទនៃការជំរុញលើកទឹកចិត្ត៖ .......... 74
៩.៤ សន្និដ្ឋាន .......... 77
មេរៀនទី១០ វិធីសាស្រ្តបង្រៀន .......... 79
(Methods of Teaching) .......... 79
១០.១ វត្ថុបំណង .......... 79
១០.២ សេចក្តីផ្តើម .......... 79
១០..៣ ខ្លឹមសារ .......... 79
១០.៣.១ បញ្ញត្តិ .......... 79
១០.៣.២ វិធីសាស្រ្តបង្រៀនទាំង៥ប្រភេទ .......... 80
១០.៣.៣ ការសិក្សានៅក្នុងថ្នាក់ទាំងមូល (Whole-class learning) .......... 80
១០.៣.៤ ការសិក្សាក្រុមតូច (Small-group learning) .......... 82
១០.៣.៥ ការសិក្សាតាមបែបដោះស្រាយបញ្ហា (Problem-based, project-based and resource-based learning) .......... 83
១០.៣.៦ ការសិក្សាតាមបែបស្វែងរក (Discovery learning) .......... 84

១០.៣.៧ ការសិក្សាតាមវិធីសាស្ត្រ ជីកស (Jigsaw technique)....................................85

រូបភាព 55៖ការបែងចែកក្រុមតាមរបៀបជីកស (Jigsaw technique) ..............................86

១០.៤ សន្និដ្ឋាន.......................................................................................................86

មេរៀនទី១១ ឥទ្ធិពលនៃការរំពឹងទុក (Pygmalion effects) ................................................88

១១.១ វត្ថុបំណង ......................................................................................................88

១១.២ សេចក្តីផ្តើម.....................................................................................................88

១១.៣ ខ្លឹមសារ.........................................................................................................89

១១.៣.១ បញ្ញត្តិ ៖...................................................................................................89

១១.៣.២ ប្រភេទឥទ្ធិពលនៃការរំពឹងទុកនៅក្នុងការសិក្សា (Pygmalion effects) ៖ .........90

១១.៤ សន្និដ្ឋាន .......................................................................................................94

ឯកសារយោង៖ .......................................................................................................95

# មេរៀនទី១ សេចក្ដីផ្ដើមនៃចិត្តវិទ្យា

( Introduction to Psychology )

## ១.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់គរុនិស្សិតនឹង៖

- ពណ៌នាបានពីនិយមន័យនៃចិត្តវិទ្យាអប់រំ និងការអនុវត្តទ្រឹស្តីនៅក្នុងថ្នាក់រៀន
- កំណត់បាន អំពីតួនាទីរបស់គ្រូ និងការអនុវត្តចំណេះដឹងថ្មីៗនៅក្នុងថ្នាក់រៀន
- មានស្មារតីស្រឡាញ់ចូលចិត្តសិក្សាចិត្តវិទ្យាអប់រំដើម្បីរួមចំណែកប្រកាន់ខ្ជាប់នូវចរិតលក្ខណៈល្អរបស់គ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព។

## ១.២ សេចក្ដីផ្ដើម

គោលបំណងមេរៀននេះ គឺផ្ដល់នូវរូបភាពមួយដែលអាចឱ្យសិស្សទទួលបានទស្សនៈវិស័យកាន់តែទូលំទូលាយអំពីទិដ្ឋភាពទូទៅ និងបញ្ហាប្រឈមក្នុងវិស័យអប់រំ ដូចជាការលើកកម្ពស់គុណភាពគ្រូ នៅក្នុងវិស័យអប់រំ រួមទាំងសមត្ថភាពនៃការបណ្ដុះបណ្ដាលគ្រូបង្រៀននៅសតវត្សរ៍ទី២១។ ដើម្បីយល់ស៊ីជម្រៅទៅលើចិត្តវិទ្យាអប់រំ១ និងកាន់តែច្បាស់ពីខ្លឹមសារសំខាន់ៗ ដែលសិស្សត្រូវទទួលបានការអប់រំដែលមានវិសាលភាព ធំធេងគឺត្រូវការពេលវេលាដើម្បីបង្កើតប្រព័ន្ធអប់រំដែលល្អមួយតាមរយៈការអនុវត្តចិត្តវិទ្យាអប់រំ១ រួមមានការគិត ដល់តួនាទីរបស់គ្រូ ពិសេសការផ្ដោតលើចរិតលក្ខណៈល្អរបស់គ្រូបង្រៀន និងការសម្រេចបាននូវអត្ថប្រយោជន៍ចេញពីចិត្តវិទ្យាអប់រំ១។

ជាក់ស្ដែងមុខវិជ្ជានេះផ្ដល់នូវចំណេះដឹងមូលដ្ឋាននៃចិត្តវិទ្យាអប់រំ១និងជំនាញនានាដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ ដោយផ្ដោតលើការអនុវត្តទ្រឹស្តី ការដោះស្រាយបញ្ហាប្រឈមនានាដែលតែងតែកើតមានដូចជា ការគ្រប់គ្រងថ្នាក់រៀន ការកសាងទំនាក់ទំនងរវាងសិស្ស និងគ្រូ និងលំនឹកជាដើម។ ដោយឡែកចិត្តវិទ្យាអប់រំ១ ក៏បង្ហាញអំពីទំនាក់ទំនងនៃទ្រឹស្តីចិត្តវិទ្យាជាមូលដ្ឋាន ដែលរួមបញ្ចូលអំពីការអភិវឌ្ឍការរៀន ការជំរុញលើកទឹកចិត្ត និងសុខភាពផ្លូវចិត្តផងដែរ។

## ១.៣ ខ្លឹមសារ

### ១.៣.១ បញ្ញត្តិចិត្តវិទ្យា

ចិត្តវិទ្យា ជាវិទ្យាសាស្ត្រដែលសិក្សាពីអាកប្បកិរិយា និងដំណើរការផ្លូវចិត្តរបស់មនុស្ស។ អាកប្បកិរិយាមានន័យថាជាអ្វីៗដែលមនុស្សធ្វើ និងអាចសង្កេតបានដោយផ្ទាល់ ចំណែកឯដំណើរការ

ផ្លូវចិត្ត សំដៅលើទៅលើការគិត អារម្មណ៍និងកម្លាំងជំរុញដែលបុគ្គលម្នាក់ៗបានគិត និងជួបប្រទះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ម្យ៉ាងវិញទៀតចិត្តវិទ្យាជាវិទ្យាសាស្ត្រដែលសិក្សាពីបាតុភូតចិត្ត។




*រូបភាព 1៖វដ្តរបស់បាតុភូត*

តាមរយៈការសិក្សាមុខវិជ្ជាចិត្តវិទ្យា ត្រូវបានគេធ្វើពិសោធឱ្យឃើញថា វាមានឥទ្ធិពលទៅលើបទពិសោធន៍របស់មនុស្ស តាមរយៈការគិត អារម្មណ៍និងសកម្មភាព។ ឥទ្ធិពលទាំងនេះមានទំនាក់ទំនងលើកត្តាតំណពូជ ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្សចាប់ពីទារករហូតដល់មនុស្សពេញវ័យ។ កម្មវត្ថុនៃចិត្តវិទ្យា ផ្តោតលើការសង្កេត ដែលអ្នកអាចមើលឃើញនូវឥទ្ធិពលរបស់សង្គមមកលើការអភិវឌ្ឍរបស់មនុស្សផងដែរ។ ជាងនេះទៅទៀត ចិត្តវិទ្យាបានបង្ហាញពីមូលហេតុដែលនាំឱ្យមនុស្សមានអារម្មណ៍ មានការគិត ហើយនិងការសម្តែងចេញជាសកម្មភាព ឬអាកប្បកិរិយា។

### ១.៣.២ ចិត្តវិទ្យាក្លាយជាវិទ្យាសាស្ត្រ

យោងតាមចិត្តវិទូដែលបានចូលរួមស្រាវជ្រាវនិងជំរុញឱ្យចិត្តវិទ្យាក្លាយជាវិទ្យាសាស្ត្រមានដូចជា៖

- ចិត្តវិទូជនជាតិអាល្លឺម៉ង់ **លោក Wilhelm Wundt** ដែលជាទូទៅត្រូវបានគេ ហៅថាជាបិតាចិត្តវិទ្យា បានបង្កើតមន្ទីរពិសោធន៍ចិត្តវិទ្យាដំបូងគេ នៅសកលវិទ្យាល័យ **Leipzig** នៃប្រទេសអាល្លឺម៉ង់នៅក្នុងឆ្នាំ១៨៧៩ ដើម្បីធ្វើការពិសោធចិត្តវិទ្យា លោកបានផ្តាច់ចេញ មុខវិជ្ជាចិត្តវិទ្យាចេញពីទស្សនវិជ្ជា និងជីវវិទ្យាហើយបានក្លាយជាមនុស្សទី១ដែលត្រូវបានគេហៅថាជាចិត្តវិទូ។
- ចិត្តវិទូ **E.B. Titchener** បានធ្វើការផ្សព្វផ្សាយគំនិតរបស់លោក **Wundt** នៅក្នុងសហរដ្ឋអាមេរិកដែលទ្រឹស្តីចិត្តវិទ្យា របស់គាត់ ត្រូវបានគេស្គាល់ថា ជាទ្រឹស្តី រចនាសម្ព័ន្ធនិយម ព្រោះ

សង្កត់ធ្ងន់លើរចនាសម្ព័ន្ធនៃចិត្ត(រចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ)។

- លោក **William James** ជាចិត្តវិទូជនជាតិអាមេរិក និងជាអ្នកអប់រំដំបូងគេ ដែលផ្ដល់ការអប់រំចិត្តវិទ្យា នៅសហរដ្ឋអាមេរិក គាត់ត្រូវបានគេចាត់ទុកជាបិតា ចិត្តវិទ្យានៃជនជាតិអាមេរិក (father of American psychology)។




*រូបភាព 2៖ចិត្តវិទ្យាមានលក្ខណៈជាវិទ្យាសាស្ត្រ*

## ១.៣.៣ មែកធាងនៃចិត្តវិទ្យា

មែកធាងសំខាន់ៗរបស់ចិត្តវិទ្យា មានច្រើនបែបច្រើនយ៉ាង ប៉ុន្តែដើម្បីឱ្យមានភាពងាយស្រួល ចិត្តវិទូបានចែកចិត្តវិទ្យាជាពីរផ្នែកធំៗគឺ ផ្នែកទ្រឹស្ដី(Pure Psychology) និង ផ្នែកអនុវត្ត (Applied Psychology)។

**ក) ចិត្តវិទ្យាផ្នែកទ្រឹស្ដី** (Pure psychology)

ចិត្តវិទ្យាផ្នែកទ្រឹស្ដីផ្ដល់ឱ្យសិស្សនូវក្របខណ្ឌនិងទ្រឹស្ដីផ្នែកចិត្តវិទ្យា។ ខ្លឹមសារនេះផ្ដោតទៅលើទ្រឹស្ដី និងគោលការណ៍សំខាន់ៗនៃចិត្តវិទ្យា ដោយរៀបរាប់ពីវិធីសាស្ត្រ និងបច្ចេកទេសផ្សេងៗសម្រាប់ការវិភាគ ការវាយតម្លៃ ការកំណត់ និងការជំរុញអាកប្បកិរិយា។ ចិត្តវិទ្យាផ្នែកទ្រឹស្ដីមានដូចជា៖ចិត្តវិទ្យាទូទៅ ចិត្តវិទ្យាមិនធម្មតា ចិត្តវិទ្យាសង្គម ចិត្តវិទ្យាសរីរៈ ចិត្តវិទ្យាអភិវឌ្ឍ និងចិត្តវិទ្យាពិសោធន៍។

**ខ) ចិត្តវិទ្យាផ្នែកអនុវត្ត** (Applied psychology)

ចិត្តវិទ្យាផ្នែកអនុវត្តនេះ ផ្ដោតទៅលើការបញ្ចូលអំពីការស្រាវជ្រាវអនុវត្តឱ្យទៅជាសកម្មភាព។ ចិត្តវិទ្យាអនុវត្ត សង្កត់ធ្ងន់លើការអនុវត្តទ្រឹស្ដីអរូបីយ៍ នៅក្នុងទិដ្ឋភាពជាក់ស្ដែង និងក្នុងមន្ទីរពិសោធន៍ ព្រមទាំងបានបញ្ជាក់ថាទ្រឹស្ដីចិត្តវិទ្យាពិតជាត្រឹមត្រូវ ដើម្បីឱ្យសម្រេចបានលទ្ធផល។

ចិត្តវិទ្យាផ្នែកអនុវត្តមានដូចជា៖ ចិត្តវិទ្យាអប់រំ ចិត្តវិទ្យាវេជ្ជសាស្ត្រ ចិត្តវិទ្យាសម្រសម្រួល ចិត្តវិទ្យាឧស្សាកម្ម ចិត្តវិទ្យាផ្នែកបទឧក្រិដ្ឋ (criminal psychology) ចិត្តវិទ្យាផ្នែកច្បាប់ (forensic psychology) និង ចិត្តវិទ្យាផ្នែកសុខភាពផ្លូវចិត្ត (mental health)។ល។

## ១.៣.៤ ចិត្តវិទ្យាអប់រំជាអ្វី?

ចិត្តវិទ្យាអប់រំ ជាវិទ្យាសាស្ត្រនៃការអនុវត្តអាកប្បកិរិយារបស់មនុស្ស នៅក្នុងលំនាំនៃការបង្រៀន និងរៀន។ ចិត្តវិទ្យាអប់រំ មានលក្ខណៈជាវិទ្យាសាស្ត្រដូចគ្នាទៅនឹងចិត្តវិទ្យាទូទៅផងដែរ ហេតុដូច្នេះ របកគំហើញថ្មីត្រូវបានបង្កើតឡើងតាមរយៈការស្រាវជ្រាវ ដែលពឹងផ្អែកយ៉ាងខ្លាំង ទៅលើវិធីបែបវិទ្យាសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងនៅក្នុងការសិក្សានេះគឺបង្កើតការអនុវត្ត ចំណេះដឹងស្តីអំពីអាកប្បកិរិយានិងវិស័យអប់រំ។ ចិត្តវិទ្យាអប់រំជួយគ្រូឱ្យយល់ដឹងពីបញ្ហាផ្សេងដូចជា របៀបរៀនរបស់សិស្ស កត្តានានាដែលជំរុញទឹកចិត្តសិស្សឱ្យចង់រៀនរបៀបរៀបចំ ការបង្រៀនដែលពង្រីកការចូលរួមរបស់សិស្ស របៀបវាយតម្លៃលទ្ធផលសិក្សា និងប្រសិទ្ធភាពនៃកម្មវិធីសិក្សា។ចិត្តវិទ្យាអប់រំ ជួយគ្រូឱ្យយល់ដឹងផងដែរអំពីការគិតនិងសកម្មភាពរបស់ខ្លួនដែលជាប់ទាក់ទងទៅនឹងឥទ្ធិពលនៃការគិតរបស់សិស្ស និងអ្នកដែលនៅជុំវិញខ្លួន។

ឧទាហរណ៍ទី១៖ យោងតាម លោកបណ្ឌិតសាស្ត្រាចារ្យ Dr. Jennifer Irwin លើកឡើងថា ចិត្តវិទ្យាអប់រំជាការសិក្សាទៅលើការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ។

ឧទាហរណ៍ទី២៖ យោងតាម លោកបណ្ឌិតសាស្ត្រាចារ្យ Dr. Charles. E.Skinnerលើកឡើងថាចិត្តវិទ្យាអប់រំ ជាមែកធាងរបស់ចិត្តវិទ្យា ដែលដោះស្រាយជាមួយ អាកប្បកិរិយារបស់មនុស្សនៅក្នុងបរិបទអប់រំ។

### ក) ហេតុអ្វីបានជាចាំបាច់ត្រូវសិក្សាពីអាកប្បកិរិយារបស់មនុស្ស?

អាកប្បកិរិយារបស់មនុស្ស គឺជាសកម្មភាពរបស់បុគ្គលម្នាក់ៗប្រព្រឹត្តទៅនៅក្នុងស្ថានភាពមួយ វាមិនមែនជារឿងចៃដន្យទេជានិច្ចជាកាលតែងតែប្រព្រឹត្តទៅតាមលំនាំជាច្រើនហើយអាចព្យាករណ៍ទុកមុនបាន។ អាកប្បកិរិយាទាំងនេះត្រូវបានព្យាករណ៍ថាជាប្រតិកម្មមួយដែលផ្សារភ្ជាប់ទៅនិព្រឹត្តិការណ៍ ឬស្ថានភាពខាងក្រៅ។ ផ្ទុយមកវិញវាអាចធ្វើឱ្យកើតមាននូវអាកប្បកិរិយាផ្សេងៗទៀតផងដែរ។

ឧទាហរណ៍៖ នៅពេលដែលមានសិស្សណាម្នាក់ស្រែកដាក់សិស្សម្នាក់ទៀតខ្លាំងៗគាត់តែងតែស្រែកតបដាក់ទៅវិញ ហើយពួកគាត់អាចមានអារម្មណ៍ឈឺចាប់ឬចងគំនុំ។គ្រូមានបំណងចង់គ្រប់គ្រងបរិយាកាសសិក្សាតាមយៈការស្រែក ឬគំរាមកំហែងពីមិត្តរួមថ្នាក់របស់ពួកគេ ខណៈនោះគ្រូត្រូវបំបែកសិស្សរបស់គាត់ឱ្យបានលឿន។ ជាទូទៅគ្រូដែលមានជំនាញដឹងថានៅពេលដែលមានសិស្សចាប់ផ្តើមតម្លើងសម្លេង គឺគាត់ត្រូវតែនិយាយទន់ភ្លន់ ដើម្បីបំលែងស្ថានការណ៍ ជាជាងការតម្លើងសម្លេង ឬ

បង្កើនសម្លេងរំខាននៅក្នុងថ្នាក់រៀន។ ជាញឹកញាប់យើងអាចដឹងបានពីទំនាក់ទំនងដែលតែងតែកើតមានឡើង និងលទ្ធផលនៃអាកប្បកិរិយារបស់ខ្លួន។

ឧទាហរណ៍៖ នៅពេលដែលសិស្សលើកឡើងពីគំនិតរបស់ពួកគេ ហើយគាត់មានឱកាសបានពន្យល់ហេតុផលផលយ៉ាងច្បាស់លាស់ទៅកាន់គ្រូរបស់ខ្លួន ធ្វើឱ្យគ្រូរបស់គាត់បានយល់ដឹងពីគំនិតរបស់គាត់។ម្យ៉ាងទៀតនៅពេលដែលក្មេងយំ អ្នកមើលថែក្មេងនោះតែងតែលួងលោមដើម្បីឱ្យក្មេងឈប់យំ។ អាកប្បកិរិយា ធម្មតាទាំងនេះ ត្រូវបានមនុស្សភាគច្រើនដឹងដោយផ្អែកលើបទពិសោធន៍របស់ពួកគេ។ នៅពេលក្មេងធំឡើងពួកគេរៀនអ្វីៗទាំងនេះដោយខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយអាកប្បកិរិយាធម្មតាទាំងនេះមិនត្រូវបានកត់សម្គាល់ទេពីព្រោះ (១) ពួកគេមានភាពឆ្លាតវៃ (២) វាពិបាកក្នុងការប្រព្រឹត្ត និងវិភាគនូវអ្វីដែលកំពុងកើតឡើងក្នុងពេលតែមួយឬ (៣) មនុស្សភាគច្រើនមិនបានស្វែងយល់ដើម្បីចូលរួមចំពោះអាកប្បកិរិយា និងយល់អំពីបុព្វហេតុរបស់វា។ លើសពីនេះទៅទៀតមានកត្តាជាច្រើនដែលជួយពន្យល់ពីអាកប្បកិរិយា ដែលតែងតែកើតមានឡើងនៅខាងក្នុងដោយផ្អែកលើបទពិសោធដែលមនុស្សមានមករួចហើយ ជាជាងនៅខាងក្រៅដែលពួកគេអាចត្រូវបានគេសង្កេតឃើញ។ ជាញឹកញាប់អ្វីដែលត្រូវបានសង្កេត មិនចាំបាច់ឆ្លុះបញ្ចាំងឱ្យត្រឹមត្រូវពីអ្វីដែលកំពុងប្រព្រឹត្តទៅនៅក្នុងចិត្តរបស់យើងនោះទេ។

ឧទាហរណ៍៖ មនុស្សជាច្រើនញញឹម ទោះបីជាគេមានទុក្ខព្រួយក៏ដោយ ឬសើចសូម្បីតែនៅពេលដែលពួកគេមិនបានជួបរឿងដែលគួរឱ្យអស់សំណើច។

**ខ) គ្រូគឺជាអ្នកអនុវត្ត**

ការយល់ដឹងចិត្តវិទ្យា មានតម្លៃជាពិសេសសម្រាប់អ្នកដែលមានវិជ្ជាជីវៈទាក់ទងនឹងអន្តរកម្មជាញឹកញាប់ជាមួយសិស្ស ដែលគ្រូមានកម្រិតនៃការទទួលខុសត្រូវចំពោះលទ្ធផលរបស់សិស្ស ដែលប្រឈមមុខជាមួយ ភារកិច្ច និងការងារដែលពិបាកក្នុងការគ្រប់គ្រង។ តាមរយៈលោក **Doyle (1986)** បានកំណត់លក្ខណៈពិសេស៦យ៉ាងនៃបរិស្ថានថ្នាក់រៀន និងតួនាទីរបស់គ្រូមានដូចតទៅ៖

- **ទិដ្ឋភាពចម្រុះ** (Multidimensionality) គ្រូបង្រៀនម្នាក់ត្រូវដោះស្រាយជាមួយនឹងទិដ្ឋភាពជាច្រើន និងប្រភេទផ្សេងៗនៃអាកប្បកិរិយារបស់សិស្សរួមមាន ការកំណត់ពេលវេលា ឬម៉ោងសិក្សា ការសង្កេត ការកត់ត្រា ប្រតិកម្មរបស់សិស្ស និងការវាយតម្លៃចំពោះសិស្សដែលអាចមាននៅក្នុងថ្នាក់ និងកិច្ចការដែលសិស្សភាគច្រើនអាចបំពេញដោយខ្លួនពួកគេបាន។
- **ក្នុងពេលដំណាលគ្នា** (Simultaneity) ប្រភេទនៃអាកប្បកិរិយាទាំងអស់នេះ អាចនឹងកើតមានឡើងក្នុងពេលតែមួយ។
- **ភាពរហ័សរហួននិងទាន់ពេល (Immediacy)** ប្រតិកម្មរបស់គ្រូត្រូវតែកើតមាននៅពេលដែលអាកប្បកិរិយារបស់សិស្សកើតមានឡើង។
- **មិនអាចទាយទុកជាមុនបាន (Unpredictability)** គ្រូអាចនឹងប្រឈម ឬមិនបានគិតទុកជាមុននូវអ្វីដែលនឹងកើតមានឡើង។
- **លក្ខណៈសាធារណៈនៃថ្នាក់រៀន(Public nature of the classroom)** សិស្សគ្រប់រូប ទទួលដឹង

នូវអ្វីដែលគ្រូធ្វើ ទោះបីជាចូលរួមសកម្មភាពជាមួយសិស្សផ្សេងទៀតក៏ដោយ។

- **លក្ខណៈជាប្រវត្តិសាស្ត្រ** សិស្សតែងតែគិតទុកជាមុន និងប្រតិកម្មចំពោះអាកប្បកិរិយាពីមុនរបស់គ្រូនៅក្នុងស្ថានភាពស្រដៀងគ្នានឹងអតីតកាល។

## ១.៣.៥ អត្ថប្រយោជន៍នៃចិត្តវិទ្យាអប់រំ

សារៈសំខាន់នៃចិត្តវិទ្យាអប់រំ១ ពិតជាមានអត្ថន័យ និងអត្ថប្រយោជន៍យ៉ាងធំធេង សម្រាប់គ្រូបង្រៀននៅក្នុងការទទួលយកទស្សនៈ ចំណេះដឹង និងគោលការណ៍ណែនាំនានា ក្នុងការដឹកនាំសិស្សធ្វើកិច្ចការដែលទាក់ទងទៅនិងការបង្រៀនរបស់ខ្លួន។ លោកគ្រូអ្នកគ្រូ ក៏បានមើលឃើញទំនួលខុសត្រូវរបស់សិស្ស មានដូចជាការយល់ដឹង ការលូតលាស់ និងការអភិវឌ្ឍ។ ជាពិសេសចិត្តវិទ្យាអប់រំ១ ចូលរួមចំណែកជួយឱ្យគ្រូប្រើប្រាស់បច្ចេកទេស និងវិធីសាស្ត្របង្រៀនផ្សេងៗប្រកបដោយភាពច្នៃប្រឌិត។ម្យ៉ាងទៀត គឺជួយគ្រូឱ្យដឹងថាការរៀនរបស់សិស្សមានតម្រូវការរបៀបណា?ងាយស្រួលគ្រូបានត្រៀមលក្ខណៈទុកជាមុនក្នុងការរៀបចំការបង្រៀន និងរៀនឱ្យបានល្អ។ ពិសេសការលើកទឹកចិត្តក្នុងការរៀនរបស់សិស្សឱ្យទទួលបានការរៀន ប្រកបដោយគុណភាព តាមរយៈការប្រើប្រាស់នូវសក្តានុពលរបស់ពួកគេ។

## ១.៤ សន្និដ្ឋាន

ជារួមការសិក្សាអំពីសញ្ញាណទូទៅនៃចិត្តវិទ្យា បានផ្តល់នូវចំណេះដឹងជាមូលដ្ឋាននៃចិត្តវិទ្យាអប់រំ នឹងជំនាញនានា នៅក្នុងការអនុវត្តទ្រឹស្តី និងដោះស្រាយការលំបាកពីការបង្រៀននៅក្នុងថ្នាក់ ជាពិសេសជួយដល់លោកគ្រូ អ្នកគ្រូ ក្នុងការសង្កេតការបង្រៀនដែលមានលក្ខណៈជាប្រព័ន្ធនិងពន្យល់ពីអាកប្បកិរិយា ដែលមានលក្ខណៈជាចលករ។ ការសិក្សាអំពីសញ្ញាណទូទៅនៃចិត្តវិទ្យា បានជួយដល់គ្រូបង្រៀនក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈសិស្ស តាមរយៈ ដំណើរការអប់រំទាំងមូល ដោយផ្តោតលើការជួយគ្រូឱ្យបន្តការកែតម្រូវវិធីសាស្ត្របង្រៀន និងរៀនរបស់សិស្សឱ្យសមស្របទៅនិង តម្រូវការរបស់ពួកគេ ពិសេសជាងនេះទៅទៀតគ្រូអាចដឹងពីបញ្ហា និងភាពខុសប្លែកគ្នារបស់សិស្សដែលតែងតែកើតមាននៅក្នុងថ្នាក់រៀន ដែលជួយឱ្យគ្រូបង្រៀនអាចរិះរករបៀបដោះស្រាយនូវបញ្ហាសិក្សារបស់សិស្ស និងស្វែងរកការវាយតម្លៃមួយចំនួនដែល ស្របតាមគោលបំណងនៃការបង្រៀន និងការរៀន។

## សំណួរត្រិះរិះ

១. តើអ្វីដែលគិតស្រមៃឃើញ នៅពេលដែលអ្នកបានឮឈ្មោះមុខវិជ្ជាចិត្តវិទ្យាអប់រំ?

២.ហេតុអ្វីបានជាមុខវិជ្ជាចិត្តវិទ្យាអប់រំមានសារៈសំខាន់សម្រាប់ការបង្រៀន និងរៀន?

# មេរៀនទី២ ការអភិវឌ្ឍសង្គម១៖ ចំណងក្តីស្រឡាញ់

( Attachment )

## ២.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹង៖

- បកស្រាយបញ្ញត្តិចំណងក្តីស្រឡាញ់របស់កូនទៅលើឪពុកម្តាយ ឬអ្នកមើលថែ
- កំណត់បានអំពីឥទ្ធិពលរបស់ឪពុកម្តាយ ឬអ្នកមើលថែ ទៅលើចំណងក្តីស្រឡាញ់របស់កូន
- មានស្មារតីយកចិត្តទុកដាក់ក្នុងការស្វែងយល់ពីការអភិវឌ្ឍសង្គម ដូចជា ទំនាក់ទំនងអន្តរបុគ្គលឱ្យកាន់តែល្អប្រសើរ ។

## ២.២ សេចក្តីផ្តើម

ការយល់ដឹងអំពីចំណងក្តីស្រឡាញ់រវាងឪពុកម្តាយ ឬអ្នកមើលថែជាមួយកូន ឬកុមារវានឹងអាចជួយឲ្យអ្នកបានយល់ដឹងពីខ្លួនឯងកាន់តែច្បាស់ រួមទាំងជួយអ្នក និងកូនៗ ឬកុមារឲ្យតម្រង់ឆ្ពោះទៅរកការកសាងទំនាក់ទំនងជាមួយអ្នកដទៃបានកាន់តែល្អប្រសើរឡើង។ ម្យ៉ាងទៀតការយល់ដឹងអំពីចំណងនៃក្តីស្រឡាញ់ ក៏អាចជាលទ្ធផលល្អមួយ ក្នុងការទទួលបានភាពជោគជ័យនៅក្នុងគ្រួសារ សាលារៀន និងសង្គម អាស្រ័យមកពីការកសាងទំនាក់ទំនងមួយនេះផងដែរ។

## ២.៣ ខ្លឹមសារ

### ២.៣.១ បញ្ញត្តិនៃចំណងក្តីស្រឡាញ់

ចំណងក្តីស្រឡាញ់ (Attachment) គឺជាការពិពណ៌នាអំពី ទំនោររបស់ទារកដែលទាមទាររកភាពស្និទ្ធស្នាល ពីបុគ្គលពិសេស(ម្តាយ) នឹងដើម្បីទទួលបានអារម្មណ៍សុវត្ថិភាពនៅពេលម្តាយមានវត្តមាននៅទីនោះ (Atkinson and Hilgards introduction to psychology, 16 edition)។

កាលដំបូង ចិត្តវិទូមួយចំនួនបានផ្ដល់នូវទ្រឹស្ដីអំពីចំណងក្ដីស្រឡាញ់ ដែលកើតឡើងដោយសារតែម្ដាយជាអ្នកផ្ដល់តម្រូវការជាមូលដ្ឋាន(ចំណីអាហារ) ម្យ៉ាងទៀតម្ដាយក៏ជាប្រភពនៃការផ្ដល់ការចិញ្ចឹមបីបាច់ដល់កូនៗ។

❖ *<u>ប៉ុន្ដែវាមិនឆ្លុះបញ្ចាំងការពិតទាំងអស់នោះទេ!</u>*

ឧទាហរណ៍៖ កូនមាន់ រកចំណីដោយខ្លួនឯងតាំងពីកើតមក ប៉ុន្ដែពួកវានៅតែដើរតាមមេរបស់វា។ ដូច្នេះភាពសុខស្រួលរបស់ទារក បានមកពីវត្តមានរបស់ម្ដាយ ដែលវាមិនមែនចេញតែពីតួនាទីក្នុងការផ្ដល់ចំណីតែមួយមុខនោះឡើយ ។

មានពិសោធដ៏ល្បីមួយ ជាមួយសត្វស្វា ដែលវាបង្ហាញថា ចំណងក្ដីស្រឡាញ់រវាងមេស្វា និងកូនស្វារបស់វាមាន ច្រើនជាងការផ្ដល់ចំណី (Harlow & Harlow, 1969)។

កូនស្វាត្រូវបានគេយកចេញពីមេរបស់វា ភ្លាមបន្ទាប់ពីកើត ហើយគេក៏យកកូនស្វានោះទៅទុកជាមួយស្វាពីរក្បាល (ធ្វើពីលួស មានក្បាលឈើ) ស្វាមេទីមួយ គឺធ្វើពីលួសសុទ្ធហើយមេស្វានោះអាចផ្ដល់ទឹកដោះគោ ដែលមាននៅក្នុងដប ដាក់ភ្ជាប់និងទ្រូងរបស់វាផងដែរ។ ហើយមេស្វាទីពីរ គ្របដោយកៅស៊ូស្នោ និងមានក្រណាត់គ្របដែលគួរឱ្យស្រឡាញ់ និងងាយតោងលេង ។

ការពិសោធបានព្យាយាមកំណត់ថាតើកូនស្វាដែលនៅជាប់នឹងម្ដាយតែងតែជាប្រភពនៃអាហារឬយ៉ាងណា?ជាលទ្ធផលបានបង្ហាញយ៉ាងច្បាស់ថា មិនមែនមេស្វាផ្ដល់អាហារធ្វើឱ្យមានភាពកក់ក្ដៅនោះទេ គឺកូនស្វាបានចំណាយពេលវេលារបស់ខ្លួននៅជាប់នឹងមេស្វាដែលមានក្រណាត់គ្រប។

ទំនាក់ទំនងអសកម្មមានក៏ពិតមែន ជាមួយមេស្វាដែលមានក្រណាត់គ្រប(មេស្វាទី២) តែវាជាមេស្វាដែលទន់ភ្លន់ សុខស្រួល ផ្ដល់ភាពកក់ក្ដៅ ហើយបានផ្ដល់នូវប្រភពនៃសុវត្ថិភាព។

ជាក់ស្ដែងបើគេដាក់កូនស្វាឱ្យនៅក្នុងបរិយាកាសចម្លែក គួរឱ្យខ្លាច វាត្រូវបានបន្ធូរបន្ថយការភ័យខ្លាចប្រសិនបើកូនស្វាអាចមានទំនាក់ទំនងជាមួយមេស្វាដែលមានក្រណាត់(មេស្វាទី២) ។



*រូបភាព 3៖ )Atkinson and Hilgards introduction to psychology, 16 edition(*

ម្យ៉ាងទៀតមានការពិសោធមួយទៀតដែលធ្វើឡើងដោយ Mary Ainsworth ជាសមាជិកនៃសមាគមន៍របស់លោក Bowlby ដែលធ្វើការសង្កេតទៅលើកូន និងម្ដាយរបស់ពួកគេ នៅក្នុងប្រទេសយូហ្គាន់ដា និង សហរដ្ឋអាមេរិក។ ក្រោយមកគាត់បានអភិវឌ្ឍទៅជានិតិវិធីក្នុងការពិសោធ ដើម្បីវាយតម្លៃអំពីសុវត្ថិភាព នៃចំណងក្ដីស្រឡាញ់របស់កូន ដែលមានអាយុពី១២ ទៅ១៨ខែ។ និតិវិធីនោះត្រូវបានគេហៅថា **ស្ថានភាពចម្លែក** (strange situation) វាជាលំនាំសាច់រឿងមួយដែលចែកជាដំណាក់កាលក្នុងការសង្កេតលើកុមារ ខណៈដែលអ្នកមើលថែ ចាកចេញ និងចូលមកកាន់បន្ទប់វិញ។

តាមរយៈលទ្ធផលនៃការពិសោធនេះ គេធ្វើការសង្កេតដោយ ដាក់កុមារនៅក្នុងបន្ទប់ដែលមានកញ្ចក់អាចមើលឃើញតែម្ខាង(one-way mirror) និងការសង្កេតផ្សេងទៀតត្រូវបានគេកត់ត្រា។

គេកត់សម្គាល់ថា:

- សកម្មភាព និងការលេងរបស់កុមារមានទំនាក់ទំនងគ្នាទៅវិញទៅមក
- ការយំ និងសញ្ញាតានតឹងចិត្តផ្សេងៗបានកើតឡើង
- ត្រូវការនៅក្បែរ ដើម្បីទទួលបានការចាប់អារម្មណ៍ពីម្ដាយ
- ត្រូវការនៅក្បែរ ដើម្បីចង់មានទំនាក់ទំនងជាមួយអ្នកចម្លែកមុខ

**លំនាំសាច់រឿង** ( Table 3.1, page 90 )

Atkinson and Hilgards introduction to psychology, 16 edition

១- ម្ដាយ និងកូនចូលទៅក្នុងបន្ទប់។ ម្ដាយដាក់កូននៅលើកម្រាល ដោយមានតុក្កតាលេង រួចដើរទៅអង្គុយនៅជ្រុងម្ខាងទៀតនៃបន្ទប់។

២- ស្ត្រីប្លែកមុខម្នាក់ទៀតចូលមក ដោយអង្គុយស្ងៀមស្ងាត់ប្រហែល១នាទី រួចនិយាយជាមួយម្ដាយប្រហែល១នាទី បន្ទាប់មកគាត់ក៏ចូលទៅលេងតុក្កតាជាមួយកុមារ។

៣- ម្ដាយបានដើរចេញពីបន្ទប់ដោយមិនឲ្យកូនចាប់អារម្មណ៍។ ប្រសិនបើកូនមិនរករឿង (យំ)ស្ត្រីប្លែកមុខត្រឡប់អង្គុយដោយស្ងៀមស្ងាត់វិញ។ តែបើកូននោះរករឿង (យំ)ស្ត្រីនោះនឹងលួងកុមារ។

៤- ម្ដាយត្រឡប់មកវិញ រួចលេងជាមួយកូន ហើយស្ត្រីប្លែកមុខ ដើរចេញពីបន្ទប់។

៥- ម្ដាយដើរចេញពីបន្ទប់ម្ដងទៀត ពេលនេះគឺទុកឲ្យកូនគាត់នៅក្នុងបន្ទប់តែឯង។

៦- ស្ត្រីប្លែកមុខត្រឡប់មកវិញ។ បើកូននោះរករឿង( យំ) គាត់និងលួងកុមារនោះ។

៧- ម្តាយត្រឡប់មកវិញ ហើយស្រ្តីប្លែកមុខ គេចចេញពីបន្ទប់។

## ២.៣.២ ប្រភេទនៃចំណងក្តីស្រឡាញ់

ជាបឋមតាមរយៈអាកប្បកិរិយាទាំងនេះដែលកើតចេញពីការពិសោធន៍ដោយMaryAinsworth គេបានបែងចែកក្តីស្រឡាញ់ជា៣ប្រភេទ។

**ក) ចំណងក្តីស្រឡាញ់ដែលស្វែងរកសុវត្ថិភាព(Securely attached)**ថ្វីបើកុមារមិនសប្បាយចិត្ត(យំ) នៅពេលដែលម្តាយមិននៅ ឬទុកទារកចោល ចំណងក្តីស្រឡាញ់ប្រភេទនេះគឺ កុមារទាមទារឲ្យម្តាយមានទំនាក់ទំនង(លួង)ពេលដែលម្តាយត្រឡប់មកវិញ។ ចំណែកឯកុមារខ្លះ សប្បាយចិត្តនៅពេលដឹងថាម្តាយត្រឡប់មកវិញ ហើយគាត់ក៏បន្តលេងជាមួយតុក្កតារបស់គាត់វិញ កុមារខ្លះទៀតទាមទារការមានទំនាក់ទំនងរាងកាយជាមួយម្តាយដូចជា (បី ពរ ក្រសៃភ្នែក សំលេង)។ កុមារខ្លះពិបាកខ្លាំង (តានតឹងចិត្តខ្លាំង)នៅពេលដែលម្តាយទុកពួកគាត់ចោល។




*រូបភាព 4៖ចំណងក្តីស្រឡាញ់ដែលស្វែងរកសុវត្ថិភាព )Securely attached(*

*រូបភាពយកពី: [http://ardacigin.blogspot.com//2016](http://ardacigin.blogspot.com//2016)*

ជារួមគេកត់សម្គាល់ឃើញ៖

- ទារកឬ កុមារអាចបំបែកចេញ(ម្តាយមិននៅក្បែរ)
- ទារកឬ កុមារទាមទារការលួងពីម្តាយ នៅពេលដែលគាត់ភ័យ ខ្លាច
- ទារកឬ កុមារមានអារម្មណ៍ល្អពេលម្តាយឬ(អ្នកមើលថៃ)ត្រឡប់មកវិញ

- ចំពោះឪពុកម្ដាយ៖ មានស្ម័យភាពឆ្លើយតបតម្រូវការកុមារទាន់ពេលវេលានិងសម្រប ខ្លួនជាមួយពួកគាត់បាន។

**ខ) ចំណងក្ដីស្រឡាញ់ដែលមិនទាមទារសុវត្ថិភាព(Insecurely Attached: Avoidant)**

ទារក ឬកុមារទាំងនេះមិនអើពើទំនាក់ទំនងជាមួយ និងម្ដាយនៅពេលដែលគាត់ត្រឡប់មកវិញ (ជួបគ្នាវិញ)។ កុមារខ្លះមិនអើពើជាមួយម្ដាយទាំងស្រុងនោះទេ ពេលខ្លះមានបំណងចង់មកក្បែរ ឬក៏ចង់គេចចេញពីឪពុកម្ដាយ។ កុមារដែលមិនអើពើ អាចនឹងចាប់អារម្មណ៍ បន្តិចបន្តួចជាមួយម្ដាយនៅពេលដែលគាត់ មានវត្តមាននៅក្នុងបន្ទប់ នឹងជួនកាល ហាក់ដូចជាមិនមានភាពតានតឹងចិត្ត(យំ) នៅពេលដែលម្ដាយទុកពួកគាត់ចោលឡើយ។




*រូបភាព 5៖ចំណងក្ដីស្រឡាញ់ដែលមិនទាមទារសុវត្ថិភាព )Insecurely Attached: Avoidant)*

➢ ជារួមគេកត់សម្គាល់ឃើញ៖

- ទារក ឬកុមារអាចមិនអើពើជាមួយម្ដាយ
- ទារកឬ កុមារមិនទាមទារឱ្យលួងច្រើនទេ ឬមិនត្រូវការទំនាក់ទំនងពីម្ដាយ
- ទារកឬ កុមារមិនចាប់អារម្មណ៍ ឬចាប់អារម្មណ៍តិចតួច ជាមួយម្ដាយ ឬអ្នកមើលថៃ
- ចំពោះឪពុកម្ដាយ៖ បដិសេដ មិនអើពើ និងដកខ្លួនចេញពីកូន

**គ) ចំណងក្ដីស្រឡាញ់ដែលមិនច្បាស់លាស់ (Ambivalent)**

ទារក ឬកុមារជំទាស់ ខឹងជាមួយនឹងម្ដាយ នៅពេលដែលម្ដាយត្រឡប់មកវិញ។ ទារកឬ កុមារបញ្ចេញសកម្មភាពព្រមគ្នា ទាំងការទាមទារ ឬខឹង និងមិនចង់មានទំនាក់ទំនងផ្នែករាងកាយដូចជាការ (អោប ថើប បី ក្រសៃភ្នែក សំលេងច្រៀងបំពេរ)ពីម្ដាយឡើយ។




*រូបភាព 6៖ចំណងក្តីស្រឡាញ់ដែលមិនច្បាស់លាស់ (Ambivalent)*
*រូបភាពយកពីhttp://ardaclgirl.blogspot.com/2016/*

➢ ជារួមគេកត់សម្គាល់ឃើញ៖

- ទារក ឬកុមារអាចបង្ហាញចេញដោយការប្រុងប្រយត្ន័ជាមួយមនុស្សប្លែកមុខ
- ទារក ឬកុមារមានភាពតានតឹងចិត្តខ្លាំង យំខ្លាំង នៅពេលម្តាយទៅចោល
- ទារក ឬកុមារមិនសុខស្រួល ឬ(ស្ងប់ចិត្ត)ទោះជាម្តាយត្រឡប់មកវិញក៏ដោយ
- ចំពោះឪពុកម្តាយ៖ ជាប់ជំពាក់ជាមួយកូនរហូត

## ២.៤ សន្និដ្ឋាន

ទ្រឹស្តីចំណងក្តីស្រឡាញ់ គឺជាទ្រឹស្តីដែលបង្ហាញពីទំនាក់ទំនងជិតស្និទ្ធរវាង(កូន និង ម្តាយ) ឬអ្នកមើលថែ ដែលមានបំណងចង់ទាមទារការស្រឡាញ់ ឬការនៅក្បែរពីពួកគាត់។ សំដៅគិតទៅដល់គម្លាតមួយដែលកូន ឬកុមារមានអារម្មណ៍សុខស្រួល ដោយផ្អែកលើកត្តាដូចជា អាយុ ប្រវត្តិនៃការរីកធំធាត់ ជំងឺ អារម្មណ៍ភ័យខ្លាច ទាំងនោះតម្រូវឲ្យមានចំណងអាកប្បកិរិយានេះកើតឡើង។

ចំណុចសំខាន់គឺ មូលដ្ឋាននៃសុវត្ថិភាពដែលផ្តល់នូវចំណុចចាប់ផ្តើមដល់ការស្វែងយល់ និងការរុករកនូវពិភពជុំវិញខ្លួនរបស់កុមារ។ នៅពេលដែលមានស្ថានភាពគ្រោះថ្នាក់កុមារស្វែងរកចំណងភ្ជាប់ជាមួយម្តាយ ឬអ្នកមើលថែ ហើយនៅពេលស្ថានភាពគ្រោះថ្នាក់បានកន្លងផុត វត្តមានរបស់ឪពុកម្តាយ ឬអ្នកមើលថែគឺអាចឲ្យកុមារបន្តការលេងពួកគេបាន។

| ចំណងក្តីស្រឡាញ់ដែលមានសុវត្ថិភាព | ចំណងក្តីស្រឡាញ់ដែលមិនមានសុវត្ថិភាព/អើពើ | ចំណងក្តីស្រឡាញ់ដែលមិនច្បាស់លាស់/ថប់បារម្ភ |
|---|---|---|
| • ទទួលបានភាពកក់ក្តៅនិងដែលកើតចេញពីធម្មជាតិ<br>• មានភាពរីករាយជាមួយអ្នកជាទីស្រឡាញ់ ដោយមិនមានការបារម្ភហួសហេតុ<br>• មិនមានភាពអស់សង្ឃឹមក្នុងទំនាក់ទំនង<br>• យល់ដឹងពីអារម្មណ៍របស់ខ្លួន និងដៃគូ<br>• អាចចែករំលែកភាពជោគជ័យ ឬការលំបាក<br>• អាចស្វែងរកការជួយ បើត្រូវការ<br>• មានស្វ័យភាព<br>• ឆ្លើយតបទាន់ពេលវេលា | • ជាបុគ្គលដែលផ្តោតលើភាពឯករាជ្យ និងការបំពេញនូវតម្រូវការផ្ទាល់ខ្លួន<br>• មិនសូវចង់នៅស្និទ្ធស្នាលជាមួយអ្នកដទៃ<br>• មានអារម្មណ៍មិនសុខស្រួលនៅពេលមានអ្នកនៅក្បែរ<br>• កើតចេញពីធម្មជាតិ<br>• មិនខ្វល់ខ្វាយជាមួយអ្នកជាទីស្រឡាញ់<br>• មិនសូវជាបើកចំហរទៅដៃគូ<br>• មានលក្ខណៈមិនអើពើ (នៅឆ្ងាយពីគេឯង មិនរាប់រកគេ)។ | • ជាបុគ្គលដែលចង់នៅក្បែរអ្នកជាទីស្រឡាញ់<br>• ខ្លាចអ្នកជាទីស្រឡាញ់មិននៅក្បែរ<br>• ទំនាក់ទំនងពឹងផ្អែកលើអារម្មណ៍<br>• ឆាប់ប្រតិកម្ម<br>• គិតរឿងអវិជ្ជមានមកដាក់ក្នុងខ្លួន<br>• ខ្វល់ខ្វាយចិត្តច្រើន<br>• ឆាប់សោកស្តាយ<br>• ឆាប់ពេញចិត្តគេ នៅពេលគេផ្តល់សុវត្ថិភាពដល់ខ្លួន<br>• មិនសូវមានការប្តេជ្ញាចិត្ត<br>• ទាញអ្នកដទៃឲ្យចូលរួម |

## សំណួរត្រិះរិះ

១. ដើម្បីឲ្យចំណងក្តីស្រឡាញ់មានភាពរឹងមាំ តើយើងគួរប្រកាន់យកនូវគោលការណ៍អ្វីខ្លះ ?

២. តើអ្នកស្ថិតក្នុងប្រភេទនៃចំណងក្តីស្រឡាញ់មួយណា ?ហេតុអ្វី ?

# មេរៀនទី៣ ការអភិវឌ្ឍសង្គម២ ៖ ទ្រឹស្តីចិត្ត

( Theory of Mind )

## ៣.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹង៖

- ប្រាប់បានពីបញ្ញត្តិនៃទ្រឹស្តីនៃចិត្ត
- កំណត់បានពីដំណាក់កាលអភិវឌ្ឍទាំងបីរបស់កុមារតាមរយៈទ្រឹស្តីនៃចិត្ត
- មានទម្លាប់យកទ្រឹស្តីនៃចិត្តទៅប្រើប្រាស់នៅក្នុងការអប់រំ ។

## ៣.២ សេចក្តីផ្តើម

មនុស្សពេញវ័យ អាចសម្តែងចេញនូវសកម្មភាព និងការគិត តាមរយៈការឆ្លុះបញ្ចាំងពីការយល់ដឹងរបស់ខ្លួនទៅលើលក្ខណចិត្តរបស់អ្នកដទៃដែលមាននៅក្នុងចិត្តដូចជា (ការគិត ការរំពឹងទុក ជំនឿ និងការសន្មត)។ ពេលខ្លះឆ្លុះបញ្ចាំងពីដំណើរការគិតរបស់ខ្លួនឯងតាមរយៈ (ការវាយតម្លៃពីស្ថានភាពដែលកើតមានឡើង របៀបដែលយើងមានជំនឿទៅលើអ្វីមួយ ឬកំហុសអ្វីមួយដែលកើតមានឡើង)។ ការគិតរបៀបនេះ ត្រូវបានគេឲ្យឈ្មោះថា Metacognition ៖ គឺការគិត ឬការឆ្លុះបញ្ចាំងពីរបៀបគិតផ្ទាល់ខ្លួន។

ឧទាហរណ៍៖ សិស្សដឹងពីរបៀបរៀនរបស់ខ្លួន។ បុគ្គលដឹងពីរបៀបដោះស្រាយបញ្ហារបស់ខ្លួន។

ដោយឡែកមនុស្សយើងម្នាក់ៗមានសមត្ថភាពក្នុងការយល់ដឹងពីអ្នកដទៃ តាមរយៈការគិតរបស់ខ្លួន តាំងពីកុមារភាព(៦ ទៅ៩ខែ) ដែលជាទូទៅទារកមានលទ្ធភាពប្រាប់អំពីវត្ថុ ឬព្រឹត្តការណ៍អ្វីមួយទៅអ្នកដែលនៅជុំវិញខ្លួន តាមរយៈការសម្លឹងមើលកាយវិការរបស់អ្នកទាំងនោះ។ បម្រុងប្រយត្ន័នេះ គេឱ្យឈ្មោះថា បម្រុងប្រយត្ន័រួម Joint Attention (Bakeman & Adamson, 1984; Scaife & Bruner, 1975. Atkinson and Hilgards Introduction to Psychology, 16 Edition, Page82)។ បម្រុងប្រយត្ន័រួមមានលក្ខណៈស៊ីជម្រៅ នៅក្នុងការអភិវឌ្ឍផ្នែកភាសា និង ការទំនាក់ទំនងនៅក្នុងសង្គម។

## ៣.៣ ខ្លឹមសារ

### ៣.៣.១ បញ្ញត្តិ ៖ តើទ្រឹស្តីនៃចិត្តជាអ្វី?

ផ្តើមចេញពីមូលដ្ឋាននៃការរីកចម្រើន បម្រុងប្រយ័ត្នរបស់កុមារអភិវឌ្ឍន៍បានតាមរយៈសភាពចិត្ត ដូចជា ការចង់បាន ការយល់ដឹង ជំនឿ ចំណេះដឹង ការគិត បំណងប្រាថ្នា និងអារម្មណ៍។ ការរីកចម្រើនទាំងនេះត្រូវបានគេហៅថាជា ទ្រឹស្តីនៃចិត្ត Theory of mind ។ ម្យ៉ាងទៀត ទ្រឹស្តីចិត្ត គឺជាការយល់ដឹងថា អ្នកដទៃមានគោលបំនង សេចក្តីប្រាថ្នា ជំនឿ ប្រត្យក្សារម្មណ៍ អារម្មណ៍ ខុសពីខ្លួនឯង ហើយទិដ្ឋភាពទាំងនោះ នឹងត្រូវបានជះឥទ្ធិពលដល់សកម្មភាព និងអាកប្បកិរិយារបស់បុគ្គលនោះផងដែរ។

កុមារត្រូវបានគេយកមកធ្វើជាកម្មវត្ថុនៃការសិក្សាក្នុងទ្រឹស្តីចិត្តនេះ តាមរយៈការដែលកុមារមានបម្រុងប្រយត្ន័ ដូច្នេះពួកគេមានការអភិវឌ្ឍនូវការយល់ដឹង ការគិត ការចង់បាន និងជំនឿ។

ឧទាហរណ៍៖ នៅពេលម្តាយនិយាយទៅកាន់កូនថា កូនឃើញតុក្កតានៅទីនោះទេ? ដោយម្តាយមើល និងចង្អុលទៅកាន់តុក្កតា កុមារនិងសម្លឹងតាម និងចង្អុលទៅរកតុក្កតានោះ។

ឧទាហរណ៍៖ ការចង្អុលទៅកាន់អ្វីមួយដើម្បីទាញបម្រុងប្រយ័ត្នពីមនុស្សធំ នោះកុមារអាចក៏ដឹងថាចិត្តរបស់មនុស្សធំ ខុសពីចិត្តរបស់ខ្លួនឯង។



*រូបភាព 7៖ ទាក់ទងទ្រឹស្តីចិត្ត*

*រូបភាពយកពីសៀវភៅ: Atkinson and Hilgards introduction to psychology, 16 edition*

- ការសិក្សាពីទ្រឹស្តីនៃចិត្តតាមរយៈលោក (Flavell,1999)

គេធ្វើពិសោធន៍ជាមួយកុមារអាយុ៥ឆ្នាំ ជាមួយនឹងប្រអប់ស្ករគ្រាប់៖

អ្នកពិសោធន៍៖ បង្ហាញប្រអប់មួយដែលមានរូបស្ករគ្រាប់ទៅកាន់កុមារអាយុ៥ឆ្នាំម្នាក់។ រួចសួរទៅកាន់កុមារទី១ឲ្យទាយ តើកុមារគិតថាមានអ្វីនៅក្នុងប្រអប់នេះ?

**កុមារទី១៖** ឆ្លើយថា ស្ករគ្រាប់។ រួចកុមារបើកមើល។ គាត់ក៏ភ្ញាក់ផ្អើល ដោយការពិតនៅក្នុងប្រអប់មានតែខ្មៅដៃ មិនមែនស្ករគ្រាប់ទេ!។

**អ្នកពិសោធ៖** បន្ទាប់មកសួរកុមារទី១ដដែល។ តើកុមារផ្សេងទៀតដែលមិនទាន់បានមើលនៅក្នុងប្រអប់ តើពួកគេនឹងគិតថាមានអ្វីនៅក្នុងប្រអប់នោះ?

**កុមារទី១៖** ឆ្លើយថា ស្ករគ្រាប់ ។ដោយមិនទាន់បានមើលនៅក្នុងប្រអប់ផង(គាត់មើលឃើញរូបស្ករគ្រាប់នៅខាងក្រៅប្រអប់គាត់ក៏គិតថាត្រូវបានគេបោកប្រាស់

**អ្នកពិសោធ៖** បន្ទាប់មក ព្យាយាមប្រើវិធីដដែល រួចសួរកុមារទី២ដែលមានអាយុត្រឹម៣ឆ្នាំឲ្យទាយ តើមានអីនៅក្នុងប្រអប់នេះ?

**កុមារទី២ ឆ្លើយថា ស្ករគ្រាប់**(កុមារអាយុ៣ឆ្នាំ និង៥ឆ្នាំឆ្លើយដូចគ្នា)។ **សួរទៅកុមារទី២**ដដែល ប្រសិនបើកូនសួរទៅកុមារដទៃទៀតដែលមិនបានមើលនៅក្នុងប្រអប់តើគាត់គិតថាមានអ្វីនៅក្នុងនោះ?

គឺឆ្លើយថាខ្មៅដៃ ។ ហេតុអ្វីបានជាកុមារអាយុ៣ឆ្នាំឆ្លើយថាខ្មៅដៃ ?

នៅពេលដែលកុមារមិនទាន់បានមើលនៅក្នុងប្រអប់ គាត់ទំនងជាគិតថាជាស្ករគ្រាប់ដោយសារនៅក្រៅប្រអប់មានគំនូសរូបស្ករគ្រាប់។ នៅពេលដែលគេបើកប្រអប់ឱ្យមើលឃើញថាមានខ្មៅដៃនៅក្នុងប្រអប់ហើយ គិតថាអ្នកដទៃដែលមិនបានមើលនៅក្នុងប្រអប់ក៏គិតដូចខ្លួនដែរថាមានខ្មៅដៃនៅក្នុងប្រអប់។ តាមការពិតកុមារអាយុ៣ឆ្នាំពិបាកបែងចែករវាងចំណេះដឹងដែលខ្លួនមាននិងចំណេះដឹងរបស់អ្នកដទៃ(កុមារអាយុ៣ឆ្នាំមានការគិតត្រឹមតែរូបីយ៍)ការគិតរបស់ខ្លួនដូចនិងការគិតរបស់អ្នកដទៃ។

ក៏ប៉ុន្តែចំពោះកុមារអាយុ៥ឆ្នាំអាចបែងចែកចំណេះដឹងរបស់ខ្លួន និងចំណេះដឹងរបស់អ្នកដទៃមានន័យថា បន្ទាប់ពីគេបានបើកប្រអប់ឱ្យមើលឃើញខ្មៅដៃក្នុងប្រអប់ប៉ុន្តែអ្នកមិនបានមើលក្នុងប្រអប់ប្រហែលជាឆ្លើយថាស្ករគ្រាប់ហើយ។

ដូច្នេះការបកស្រាយជាមូលដ្ឋាននៃលទ្ធផលទាំងនេះ អំពីជំនឿខុស គឺថា កុមារនៅក្នុងអំឡុងអាយុមុនពេលចូលរៀន មិនទាន់មានការយល់ដឹងពេញលេញនៅឡើយទេ ទៅលើការយល់ឃើញរបស់

អ្នកផ្សេង ដែលមានការយល់ដឹង ខុសពីខ្លួន។ ជាងនេះទៀត កុមារមិនទាន់យល់ដឹងថា មនុស្សមានជំនឿខុសៗគ្នា ទៅលើតថភាពជាក់ស្តែងនោះ។




*រូបភាព ៩៖ការពិសោធស្មារគ្រាប់ជំនឿខុសរបស់កុមារទៅលើក្មេងអាយុ៥ឆ្នាំ និង៣ឆ្នាំ*

*រូបភាពយកពី https://www.simplypsychology.org/theory-of-mind.html*

- **បង្ហាញអំពីការសម្តែងតួ ដោយ Sally and Anne Task (មានសម្ភារៈ បាល់ កញ្ច្រែងនិងប្រអប់)**




*រូបភាព 9៖ការសម្តែងតួ ដោយ Sally and Anne Task*

**ដំណើរការសម្តែង!**

១. Sally ដាក់បាល់ នៅក្នុងកញ្ច្រែង

២. ហើយគាត់ដើរចេញទៅណាបាត់

៣. កំឡុងពេលSallyមិននៅ Anneយកបាល់ ពីកញ្ច្រែងទៅដាក់ក្នុងប្រអប់

៤. Sally បានត្រឡប់មកវិញ។ តើអ្នកគិតថាSallyទៅរកបាល់ ដែលគាត់បានដាក់នៅឯណាដើម្បីទៅយកវាចេញ?

៥. ប្រសិនបើអ្នកទាំងអស់គ្នាជាកុមារអាយុ3ឆ្នាំដែលបានណែនាំដំបូងនោះឆ្លើយថាយ៉ាងម៉េច?

**ឆ្លើយថានៅក្នុងប្រអប់!**

៦.**ឆ្លើយថានៅក្នុងប្រអប់មែន**។ ដោយសារកុមារអាយុ៣ឆ្នាំប្រាកដជាពិបាកបែងចែករវាងចំណេះដឹងរបស់ខ្លួន និងចំណេះដឹងរបស់អ្នកដទៃ។

ចំណុចសម្គាល់!

- ពេលបង្កើតជំនឿដាក់ខុស គឺចំណេះដឹងដែលខ្លួនឯងមាន ចំបាច់ត្រូវខុសគ្នាពីចំណេះដឹងរបស់អ្នកដទៃមាន!

តាមរយៈឧទាហរណ៍ ចំពោះកិច្ចការ Sally and Anne អ្នកដែលកំពុងអាន ដឹងថាបាល់ ផ្លាស់ទីទៅក្នុងប្រអប់ ប៉ុន្តែ Sally មិនបានដឹងថាបាល់នៅក្នុងប្រអប់ទេ។ កិច្ចការនេះដែលធ្វើឱ្យមានភាពខុសគ្នាប្លែកគ្នារវាងចំណេះដឹងរបស់ Sally and Anne!។

សរុបមក Sally ប្រាកដជាមិនដឹងថាបាល់ បានផ្លាស់ទីពីកញ្ច្រែងមកក្នុងប្រអប់ទេ តែអ្នកដែលបានមើលរូបភាពនៃការសម្តែងទើបដឹងខ្លួនថាបាល់ នៅក្នុងប្រអប់ហើយក៏គិតថា Sally និងទៅរកនៅក្នុងប្រអប់ដែរ (គាត់មើលឃើញយ៉ាងម៉េចគាត់ក៏និងគិតថាអ្នកដ៏ទៃគិតដូចគាត់ដែរ) ។

## ៣.៣.២ ដំណាក់កាលអភិវឌ្ឍទ្រឹស្តីនៃចិត្ត

ការសិក្សាពី Theory of mind ដោយ Bartch and Wellman(1995) អ្នកទាំងពីរអះអាងថា ការអភិវឌ្ឍនូវទ្រឹស្តីនៃចិត្តនេះ កុមារឆ្លងត្រូវកាត់៣ដំណាក់កាលះ

**ក) កុមារអាយុប្រហែល២ឆ្នាំ៖**

កុមារមានការយល់ដឹងជាបឋម ដោយផ្តោតលើការចង់បានរបស់ងាយៗ ធាប់ទទួលយកអារម្មណ៍ (ការយល់ឃើញពីការពិសោធ)។ កុមារយល់ថា មនុស្សមានចំណង់ មានអារម្មណ៍ខ្លាច អាចមើលឃើញអ្វីៗនៅជុំវិញខ្លួន និងមានអារម្មណ៍ចំពោះវត្ថុទាំងនោះ។ ប៉ុន្តែកុមារមិនយល់ថា មនុស្សមានការអភិវឌ្ឍចិត្តទៅលើរូបតំណាង វត្ថុ ចំណង់ និងជំនឿនោះឡើយ។

**ខ) កុមារអាយុប្រហែល៣ឆ្នាំ៖**

កុមារចាប់ផ្តើមនិយាយចេញពីជំនឿ និងគំនិត រួមទាំងចំណង់ ហើយពួកគេហាក់ដូចជាយល់ថា ជំនឿអាចខុសឬត្រូវ (ខុសពីមនុស្សម្នាក់ទៅម្នាក់ទៀត)។ប៉ុន្តែពួកគេនៅតែបន្តយល់ថា សកម្មភាពរបស់ខ្លួន និងសកម្មភាពរបស់អ្នកផ្សេង គឺធ្វើឡើងដើម្បីចំណង់ ជាជាងដើម្បីជំនឿ។

**គ) កុមារអាយុប្រហែល៤ឆ្នាំ៖**

កុមារចាប់ផ្តើមយល់ដឹងថា ការគិត និងជំនឿរបស់មនុស្ស មានឥទ្ធិពលលើអាកប្បកិរិយារបស់ពួកគេ ហើយពួកគេអាចមានជំនឿថា វាជារឿងធម្មតាដែលមិនឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងឡើយ។ នៅចុងអាយុ៥ឆ្នាំ កុមារភាគច្រើននៅក្នុងពិភពលោក អាចឆ្លងផុត False-belief task (Callanhan et al.,2005)។

**អំពីជំនឿខុស (**False belief task) គឺសំដៅដល់កុមារតូចដែលមិនទាន់មានការយល់ដឹងពេញលេញថាអ្នកដទៃមាន ចិត្តគំនិត ជំនឿផ្សេងៗគ្នា ពីតថភាពមួយនោះឡើយ។

## ៣.៤ សន្និដ្ឋាន

ការសិក្សាអំពី ទ្រឹស្តីនៃចិត្តអាចចាត់ទុកជាជំនាញមួយរបស់កុមារក្នុងការអភិវឌ្ឍសមត្ថភាពក្នុងការស្វែងយល់ពីគំនិត និងការយកចិត្តទុកដាក់ស្វែងយល់ពីចេតនារបស់អ្នកដទៃ រួមទាំងការបង្កើនសមត្ថភាពក្នុងការគ្រាប់តាមអ្នកដទៃគឺសុទ្ធតែជាដំណើរការនៃការអភិវឌ្ឍទ្រឹស្តីនៃចិត្ត។

ជារួមទ្រឹស្តីនៃចិត្ត គឺជាយន្តការមូលដ្ឋានសំខាន់មួយ ដែលអនុញ្ញាតឱ្យកុមារមានទំនាក់ទំនងនៅក្នុងសង្គម។ប្រសិនបើគ្មានទ្រឹស្តីចិត្តទេ យើងនឹងពិបាកនៅក្នុងការប្រាស្រ័យទាក់ទងជាមួយគ្នាដើម្បីស្វែងយល់ពីគំនិត និងអាកប្បកិរិយារបស់គ្នាទៅវិញទៅមកឡើយ។

## សំណួរត្រិះរិះ

១. តើអ្នកអាចស្មានលក្ខខណ្ឌចិត្តរបស់អ្នកដទៃបានយ៉ាងដូចម្ដេច?
២. តើមានវិធីស្មានខុសគ្នាទេ តាំងពីកុមារភាពរបស់អ្នក និងរហូតមកដល់បច្ចុប្បន្ន?

# មេរៀនទី៤ ការអភិវឌ្ឍចិត្តរំភើប និងសីលធម៌

( Development of Emotion and Morality )

## ៤.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹង៖

- ពន្យល់បានអំពី ការអភិវឌ្ឍចិត្តរំភើបរបស់កុមារ
- កំណត់បានពីការអភិវឌ្ឍសីលធម៌ ដោយផ្អែកលើការសិក្សារបស់លោក Kohlberg
- មានបម្រុងប្រយ័ត្នខ្ពស់នៅក្នុងការបង្កើតសំណួរអំពីក្រមសីលធម៌ Heinz Dilemma ។

## ៤.២ សេចក្តីផ្តើម

មេរៀននេះបានផ្តោតទៅលើ ការអភិវឌ្ឍចិត្តរំភើប និងសីលធម៌។ ចិត្តរំភើបមានដូចជាការរាប់បញ្ចូលសមាសភាព និងភាពដោយឡែករបស់វា។ ចំពោះសីលធម៌ គឺផ្តោតលើ ដំណាក់កាលអភិវឌ្ឍសីលធម៌របស់ Kohlberg រួមនឹងការពិភាក្សាអំពីសំណួរទាក់ទងនឹងក្រមសីលធម៌ដោយ លោក Heinz Dilemma។

តាមរយៈមេរៀននេះ យើងក៏អាចឆ្លុះបញ្ចាំងនៅក្នុងជីវភាពរស់នៅរស់នៅប្រចាំថ្ងៃ ដែលមនុស្សគ្រប់រូបតែងមានការប្រែប្រួលសកម្មភាពនិងអារម្មណ៍ និងឥរិយាបថរបស់ខ្លួនទៅតាមតថភាពសត្យានុម័ត។ ហើយឥរិយាបថទាំងនោះវាស្តែងចេញឲ្យឃើញតាមរយៈចិត្តរំភើប។

## ៤.៣ ខ្លឹមសារ

### ៤.៣.១ បញ្ញត្តិ

#### ក) តើអ្វីជាចិត្តរំភើប?

- **ចិត្តរំភើប** (Emotion) ៖ គឺជាសភាពចិត្តដែលបង្កឡើងតាមរយៈ ការចាប់អារម្មណ៍ខ្លាំងក្លាដែលកើតមានក្នុងរយៈពេលដ៏ខ្លី។ ជាទូទៅ វាកើតតែកើតមាននៅពេលណាដែលមានហេតុការណ៍សំខាន់ណាមួយនោះផុសចេញភ្លាមៗ ក្នុងជីវភាពរស់នៅរបស់យើង។

ឧទាហរណ៍៖ សិស្សសប្បាយចិត្តខ្លាំងពេលប្រលងជាប់ ( ចិត្តរំភើបបែបវិជ្ជមាន )។

ឧទាហរណ៍៖ សិស្សមានអារម្មណ៍អស់សង្ឃឹមពេលប្រលងធ្លាក់(ជាចិត្តរំភើបបែបអវិជ្ជមាន។

ដោយឡែកការកំណត់អារម្មណ៍ គឺជាកិច្ចការដែលនៅតែបន្តសិក្សារហូត។ អ្នកស្រាវជ្រាវនៅតែសិក្សាទ្រឹស្តីអំពីអ្វី ដែលបង្កើតអារម្មណ៍របស់មនុស្សហើយទ្រឹស្តី ដែលមានស្រាប់កំពុងត្រូវបានជំទាស់ឥតឈប់ឈរ។ ទោះយ៉ាងណាក៏ដោយវាជាមូលដ្ឋានចំណេះដឹងដ៏ល្អសម្រាប់វិភាគនៅពេលដែលអ្នកចង់ស្វែងយល់ពីអំពីប្រធានបទចិត្តរំភើប។នៅក្នុងទិដ្ឋភាពនៃចិត្តរំភើប បុគ្គលអាចមានអារម្មណ៍ច្រើនហើយច្របូកច្របល់ជាមួយគ្នា។ យោងតាមសមាគមចិត្តសាស្ត្រអាមេរិក (APA) អារម្មណ៍ត្រូវបានកំណត់ថាជា "គំរូប្រតិកម្មដ៏ស្មុគស្មាញ ដែលពាក់ព័ន្ធនឹងធាតុផ្សំនៃបទពិសោធ អាកប្បកិរិយា និងសរីរវិទ្យា"។ ឬអាចហៅម្យ៉ាងទៀតថា អារម្មណ៍ គឺជារបៀបដែលបុគ្គលម្នាក់ៗអនុវត្ត។

តាមរយៈបទពិសោធន៍នៃអារម្មណ៍របស់បុគ្គល មានធាតុផ្សំបីយ៉ាងដែលប្រព្រឹត្តទៅនៅក្នុងដំណើរការនៃចិត្តរំភើប មានដូចជា៖ **បទពិសោធផ្ទាល់ខ្លួនរបស់បុគ្គល ការឆ្លើយតបខាងសរីរវិទ្យា និងការឆ្លើយតបខាងអាកប្បកិរិយា ឬការបង្ហាញ។**

**ក) បទពិសោធផ្ទាល់ខ្លួនរបស់បុគ្គល** (Subjective Experiences)

- អារម្មណ៍ទាំងអស់ចាប់ផ្តើមដោយបទពិសោធរបស់បុគ្គល ដែលត្រូវបានគេហៅម៉្យាងទៀតថាជាការជំរុញទឹកចិត្ត ប៉ុន្តែតើវាមានន័យយ៉ាងដូចម្តេច? ខណៈពេលដែលអារម្មណ៍ជាមូលដ្ឋានត្រូវបានបង្ហាញដោយបុគ្គលទាំងអស់ដោយមិនគិតពីវប្បធម៌ ឬការចិញ្ចឹមបីបាច់បទពិសោធដែលបង្កើតឱ្យបុគ្គលអាចធ្វើឱ្យគាត់មានការយល់ដឹងពីខ្លួនឯងបានកាន់តែច្រើន។
- បទពិសោធន៍ផ្ទាល់របស់បុគ្គល អាចចាប់ផ្តើមពីអ្វីដែលមានលក្ខណៈសាមញ្ញៗ។ ឧទាហរណ៍៖ ដូចជាការមើលឃើញពណ៌នៃវត្ថុ ឬរបស់អ្វីមួយ បានធ្វើឱ្យបុគ្គលភ្ជាប់ទៅអ្វីមួយដែលទាក់ទងនឹងអនុស្សាវរីយ៍របស់ខ្លួន។ មិនថាបទពិសោធច្រើនប៉ុណ្ណានោះទេ វាអាចធ្វើឱ្យអារម្មណ៍ជាច្រើនដក់ជាប់នៅក្នុងចិត្តបុគ្គល ហើយបុគ្គលម្នាក់ៗអាចមានអារម្មណ៍ខុសៗគ្នា។ ឧទាហរណ៍៖ មនុស្សម្នាក់អាចមានអារម្មណ៍ខឹង និងសោកស្តាយចំពោះការបាត់បង់មនុស្សជាទីស្រឡាញ់ ខណៈពេលដែលមនុស្សម្នាក់ទៀតអាចមានអារម្មណ៍សោកសៅខ្លាំងតាមរយៈបទពិសោធរបស់បុគ្គល។

**ខ) ការឆ្លើយតបខាងសរីរវិទ្យា** (Physiological Responses)

- យើងទាំងអស់គ្នាដឹងពី អារម្មណ៍ដែលបេះដូងរបស់យើងលោតញាប់ដោយសារការភ័យខ្លាច។ ការឆ្លើយតបខាងសរីរវិទ្យានេះ គឺជាលទ្ធផលនៃប្រតិកម្មប្រព័ន្ធសរសៃប្រសាទចំពោះអារម្មណ៍ដែលយើងកំពុងជួបប្រទះ។ យោងតាមអ្នកចិត្តសាស្ត្រជាច្រើន ការឆ្លើយតបខាងសរីរវិទ្យារបស់យើងទំនងជារបៀបដែលបង្កើតឱ្យមានអារម្មណ៍បានជំរុញឱ្យមានភាពរីកចម្រើន និងរស់រានមានជីវិត។
- ម្យ៉ាងទៀតតាមកត្តាសរីរវិទ្យា បានបង្ហាញថាការឆ្លើយតបខាងសរីរវិទ្យាគឺមានឥទ្ធិពលខ្លាំងជាមួយបុគ្គលដែលមានភាពជិតស្និទ្ធបំផុត ដោយបុគ្គលអាចនឹងបង្ហាញអារម្មណ៍ដែលពួកគេ

កំពុងជួបប្រទះបង្ហាញឱ្យយើងដឹងតាមរយៈការបញ្ចេញទឹកមុខដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបអារម្មណ៍តាមរូបរាងកាយរបស់យើង។

ឧទាហរណ៍៖ ព្រឺសម្បុរ បេះដូងលោតញាប់ មុខប្រែពណ៌ក្រហម។

គ) **ការឆ្លើយតបអាកប្បកិរិយា** (Behavioral Responses)

- ទិដ្ឋភាពនៃការឆ្លើយតបតាមអាកប្បកិរិយា គឺជាការឆ្លើយតបផ្លូវអារម្មណ៍ដែលបង្ហាញចេញនូវអារម្មណ៍ពិត។ ការឆ្លើយតបពីអាកប្បកិរិយាអាចរួមបញ្ចូល ស្នាមញញឹម សើច ឬការដកដង្ហើមធំ រួមជាមួយនឹងប្រតិកម្មជាច្រើនទៀត អាស្រ័យលើបទដ្ឋានសង្គម និងបុគ្គលិកលក្ខណៈ។
- ខណៈពេលដែលការស្រាវជ្រាវជាច្រើនបានបង្ហាញថាការបញ្ចេញទឹកមុខជាច្រើនមានលក្ខណៈជាសកល ដូចជាការងក់ក្បាលដើម្បីបង្ហាញពីការយល់ស្រប (បទដ្ឋាននៃសង្គមវប្បធម៌) ការចិញ្ចឹមបីបាច់របស់បុគ្គលមានតួនាទីនៅក្នុងការឆ្លើយតបខាងអាកប្បកិរិយារបស់យើង។ ឧទាហរណ៍៖ របៀបបង្ហាញចេញនូវសេចក្តីស្រឡាញ់គឺខុសគ្នាពីមនុស្សម្នាក់ទៅមនុស្ស ម្នាក់ទៀត និងការខុសគ្នាពី វប្បធម៌ (ការសំពះ ការអោប ការថើប ការញញឹម)។

## ៤.៣.២ .ធាតុផ្សំនៃភាពវៃឆ្លាតខាងអារម្មណ៍រួមមាន៖

ការវាយតម្លៃ និងបង្ហាញពីអារម្មណ៍របស់ខ្លួន និងអ្នកដទៃអាចត្រូវបានកត់សម្គាល់តាមរយៈការទទួលស្គាល់ ឬបង្ហាញពីពាក្យសំដីពិត ឬមិនពិតចេញអំពីអារម្មណ៍ដែលខ្លួនកំពុងមាន។

ឧទាហរណ៍៖ បុគ្គលនិយាយប្រាប់អំពីអារម្មណ៍រីករាយរបស់ខ្លួននៅក្នុងស្ថានភាពមួយ។

រីឯការគ្រប់គ្រងអារម្មណ៍ខ្លួនឯង និងអ្នកដទៃអាចត្រូវបានកត់សម្គាល់តាមរយៈការគ្រប់គ្រងអារម្មណ៍ដើម្បីឱ្យអ្នកនៅជុំវិញទាំងអស់មានភាពរីករាយ ឬការលើកទឹកចិត្តដើម្បីឆ្ពោះទៅរកលទ្ធផលជាវិជ្ជមាន។

ឧទាហរណ៍៖ បុគ្គលគ្រប់គ្រងអារម្មណ៍ខឹង ឬចិត្តរំភើបដោយមិនបញ្ចេញវាមកក្រៅ មិនឱ្យប៉ះពាល់ដល់អ្នកដទៃ។

ចំពោះការប្រើប្រាស់អារម្មណ៍ដើម្បីសម្របខ្លួនអាចជាវិធីមួយ ដែលគេអាចកត់សម្គាល់តាមរយៈការប្រើប្រាស់អារម្មណ៍ និងការបកស្រាយពីអារម្មណ៍ ដើម្បីផ្តល់លទ្ធផលវិជ្ជមាន។

ឧទាហរណ៍៖ បុគ្គលរឭកខ្លួនឯងជារឿយៗ កុំឱ្យខ្លួនព្រងើយកន្តើយចំពោះការបំពេញភារកិច្ចប្រចាំថ្ងៃរបស់ខ្លួន។

## ៤.៣.៣ ដំណើរការនៃចិត្តរំភើប (The Process of Emotion)

សមាសភាពទាំង៦នៃដំណើររបស់ចិត្តរំភើបគឺ៖

ក) ស្វែងយល់ពីស្ថានភាព និង ការទំនាក់ទំនង(ការទទួលអារម្មណ៍ ការភ្ញោច)

ឧទាហរណ៍៖ ដឹងថាមានគេនិយាយមិនល្អពីខ្នៅដៃរបស់ខ្លួន។

ខ) ការដឹងសភាពចិត្ត ឬអារម្មណ៍របស់ខ្លួន

ឧទាហរណ៍៖ ដឹងថាខ្លួនមានអារម្មណ៍ខឹង។

គ) មានទំនោរទៅលើការគិត និងការធ្វើសកម្មភាព

ឧទាហរណ៍៖ បុគ្គលចាប់ផ្តើមឈ្លោះប្រកែកគ្នា។

ឃ) ការបម្រែបម្រួលលើរូបរាងកាយ

ឧទាហរណ៍៖ ក្តៅមុខឡើងពណ៌ក្រហម ក្តៅស្លឹកត្រចៀក បេះដូងលោតញាប់។

ង) ការបញ្ចេញទឹកមុខ

ឧទាហរណ៍៖ ទឹកមុខស្រពោន មិនសប្បាយចិត្ត អន់ចិត្ត។

ច) ការឆ្លើយតបចិត្តរំភើប

ឧទាហរណ៍៖ ការទប់កំហឹងដោយការដើរចេញ។

### ៤.៣.៤. ការអភិវឌ្ឍចិត្តរំភើបរបស់ទារក ឬកុមារ (The Emotional Development in Childhood)

ការអភិវឌ្ឍចិត្តរំភើបរបស់កុមារ អាចមានកត្តាជាច្រើនចូលរួមដូចជា បរិស្ថានដែលត្រូវបានគេមើលឃើញថាជាដំណើរការដែលពាក់ព័ន្ធ នឹងសមាសធាតុដែលទាក់ទងនឹងចិត្តរំភើបរបស់កុមារ។

ឧទាហរណ៍៖ អាកប្បកិរិយាការលេង ការញ៉ាំ សកម្មភាព ឬចលនារាងកាយ។ កុមារតូចមានការឆ្លើយតបចិត្តរំភើបទៅនឹងការផ្លាស់ប្តូរអន្តរកម្ម នៅក្នុងបរិស្ថានរស់នៅរបស់ពួកគេ។ ការអភិវឌ្ឍចិត្តរំភើបរបស់ទារក ឬកុមារឆ្លុះបញ្ចាំងពីបទពិសោធសង្គម រួមទាំងបរិបទវប្បធម៌ផងដែរ ហើយត្រូវបានគេបែងចែកចេញជា៣ដំណាក់កាល៖

**ការអភិវឌ្ឍចិត្តរំភើប៖**

- ក្រោយពីចាប់កំណើតកំឡុង៣ខែ៖ មានលេចចេញជាភាពរីករាយ កើតទុក្ខ ស្អប់។
- កំឡុងពេល៤ទៅ៦ខែ៖ មានលេចចេញជាកំហឹង ការភ័យខ្លាច ។
- កំឡុងពេល៣ឆ្នាំ៖ មានលេចចេញជាអំនួត ភាពអៀនខ្មាស កំហុស (ការបន្ទោសខ្លួនឯង)។

### ៤.៣.៥.តើសីលធម៌ជាអ្វី?

**ក) សីលធម៌ (Morality)៖**

ជាទ្រង់ទ្រាយមួយនៃមនសិការសង្គម ដែលបង្ហាញឱ្យឃើញពីឥរិយាបថ ការវាយតម្លៃទំនាក់ទំនងរវាងផលប្រយោជន៍ខ្លួនឯងជាមួយផលប្រយោជន៍របស់អ្នកដទៃ និងសង្គម។

ម្យ៉ាងទៀតសីលធម៌គឺជាស្តង់ដានៃសង្គមដែលប្រើប្រាស់ដើម្បីសម្រេចថាអ្វីដែលត្រឹមត្រូវ ឬមិនត្រឹមត្រូវ។

ឧទាហរណ៍៖

- សីលធម៌ផ្ទាល់ខ្លួន (ការទទួលខុសត្រូវនូវទង្វើរបស់ខ្លួន ការគោរពឪពុកម្តាយ)
- សីលធម៌ក្នុងគ្រួសារ (ស្តាប់ដំបូន្មានឪពុកម្តាយ ស្រឡាញ់បងប្អូន ស្រឡាញ់កូនស្មើៗគ្នា)
- សីលធម៌ក្នុងការងារ (មនសិការចំពោះការងារ មានសមត្ថភាពបំពេញការងារ មិនបំពានអ្នកដទៃ)
- សីលធម៌ក្នុងសង្គម (គោរព ប្រពៃណី ទំនៀមទម្លាប់ ច្បាប់រដ្ឋ ស្រឡាញ់យុត្តិធម៌)

តាមរយៈលោក Piaget បានលើកឡើងថា ការវាយតម្លៃសីលធម៌របស់កុមារ (Moral Judgment) គឺជាការយល់ដឹងរបស់កុមារអំពីក្បួនច្បាប់សីលធម៌ដែលមាននៅក្នុងសង្គម។

**ខ) ទំនាស់សីលធម៌ (Moral Dilemma)**

| |
|---|
| ករណីសិក្សា៖ បុរសម្នាក់មានប្រពន្ធឈឺ ដែលគាត់ត្រូវការថ្នាំពេទ្យព្យាបាល។ គាត់មិនមានលទ្ធភាពទិញថ្នាំ គាត់បានសុំអង្វរ អ្នកលក់ថ្នាំ លក់ឲ្យគាត់នូវតម្លៃថោក។ ពេលដែលអ្នកលក់ថ្នាំមិនព្រម ធ្វើតាមការសុំរបស់គាត់ បុរសនោះក៏សម្រេចចិត្តលួចថ្នាំ។ |




*រូបភាព 10៖ ទំនាស់សីលធម៌ (Moral Dilemma)*

តាមរយៈករណីសិក្សានេះ ធ្វើឲ្យមានការពិភាក្សាអំពីទង្វើរបស់មនុស្ស ឬទំនាស់ជាមួយសីលធម៌ (វាជាទំនាស់រវាងការសម្រេចចិត្តថាអ្វីត្រូវឬខុសនៅក្នុងស្ថានភាពជាក់លាក់មួយ តើសកម្មភាពនោះវានឹងផ្តល់ផលល្អ ឬក៏អាក្រក់)។

តាមរយៈទ្រឹស្តីរបស់ចិត្តវិទូអាមេរិកាំង លោក Lawrence Kohlberg អះអាងថា ការអភិវឌ្ឍនៃការផ្តល់ហេតុផលផ្នែកសីលធម៌របស់យើងកើតឡើងជាប្រាំមួយដំណាក់កាល។ ដំណាក់កាលទាំងនោះត្រូវបានរៀបចំជាបីកម្រិតគឺ៖ សីលធម៌សាមញ្ញ(Pre-Conventional) សីលធម៌ធម្មតា(Conventional) និង សីលធម៌ខ្ពស់បំផុត(Post-Conventional)។

- **ដំណាក់កាលទាំង៦៖** ដើម្បីងាយស្រួលយល់អំពីអត្ថន័យនៅក្នុងដំណាក់កាលនីមួយៗ យើងអាចពិនិត្យមើលរូបភាពដែលបង្ហាញពីជម្លោះរបស់សិស្សនៅក្នុងសាលារៀន។




*រូបភាព 11៖ជម្លោះរបស់សិស្សនៅក្នុងសាលារៀន*

មានការវាយតប់គ្នានៅក្នុងទីធ្លាសាលា។សិស្សថ្នាក់ទី៩ពីរនាក់កំពុងវាយTom។ អ្នកដែលមើលការវាយគ្នានោះ គឺស្ថិតក្នុងដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍសីលធម៌។

ឥលូវសូមពិនិត្យមើល! តើអ្វីដែលពួកគេកំពុងធ្វើ និងរបៀបដែលពួកគេបង្ហាញពីភាពត្រឹមត្រូវនៃអាកប្បកិរិយារបស់ពួកគាត់។

- **ដំណាក់កាលទី១៖ ការស្តាប់បង្គាប់ និង ការដាក់ទណ្ឌកម្ម** (Obedience and Punishment)




*រូបភាព 12៖ Fin (ការស្តាប់បង្គាប់ និងការដាក់ទណ្ឌកម្ម)*

នៅដំណាក់កាលទី១នេះ ផ្តោតលើការវិនិច្ឆ័យខាងសីលធម៌ដោយផ្អែកលើការស្តាប់បង្គាប់ និងការដាក់ទណ្ឌកម្ម។ **Finn ដឹងថាល្អ ឬអាក្រក់ វាអាស្រ័យថា តើគាត់ត្រូវទទួលទណ្ឌកម្មឬអត់?** ។ Finn មើលឃើញអ្វីដែលកំពុងកើតមានឡើងចំពោះមិត្តរបស់គាត់ ហើយគាត់ចង់ជួយ។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនដឹងថា តើគ្រូអាចដាក់ទណ្ឌកម្មគាត់ដែរឬទេ? ប្រសិនបើគាត់ត្រូវគេវាយឱ្យរបួស។ គាត់សួរខ្លួនឯងថា តើខ្ញុំអាចគេចពីការដាក់ទណ្ឌកម្មនេះដោយរបៀបណា?

- **ដំណាក់កាលទី២៖ ប្រយោជន៍ខ្លួនឯង** (Self-Interest)




*រូបភាព 13៖ Fin (ការស្តាប់បង្គាប់ និងការដាក់ទណ្ឌកម្ម)*

នៅដំណាក់កាលទី២នេះ ផ្តោតលើការជំរុញដោយមានភាពយកចិត្តទុកដាក់។ម៉ារីសម្រេចចិត្តធ្វើអន្តរាគមន៍ ហើយនាងគិតថា នឹងជួយ Tom ។ នាងដឹងថានាងអាចនឹងត្រូវទទួលទណ្ឌកម្ម ប៉ុន្តែនាងក៏ដឹងថានាងអាចក្លាយជាជនរងគ្រោះដោយខ្លួនឯងនៅថ្ងៃណាមួយ។ ប្រសិនបើនាងជួយ Tom ឥលូវនេះ គាត់ប្រហែលជាជួយនាងនៅថ្ងៃអនាគត។ នាងសួរខ្លួនឯងថា តើមានប្រយោជន៍អ្វីខ្លះដល់ខ្ញុំ?

- **ដំណាក់កាលទី៣៖ ភាពស្របគ្នារវាងបុគ្គល និងការអនុលោមតាមគ្នា**

( Interpersonal Accord and Conformity )




*រូបភាព 14៖ Betty( ភាពស្របគ្នារវាងបុគ្គលនិងការអនុលោមតាមគ្នា )*

នៅដំណាក់កាលទី៣នេះ ផ្តោតលើភាពស្របគ្នារវាងបុគ្គល និងការអនុលោមតាមគ្នាបានបង្ហាញការវិនិច្ឆ័យខាងសីលធម៌ចំពោះអ្នកដែលនៅជុំវិញខ្លួន។ Betty ឃើញការវាយតប់គ្នាក៏ចង់ធ្វើអន្តរាគមន៍ ប៉ុន្តែនាងដឹងថា អ្នកដទៃគ្រាន់តែឈរមើល នាងក៏សម្រេចចិត្តមិនចូលទៅជួយដែរ។ នាងចង់ឲ្យអ្នកដទៃមើលឃើញថា នាងជាមនុស្សស្រីល្អ ដែលត្រូវតាមក្រុមសីលធម៌របស់សហគមន៍ ( ដូចអ្នកនៅជុំវិញខ្លួននាង )។ នាងសួរខ្លួនឯងថា តើអ្នកដទៃគិតយ៉ាងណាចំពោះខ្ញុំ ?។

- **ដំណាក់កាលទី៤៖ ច្បាប់ និងការរក្សាសណ្តាប់សង្គម**

( Authority and Maintaining Social Order )




*រូបភាព 15៖ច្បាប់និងការរក្សាសណ្តាប់សង្គម(Authority and Maintaining Social Order )*

នៅដំណាក់កាលទី៤នេះ ផ្តោតលើការឲ្យតម្លៃទៅលើច្បាប់ និងការរក្សាសណ្តាប់ធ្នាប់សង្គម។ ពេលគ្រូឃើញក្រុមសិស្សវាយគ្នា គាត់ក៏ដើរចូលភ្លាម ហើយស្រែកថា៖ «ហាមវាយគ្នា នៅក្នុងសាលា!» លោកគ្រូយល់ថា សំខាន់ ត្រូវតែអនុវត្តតាមច្បាប់ បើមិនដូច្នេះទេ ភាពវឹកវរនឹងកើតឡើង ហើយវាជាកាតព្វកិច្ចរបស់គាត់ក្នុងការថែរក្សាច្បាប់ និងសណ្តាប់ធ្នាប់សង្គម។ គ្រូសួរខ្លួនឯងថាៈ តើខ្ញុំអាចរក្សាច្បាប់ និងសណ្តាប់ធ្នាប់សង្គមដោយរបៀបណា ?

- **ដំណាក់កាលទី៥៖ កិច្ចព្រមព្រៀងក្នុងសង្គម** ( Social Contract )




*រូបភាព 16៖ Jess( កិច្ចព្រមព្រៀងក្នុងសង្គម )Social Contract*

នៅដំណាក់កាលទី៥នេះ ផ្តោតលើការយល់ពីច្បាប់ដែលជាកិច្ចព្រមព្រៀងនៅក្នុងសង្គម ផ្ទុយពីការបញ្ញាយ៉ាងតឹងរ៉ឹង។ Jessy នាងបានមើលការវាយគ្នាពីចំងាយ មិនប្រាកដថានាងមានអារម្មណ៍យ៉ាងណាចំពោះរឿងនេះទេ។ សម្រាប់នាង ច្បាប់មានន័យ លុះត្រាតែពួកគេបម្រើឱ្យគោលបំណងដែលត្រឹមត្រូវ។ ជាក់ស្តែង ច្បាប់របស់សាលាហាមឃាត់ការវាយតប់គ្នា ប៉ុន្តែប្រហែលជា Tom សមនឹងគេវាយដោយសារកាលពីម្សិលមិញ គាត់បានដាល់ក្មេងស្រីរៀនថ្នាក់ទី១។ នាងសួរខ្លួនឯងថា តើច្បាប់ពិតជាបម្រើបុគ្គលទាំងអស់ក្នុងសហគមន៍ដែរឬ?

- **ដំណាក់កាលទី៦៖ គោលការណ៍សីលធម៌សកល** (Universal Ethical Principles)




*រូបភាព 17៖(គោលការណ៍សីលធម៌សកល )Universal Ethical Principles*

នៅដំណាក់កាលទី៦ ត្រូវបានផ្តោតលើណែនាំគោលការណ៍សីលធម៌ជាសកល។ អ្នកពាក់ព័ន្ធទាំងអស់ឥឡូវត្រូវប្រឈមមុខនឹងនាយកសាលា។ ដំបូងគាត់ពន្យល់ពីច្បាប់របស់សាលា និងមូលហេតុដែលពួកគេមានច្បាប់ទាំងនោះ។ លោកបញ្ជាក់ថា ច្បាប់មានសុពលភាពលុះត្រាតែវាផ្តល់យុត្តិធម៌សម្រាប់អ្នកទាំងអស់គ្នា។ គោលការណ៍សីលធម៌ខ្ពស់បំផុតរបស់នាយកសាលាគឺ ភាពមេត្តា ករុណា និងភាពសណ្តោសប្រណី។ គាត់ជឿថា មនុស្សទាំងអស់គួរតែរៀនយល់ពីទស្សនៈរបស់គ្នាទៅវិញទៅមក នោះពួកគេមិនមានអារម្មណ៍ឯកោចំពោះខ្លួនឡើយ។ គាត់សួរថាៈ តើអ្វីជាគោលការណ៍សីលធម៌អរូបី ដែលបម្រើដល់ការយល់ដឹងរបស់ខ្ញុំអំពីយុត្តិធម៌?

❖ កម្រិតទាំង៣របស់សីលធម៌៖

➢ **កម្រិតទី១៖ សីលធម៌សាមញ្ញ** (Pre Conventional Morality)




*រូបភាព 18៖ Fin and Maryសីលធម៌សាមញ្ញ (Pre Conventional Morality)*

នៅកម្រិតទី១នេះ មានលក្ខណៈសាមញ្ញ ដោយ កុមារា Finn ត្រូវបាននាំមុខដោយភាពភ័យខ្លាច និង កុមារី Mary ដោយគិតអំពី ផលប្រយោជន៍ខ្លួនឯង។ អ្នកទាំងពីរ វិនិច្ឆ័យអ្វីដែលត្រូវឬខុស ដោយគិតពីលទ្ធផល ដែលពួកគេរំពឹងទុកសម្រាប់ខ្លួនគេ មិនមែនតាមបទដ្ឋានសង្គមទេ។ ទម្រង់នៃការវែកញែកនេះគឺជារឿងធម្មតាក្នុងចំណោមកុមារ។

➢ **កម្រិតទី២៖ សីលធម៌ធម្មតា** (Conventional Morality)




*រូបភាព 19៖ Betty and Teacherសីលធម៌ធម្មតា (Conventional Moral)*

នៅកម្រិតធម្មតានេះ Betty ឆ្លើយតបទៅនឹងសម្ពាធពីមិត្តភ័ក្តិ ហើយគ្រូធ្វើតាមច្បាប់។ សីលធម៌របស់ពួកគេផ្តោតលើអ្វីដែលសង្គមចាត់ទុកថាត្រឹមត្រូវ។ នៅកម្រិតនេះ ភាពយុត្តិធម៌នៃច្បាប់គឺកម្រត្រូវបានចោទសួរណាស់។ វាជារឿងធម្មតាទេក្នុងការគិតបែបនេះក្នុងវ័យជំទង់ និងពេញវ័យ។

- **កម្រិតទី៣៖ សីលធម៌កម្រិតខ្ពស់** ( Post Conventional Morality )




*រូបភាព 20៖ Jessy and នាយក សីលធម៌កម្រិតខ្ពស់ (Post Conventional*

នៅកម្រិតខ្ពស់នេះ Jessy ដឹងថាអ្វីៗមានភាពស្មុគស្មាញ ដោយសារបុគ្គលម្នាក់ៗអាចមិនគោរពច្បាប់ដែលមិនស្របនឹងសីលធម៌ផ្ទាល់ខ្លួនរបស់ពួកគេ។ ចំណែកឯនាយកសាលាធ្វើតាមគំនិតសីលធម៌សកល ដោយផ្ទុយគ្នានឹងអ្វីដែលសង្គមគិត ឬច្បាប់និយាយ។ ចំពោះនាយកសាលា អ្វីៗត្រូវបានដោះស្រាយដោយការអាណិតអាសូរ។ តាមគំនិតរបស់គាត់ អាកប្បកិរិយាឬទង្វើល្អ គឺវាមិនត្រូវបានគេបញ្ឈប់ទេ លុះត្រាតែវាបញ្ចប់ដោយខ្លួនឯង ហើយមិនមែនមនុស្សគ្រប់រូបសុទ្ធតែអាចឈានដល់កម្រិតខ្ពស់ទាំងអស់នោះទេ។

## ៤.៤ សន្និដ្ឋាន

ការសិក្សាអំពីការអភិវឌ្ឍចិត្តរំភើប និងសីលធម៌តាមរយៈបញ្ញត្តិដែលបានកំណត់នូវការអភិវឌ្ឍ

ចិត្តរំភើប និងអារម្មណ៍កើតឡើងជាលំនាំមួយតាំងពីកុមារភាព។ ការអភិវឌ្ឍចិត្តរំភើប និងសីលធម៌តាមរយៈទ្រឹស្តីរបស់ចិត្តវិទូអាចឱ្យយើងធ្វើការឆ្លុះបញ្ចាំងទៅលើការឆ្លើយតបផ្លូវអារម្មណ៍របស់បុគ្គល

ម្នាក់ៗ។ជាពិសេស តាមរយៈទ្រឹស្តីរបស់ Kohlberg ដែលមានឥទ្ធិពលទៅលើការរីកចម្រើនផ្នែក

សីលធម៌សង្គម ជាពិសេសខ្លឹមសារដែលផ្តោតលើការអភិវឌ្ឍសីលធម៌ទាំង៦ដំណាក់កាល និង៣កម្រិត ដែលត្រូវបានបង្ហាញនៅក្នុងមេរៀននេះ អាចជាទ្រឹស្តីសង្គម ឬបទពិសោធន៍ដ៏ល្អ ចេញពីករណីសិក្សា ដែលបង្ហាញនូវទំនាក់ទំនងរវាងបុគ្គល សហគមន៍ និងច្បាប់សង្គម ដែលជុះពន្លកចេញពីការយល់ដឹង តាំងពីកុមារភាព(កម្រិតសាមញ្ញ ទៅកម្រិតជម្មតា ហើយឈានដល់កម្រិតខ្ពស់បំផុត ដែលបុគ្គលគ្រប់រូបគួរចែករំលែកនូវក្តីស្រឡាញ់ សេចក្តីអាណិតអាសូរ រវាងគ្នានឹងគ្នា ដែលនឹងត្រូវឈានដល់កម្រិតចុងក្រោយនេះ)។

## សំណួរត្រិះរិះ

១. នៅក្នុងដំណាក់កាលទី១ តើខ្ញុំអាចគេចពីការដាក់ទណ្ឌកម្មដោយរបៀបណា?

២. នៅក្នុងដំណាក់កាលទី២ តើមានប្រយោជន៍អ្វីខ្លះដល់ខ្ញុំ?

៣. នៅក្នុងដំណាក់កាលទី៣ តើអ្នកដទៃគិតយ៉ាងណាចំពោះខ្ញុំ?

៤. នៅក្នុងដំណាក់កាលទី៤ តើខ្ញុំអាចរក្សាច្បាប់ និងសណ្តាប់ធ្នាប់សង្គមដោយរបៀបណា?

៥. នៅក្នុងដំណាក់កាលទី៥ តើច្បាប់ពិតជាបម្រើបុគ្គលទាំងអស់ក្នុងសហគមន៍ដែរឬ?

៦. នៅក្នុងដំណាក់កាលទី៦ តើអ្វីជាគោលការណ៍សីលធម៌អរូបី ដែលបម្រើដល់ការយល់ដឹងរបស់ខ្ញុំ អំពីយុត្តិធម៌?

៧. តើអ្នកនឹងអនុវត្តទ្រឹស្តីអភិវឌ្ឍសង្គម ចិត្តវិភើបនិងសីលធម៌នៅក្នុងបរិបទអប់រំបានយ៉ាងដូចម្តេច?

# មេរៀនទី៥ ការអភិវឌ្ឍប្រត្យក្សារម្មណ៍

( Development of Perception )

## ៥.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹង៖

- ប្រាប់បានអំពីបញ្ញត្តិ ការអភិវឌ្ឍប្រត្យក្សារម្មណ៍របស់កុមារ
- កំណត់បានពីរបៀបនៅក្នុងការមើលពណ៌ និងលាយពណ៌
- មានស្មារតីគ្រប់គ្រងចំណាំងកន្តុប្រឡំឱ្យមានភាពត្រឹមត្រូវ ។

## ៥.២ សេចក្តីផ្តើម

មេរៀននេះផ្តោតលើការអភិវឌ្ឍប្រត្យក្សារម្មណ៍ ដោយរាប់បញ្ចូលទាំងយន្តការប្រត្យក្សារម្មណ៍។ ឧទាហរណ៍៖ សមត្ថភាពនៃការកំណត់ពណ៌ ឬ រូបភាពនៃវត្ថុ។ តាមរយៈដំណើរការនៃប្រត្យក្សារម្មណ៍ ការទទួលរំញោចអារម្មណ៍របស់បុគ្គលត្រូវបានប្រែក្លាយទៅជាបទពិសោធ ដូច្នេះយើងអាចទាញនូវការយល់ឃើញថា ដំណើរការនេះជំរុញឱ្យបុគ្គលមានការអភិវឌ្ឍខ្លួន និងអាចទាញចេញនូវសេចក្តីសន្និដ្ឋានពីដំណើរការនៃប្រត្យក្សារម្មណ៍នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ រួមនិងទំនាក់ទំនងដែលបាន រកឃើញរវាងប្រភេទផ្សេងៗនៃការភ្លោច ដែលផ្សំពី រលកពន្លឺ និងរលកសំឡេង។

## ៥.៣ ខ្លឹមសារ

### ៥.៣.១ បញ្ញត្តិ

**សំណួរទី១៖** តើរូបភាពបំភាន់ជាអ្វី?

**រូបភាពបំភាន់៖** គឺកើតឡើងដោយការមើលឃើញ និងកំណត់លក្ខណៈដែលមើលទៅហាក់ដូចជាខុសពីការពិត។



តើអ្នកមើលឃើញអ្វីចេញពីរូបគំនូរនេះ?

*រូបភាព 21៖រូបភាពបំភាន់*

**សំណួរទី២ ៖** តើរូបភាពក្រឡាអុក A និង រូបភាពក្រឡាអុក B តើមួយណាភ្លឺជាង ?



រូបភាពបំភាន់ដោយក្តារអុក ( Adelson Checkerboard )

*រូបភាព 22៖ក្រឡាអុក A and B មួយណាភ្លឺជាង*

តាមរយៈលោកសាស្ត្រាចារ្យ Edward H. Adelson ផ្នែកវិទ្យាសាស្ត្រដែលផ្តោតលើចក្ខុ និងពន្លឺ បានធ្វើការពិសោធដោយប្រើក្តារអុកដែលមានជ្រុងពណ៌ស្រាល និងងងឹត ដែលផ្នែកខ្លះមានស្រមោលដោយវត្ថុផ្សេង ទៀត។ ការបំភាន់អុបទិកគឺថា ផ្ទៃដែលមានក្រឡា A ហាក់ដូចជាពណ៌ងងឹតជាងតំបន់ដែលមានក្រឡា B។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទនៃរូបភាពពីរវិមាត្រ ពួកវាមានពន្លឺដូចគ្នាពេលគឺវានឹងត្រូវបានគេបោះពុម្ពជាមួយនឹងល្បាយដូចគ្នានៃទឹកថ្នាំ ហើយការបង្ហាញនៅលើអេក្រង់លមានភីកសែលនៃពណ៌ដូចគ្នាបេះបិទ។



រូបភាពក្រឡា A និង រូបភាពក្រឡា B មានពន្លឺស្មើគ្នា !

*រូបភាព 23៖ក្រឡាអុកA និងក្រឡាអុកB មានពន្លឺស្មើគ្នា*

មុននឹងសិក្សាស្វែងយល់អំពីប្រត្យក្សារម្មណ៍។ យើងគួរតែញែកឱ្យដាច់ពីគ្នារវាងឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ ដើម្បីឱ្យការសិក្សារបស់យើងមានភាពច្បាស់លាស់។ ប៉ុន្តែតាមពិត លំនាំទាំង២ នេះផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ។ កាលណាគេទទួលឥន្ទ្រីយារម្មណ៍ ភ្លាមនោះគេក៏ទទួលបានប្រត្យក្សារម្មណ៍ផងដែរ។

- ឥន្ទ្រីយារម្មណ៍ (Sensation) ៖ គឺជាលំនាំចិត្តសាមញ្ញបំផុត ដែលឆ្លុះបញ្ចាំងលក្ខណៈតែម្យ៉ាង ឬទោលនៃវត្ថុ ឬបាតុភូតទាំងឡាយ ដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍។

ឧទាហរណ៍៖ មើលក្ដារខៀន ឃើញពណ៌ស។ មើលផ្កាកូឡាប ឃើញពណ៌ក្រហម។

- ប្រត្យក្សារម្មណ៍ (Perception) ៖ គឺជាលំនាំចិត្តដែលឆ្លុះបញ្ចាំងលក្ខណៈទាំងស្រុងនៃវត្ថុ ឬបាតុភូត ដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍។

ឧទាហរណ៍៖ មើលនាឡិកាព្យួរជញ្ជាំង ខ្ញុំឃើញទម្រង់នាឡិការនោះ (ជ្រុង) លឺសំលេងទឹកតុក ខ្ញុំស្មាបផ្ទៃកញ្ចក់វាររលោង។

## ៥.៣.២ តើប្រត្យក្សារម្មណ៍បង្កើតឡើងដើម្បីអ្វី?

មនុស្សត្រូវការរបៀបរស់នៅសមស្របជាមួយនិងបរិស្ថានជុំវិញខ្លួន ដូចនេះបុគ្គលម្នាក់ៗប្រើប្រាស់នូវប្រត្យក្សារម្មណ៍ ដើម្បីជាមូលដ្ឋាននៃការយល់ឃើញ ការបំពេញការងារប្រចាំថ្ងៃ និងការសម្រេចចិត្ត។ ដើម្បីបង្កើត និងរក្សានូវរបៀបរស់នៅដ៏សមរម្យ មនុស្សត្រូវការ ទាញចេញនូវព័ត៌មានដែលបានមកពីឥន្ទ្រីយារម្មណ៍ផងដែរ។

## ៥.៣.៣ មុខងារនៃប្រត្យក្សារម្មណ៍

ប្រត្យក្សារម្មណ៍ក៏មានភាពស្មុគស្មាញខ្លះដែរនៅក្នុងការធ្វើចំណាត់ថ្នាក់នៃព័ត៌មានដែលទទួលបានដើម្បដោះ ស្រាយ ជាមួយនឹងស្ថានភាពលំបាកនេះ គេចែកប្រព័ន្ធប្រត្យក្សារម្មណ៍ជា៥ផ្នែក។

ទី១៖ បំរុងប្រយ័ត្នទៅលើផ្នែកឥន្ទ្រីយ៍ដែលទទួលព័ត៌មានពីមជ្ឈដ្ឋានជុំវិញ

ទី២៖ ការកំណត់ទីតាំងនៃវត្ថុ ឬបាតុភូត

ទី៣៖ ការកត់សម្គាល់វត្ថុ ឬបាតុភូត

ទី៤៖ ការសង្ខេបព័ត៌មានសំខាន់ៗចេញពីវត្ថុ ឬបាតុភូត

ទី៥៖ ការរក្សាទុកឱ្យបានខ្ជាប់ខ្ជួន នូវទ្រង់ទ្រាយ ស្ថានភាពនៃវត្ថុ ឬបាតុភូត ទោះបី រ៉េទីនរូបភាពផ្លាស់ប្ដូរក៏ដោយ។

## ៥.៣.៤ ការរៀនមើលពណ៌

### ក) ការមើលពណ៌

ប្រពន្ធ័គំហើញរបស់មនុស្សយើងផ្សំដោយរលកប្រវែង (wavelengths) ឬកាំពន្លឺ ដែលវាបំលែងឲ្យទៅជាពណ៌។ មានពណ៌គោលចំនួន៣គឺ៖ ពណ៌ខៀវ ពណ៌បៃតង និងពណ៌ក្រហម រីឯភ្នែករបស់យើង ទទួលបានពន្លឺពណ៌ក្រហម ពណ៌បៃតង និងខៀវ ជាពណ៌គោលដែលអាចទទួលអារម្មណ៍ដឹងពណ៌ទាំងអស់បាន។

- រលកប្រវែងរយៈខ្លី (450 -500 nanometers)៖ វាចេញជាពណ៌ខៀវ
- រលកប្រវែងរយៈមធ្យម (500-570 nanometers)៖ វាចេញជាពណ៌បៃតង
- រលកប្រវែងរយៈវែង (650-780 nanometers)៖ វាចេញជាពណ៌ក្រហម

### ខ) ការលាយពណ៌

យើងមានមធ្យោបាយ២ប្រភេទក្នុងការលាយពណ៌គឺ៖

➢ ការលាយបន្ថែមពណ៌៖ (Additive color mixture)

គឺជាការលាយពណ៌ដែលធ្វើឲ្យពណ៌កាន់តែស្រាល ឬស (Additive mixing makes things whiter)




*រូបភាព 24៖ការលាយបន្ថែមពណ៌ឱ្យកាន់តែស្រាល ក្រហម បៃតង ខៀវ*

*(Additive color mixture)*

**លំហាត់អនុវត្ត៖**

ក. ពណ៌គោល បង្កើតការលាយពណ៌ដែលធ្វើឲ្យពណ៌កាន់តែស្រាល ឬស

| | | |
|---|---|---|
| ក្រហម + ខៀវ = | ក្រហម + បៃតង+លឿង = | ខៀវ + បៃតង = |
| ក្រហម + បៃតង = | | |

➢ ការលាយបន្ថយពណ៌៖ (Subtractive mixture)

គឺជាការលាយពណ៌ដែលធ្វើឲ្យពណ៌កាន់តែងងឹត ចាស់ឬខ្មៅ (Subtractive mixing makes things black)




*រូបភាព 25៖ការលាយបន្ថយពណ៌ឱ្យពណ៌កាន់តែដិត ចាស់ឬខ្មៅ Cyan Magenta Yellow( Subtractive mixture )*

**លំហាត់អនុវត្ត៖**

ខ. ពណ៌គោល បង្កើតការលាយពណ៌ដែលធ្វើឲ្យពណ៌កាន់តែដុត/ចាស់ឬខ្មៅ

| | | |
|---|---|---|
| ផ្ទៃមេឃ + លឿង = | ផ្ទៃមេឃ+ស្វាយ + លឿង = | ស្វាយ +ផ្ទៃមេឃ = |
| ស្វាយ + លឿង = | | |

**គ ) ច្បាប់ស្ថេរភាពនៃប្រត្យក្សារម្មណ៍ ទៅលើស្ថេរភាពនៃពណ៌ (color constancy)**

តើអ្វីជាច្បាប់ស្ថេរភាពពណ៌ ?

ច្បាប់ស្ថេរភាពនៃពណ៌គឺជាសមត្ថភាពក្នុងការស្គាល់ឬមើលឃើញវត្ថុដោយឥតប្រែប្រួលទោះលក្ខខណ្ឌនៃប្រត្យក្សារម្មណ៍ត្រូវបានផ្លាស់ប្តូរក៏ដោយ។វត្ថុតែមួយមើលក្នុងលក្ខខណ្ឌចំងាយខុសគ្នាក្រោមពន្លឺខុសគ្នា តែយើងនៅតែស្គាល់វត្ថុនោះច្បាស់ដដែល!!

ឧទាហរណ៍ទី១៖ អាវពណ៌ខៀវ នៅតែជាពណ៌ខៀវ ទោះមានថ្ងៃចាំង ឬខ្សោយពន្លឺ មកក៏ដោយ។

ឧទាហរណ៍ទី២៖ កុមារនៅតែស្គាល់ម្តាយ ទោះជាម្តាយប្តូរសំលៀកបំពាក់បែបណាក៏ដោយ។

## ៥.៣. ៥ ប្រត្យក្សារម្មណ៍នៃការដឹងពីចម្ងាយ ឬ ញាណដឹងពីចម្ងាយ

( Monocular Cues )

តើអ្វីជាញាណដឹងពីចម្ងាយ ?

ញាណដឹងពីចម្ងាយជាចំណែកថ្នាក់មួយនៃប្រត្យក្សារម្មណ៍ ដែលទទួលព័ត៌មានអំពីជម្រៅដែលអាចត្រូវបានវិនិច្ឆ័យដោយប្រើភ្នែកតែម្ខាង។ សញ្ញាបង្ហាញអំពីជម្រៅ ឬចម្ងាយម៉ូណូគុលអាចត្រូវបានប្រើនៅក្នុងរូបភាព ដូច្នេះ សញ្ញាបង្ហាញជម្រៅ ឬចម្ងាយ ជាច្រើនត្រូវបានប្រើប្រាស់ក្នុងសិល្បៈ ដើម្បីផ្តល់ឱ្យអ្នកទស្សនានូវភាពស៊ីជម្រៅ។

ញាណដឹងពីចម្ងាយត្រូវបានគេបែងចែកជា៥សញ្ញាណគឺ៖

- ទី១៖ **ទំហំ** (**Relative size**)៖ របស់កាន់តែតូច នៅឆ្ងាយជាងរបស់កាន់តែធំ។ លើរូបយើង មើលឃើញថា បាល់ក្រោយតូច ដូចជានៅឆ្ងាយជាង បាល់នៅមុខធំ។



*រូបភាព 26៖ទំហំ (Relative size)*

- **ទី២៖ ទីតាំង** (**Interposition**)៖ បើវត្ថុដាក់បាំងនៅពីមុខវត្ថុ១ទៀត នោះវត្ថុដែលដាក់បាំង នោះ មើលទៅវាដូចជានៅជិតជាងគេ។



*រូបភាព 27៖ទីតាំង (Interposition)*

- ទី៣៖ កម្ពស់ (Relative height) ៖បើវត្ថុ ឬសត្វកាន់តែនៅជិតបន្ទាត់ដេក នោះវត្ថុ ឬសត្វ កាន់តែតូច ហើយមើលទៅវានឹងខ្ពស់ជាងវត្ថុ ឬសត្វដែលនៅជិតបំផុត។



*រូបភាព 28៖៖កម្ពស់ (Relative height)*

- **ទី៤៖ ការមើលចម្ងាយ(Perspective)**៖ បើវត្ថុជាខ្សែឬ បន្ទាត់ស្របគ្នា ពេញលើផ្ទៃ នោះខ្សែ ឬបន្ទាត់ស្រប ហាក់ដូចជាមើលមិនឃើញពេលវានៅឆ្ងាយ។



*រូបភាព 29៖ការមើលចម្ងាយ(Perspective)*

- **ទី៥ ស្រមោល និង ម្លប់(Shadow and Shading)**៖
  - ❑ ស្រមោល៖គឺជារូបភាពរូបព្រាងៗដែលប្រាកដតាមរូបដើម ដោយមានពន្លឺចាំងត្រូវ។
  - ❑ ម្លប់៖ គឺទីដែលមានស្រមោលបាំងកម្តៅព្រះអាទិត្យ។ ឧទាហរណ៍៖ ម្លប់ដើមឈើ ម្លប់ផ្ទះ ជ្រកម្លប់។




*រូបភាព 30៖ស្រមោល និង ម្លប់ )Shadow and Shading )*

## ៥.៤ សន្និដ្ឋាន

តាមរយៈការសិក្សាអំពីការអភិវឌ្ឍប្រត្យក្សារម្មណ៍ដោយយោងតាមបញ្ញត្តិការប្រើប្រាស់ និងមុខងាររបស់ប្រត្យក្សារម្មណ៍ ដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ រួមទាំងការយល់ដឹងនូវដំណើរការដែលបានប្រើប្រាស់ប្រត្យក្សារម្មណ៍ដើម្បីមើលឃើញនិងវិភាគនូវភាពភ្លោចទាំងអស់ដែលអ្នកជួបប្រទះរាល់វិនាទី ដោយចាប់រាប់ពីពន្លឺពណ៌ វត្ថុនានានៅក្នុងមជ្ឈដ្ឋានជុំវិញខ្លួន។ ប្រត្យក្សារម្មណ៍ក៏អាចចូលរួមចំណែកអាចឱ្យយើងធ្វើការសម្រេចចិត្តលើអ្វីៗគ្រប់យ៉ាងដោយផ្អែកលើអត្ថន័យនៃវត្ថុ ឬបាតុភូតដើម្បីតម្រង់ទៅរកគោលបំណងជាក់លាក់មួយដែលស្របតាមតថភាពបរានុម័ត។

## សំណួរត្រិះរិះ

១. តើការអភិវឌ្ឍប្រត្យក្សារម្មណ៍របស់កុមារ ផ្តោតសំខាន់ទៅលើចំណុចអ្វីខ្លះ ?

២. តើប្រត្យក្សារម្មណ៍នៃការមើលពណ៌មាន សារៈប្រយោជន៍ដូចម្តេចខ្លះ ?

៣. តើអ្នកគិតថាទារក ខ្លាចទីខ្ពស់ដែរឬទេ ?

៤. តើអ្នកគិតថាទារក ដឹងពីកម្ពស់ដែរឬទេ ?

៥. តើអ្នកនឹងអនុវត្តទ្រឹស្តីការអភិវឌ្ឍប្រត្យក្សារម្មណ៍នៅក្នុងបរិបទអប់រំបានយ៉ាងដូចម្តេច ?

# មេរៀនទី៦ ការអភិវឌ្ឍបុទ្ធិ

( Cognitive Development )

## ៦.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹងៈ

- ពន្យល់បានពីការអភិវឌ្ឍពុទ្ធិ ដោយផ្អែកទៅលើទ្រឹស្តីរបស់លោក Piaget
- ប្រើប្រាស់បំណិនអំពីរបៀបគិតរបស់កុមារចំពោះពិភពនៅជុំវិញខ្លួនរបស់ពួកគេ
- ផ្សារភ្ជាប់ទ្រឹស្តីអំពីរបៀបគិតរបស់កុមារទៅក្នុងថ្នាក់រៀន ឬជីវភាពរស់នៅប្រចាំថ្ងៃ ។

## ៦.២ សេចក្តីផ្តើម

មេរៀននេះផ្តោតលើការអភិវឌ្ឍពុទ្ធិដោយផ្អែកទៅលើទ្រឹស្តីរបស់លោក Jean Piaget ដែលជាចិត្តវិទូជនជាតិស្វីស បានបង្ហាញថាភាពវៃឆ្លាតរបស់កុមារឆ្លងកាត់ការផ្លាស់ប្តូរទៅតាមវ័យរបស់ពួកគេ កាលណាពួកគេចម្រើនវ័យធំឡើង។ ការអភិវឌ្ឍការយល់ដឹងរបស់កុមារគឺមិនត្រឹមតែទាក់ទងនឹងការទទួលបានចំណេះដឹងប៉ុណ្ណោះទេ កុមារត្រូវកសាង ឬអភិវឌ្ឍគម្រូផ្លូវចិត្តចេញពីអ្នកនៅជុំវិញខ្លួនរបស់ពួកគេផងដែរ។ ទ្រឹស្តីនៃការអភិវឌ្ឍពុទ្ធិត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះនៅក្នុងវិស័យនានា ដូចជា ចិត្តវិទ្យាពិសេសក្នុងវិស័យអប់រំដែលផ្តោតលើការអភិវឌ្ឍបញ្ញារបស់កុមារក្នុងថ្នាក់រៀន។

## ៦.៣ ខ្លឹមសារ

### ៦.៣.១ បញ្ញត្តិ ៖ ការអភិវឌ្ឍពុទ្ធិ(ការយល់ដឹង)

សំណួរទី១៖ តើការអភិវឌ្ឍពុទ្ធិជាអ្វី(ការយល់ដឹង)?

ការអភិវឌ្ឍពុទ្ធិគឺជាការវិនិច្ឆ័យ ប៉ាន់ប្រមាណ និងការគិតផ្សេងៗ។

ឧទាហរណ៍៖ គ្រូបង្ហាញ កែវជ័រពីរដែលមានទឹក រួចគ្រូសួរ តើមួយណាមានទឹកច្រើនជាង?

### ៦.៣.២ លក្ខណៈពិសេសនៃដំណាក់កាលអភិវឌ្ឍពុទ្ធិ តាមទ្រឹស្តីលោក Piaget

បន្ទាប់ពីបានសង្កេតមើលកុមារយ៉ាងជិតដល់ លោក Piaget បានបង្ហាញថា ការអភិវឌ្ឍពុទ្ធិរបស់កុមាររីកចម្រើនតាមរយៈ៤ដំណាក់កាលផ្សេងៗគ្នាតាំងពីកំណើតរហូតដល់ចុងបញ្ចប់វ័យជំទង់។ តាមរយៈ "ដំណាក់កាល" ទាំងនេះបង្កប់នូវអត្ថន័យជាគម្រូនៃការគិតរបស់កុមារ ដែលមាន លក្ខណៈពិសេស៤យ៉ាងគឺ៖

១. ដំណាក់កាលអភិវឌ្ឍពុទ្ធិរបស់កុមារ តែងតែកើតមានឡើងនៅគ្រប់វ័យដូចៗគ្នា។
២. គ្មានដំណាក់កាលអភិវឌ្ឍពុទ្ធិរបស់កុមារ ណាមួយត្រូវបានរំលងឡើយ។
៣. ដំណាក់កាលនីមួយៗគឺជាការប្រែប្រួលដ៏សំខាន់នៃពុទ្ធិដែលត្រូវឆ្លងកាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។
៤. ដំណាក់កាលដំបូងកើតមានចំពោះកុមារ ហើយដំណាក់កាលបន្តបន្ទាប់ទៀតក៏កើតមានទៅក្នុងខ្លួនកុមារផងដែរ។

### ៦.៣.៣ ដំណាក់កាលអភិវឌ្ឍពុទ្ធិទាំង៤

- **ដំណាក់កាលទី១៖ ចលនាអារម្មណ៍ទទួល (Sensorimotor) ចាប់ពីចាប់កំណើត ដល់កុមារអាយុ២ឆ្នាំ**

នៅក្នុងដំណាក់កាលនេះ ជាការកើតឡើងដំបូង ហើយត្រូវបានកំណត់ ថាជាអំឡុងពេលដែលទារក "គិត" ដោយប្រើអារម្មណ៍ និង សកម្មភាពចលនារបស់ពួកគេ។ ដូចដែលឪពុកម្តាយមានបទពិសោធន៍ ជាមួយទារកដូចជាអារម្មណ៍កក់ក្តៅ ដោយការប៉ះ ការមើល



*រូបភាព 31៖ដំណាក់កាលទី១ចលនាអារម្មណ៍ទទួល*

ការស្តាប់ និងសូម្បីតែការបំបៅដោះកូន។ យោងតាមលោក Piaget សកម្មភាពទាំងនេះអនុញ្ញាតឱ្យទារក ឬកុមាររៀនអំពីពិភពនៅជុំវិញខ្លួន និងមានសារៈសំខាន់ចំពោះការអភិវឌ្ឍន៍ពុទ្ធិដំបូងរបស់ពួកគេ។

ឧទាហរណ៍ទី១៖ ទារកអាយុប្រហែល10ខែចាប់ដឹង អំពីតុក្កតាលេងរបស់ពួកគេ ដោយដឹងថា ទោះជាតុក្កតានោះបាំងក្រោមកន្សែង ក៏គាត់អាចដឹងថាវាមិនបានបាត់ទៅណានោះទេ។
ឧទាហរណ៍ទី២៖ចាប់ពីពេលចាប់កំណើត ដល់អាយុប្រហែល ២ឆ្នាំ កុមារចាប់ផ្តើមដឹងថា ពេលខ្លួនគាត់គ្រវីជួង វានឹងបន្លឺសំឡេង។
ដំណាក់កាលនេះកុមារដឹងពីទំនាក់ទំនងរវាងសកម្មភាពរបស់ខ្លួន និងលទ្ធផល ឬវត្ថុនោះ (Object Permanence)។

- **ដំណាក់កាលទី២៖ បុរេប្រតិបត្តិការ (Preoperational)ចាប់ពី២ឆ្នាំ ដល់កុមារអាយុ៧ឆ្នាំ**

នៅក្នុងដំណាក់កាលបុរេប្រតិបត្តិការ កុមារប្រើប្រាស់សមត្ថភាពការគិតថ្មីៗរបស់ពួកគេដើម្បីបង្ហាញនូវរូបភាព ឬវត្ថុដែលជារូបតំណាងឱ្យសកម្មភាពជាច្រើនកុមារអាចប្រាប់អំពីអត្ថន័យរូបភាព ដូចជា(កំពុងទាត់បាល់ កំពុងជិះកង់) ប៉ុន្តែពួកគេមិនទាន់បានរៀបចំ ឬផ្តល់ភាពសមហេតុសមផលឱ្យបានពេញលេញនៅឡើយទេ។
កុមារចូលរួមក្នុងសកម្មភាពស្រមើស្រមៃ ២កម្រិតក្នុងពេលតែមួយ មានដូចជាការស្រមើស្រមៃ និងភាពប្រាកដនិយម។ តាមរយៈបទពិសោធន៍ដែលបង្ហាញពីដំណើរការ ២កម្រិតនេះ ដើរតួយ៉ាងសំខាន់នៅក្នុងការឆ្លុះបញ្ចាំង និងការត្រួតពិនិត្យការគិតដោយខ្លួនឯង។ វាជាដំណាក់កាលដែលឆ្ពោះទៅរកភាពជោគជ័យនៅក្នុងសាលារៀន ដែលផ្តោតលើការបង្រៀនកុមារតូចៗនៅតាម (មត្តេយ្យសិក្សា និងបឋមសិក្សា) និងតែងតែចំណាយពេលវេលា និងកន្លែងនៅក្នុងថ្នាក់របស់ពួកគេសម្រាប់ការលេង ការច្រៀង ការរាំដើម្បីជួយអភិវឌ្ឍនូវពុទ្ធិរបស់កុមារ ចំពោះការគិតរបស់កុមារក៏ចាប់ផ្តើមមានលក្ខណៈតាមបែបតក្ក(ភាពពិតជាក់ស្តែង)។
ឧទាហរណ៍ទី១៖ ដំបូងមានកែវខ្លីពីរ ដែលមានទឹកស្មើគ្នា រួចគេផ្ទេរទឹកក្នុងកែវខ្លី ទៅក្នុងកែវវែង កុមារដឹងថា បរិមាណទឹកមិនប្រែប្រួលទេ។
ឧទាហរណ៍ទី២៖ គេតម្រៀបកាក់ជិតគ្នា រួចហើយនៅជួរទី១ រៀបវាឱ្យមានចន្លោះវិញ កុមារអាចគិតថា ចំនួនកាក់ដែលឃ្លាតគ្នា អាចមានច្រើនជាង។

**ចំណាំ:** កុមារផ្តោតលើខ្លួនឯង ហើយពិបាកដឹង គិតពី សារ ឬពត៌មានតាមក្រសែភ្នែករបស់កុមារដទៃ។



*រូបភាព 32៖ដំណាក់កាលទី២ បុរេប្រតិបត្តិការ (Preoperational)*

- **ដំណាក់កាលទី៣៖ ប្រតិបត្តិការជាក់លាក់ឬរូបីយ៍ (Concrete operational)ចាប់ពី៧ឆ្នាំ ដល់កុមារអាយុ១១ឆ្នាំ**

នៅក្នុងដំណាក់កាលនេះ កុមារបន្តចូលរៀននៅសាលាបឋមសិក្សា ពួកគេអាចយល់បាននូវរូបតំណាងឱ្យគំនិត និងព្រឹត្តិការណ៍ផ្សេងៗ កាន់តែមានភាពបត់បែន និងសមហេតុផល។ រីឯការគិតរបស់ពួកគេនៅតែមានលក្ខណៈជាមូលដ្ឋាននៅឡើយ បើប្រៀបធៀបជាមួយមនុស្សពេញវ័យហើយជាធម្មតាក្នុងដំណាក់កាលប្រតិបត្តិការជាក់លាក់នេះកុមារអាចធ្វើតាមការណែនាំដោយមិនដឹងខ្លួនថា"ប្រសិនបើគ្មានអ្វីត្រូវបានបន្ថែម ឬដកចេញទេ នោះបរិមាណនៃវត្ថុអ្វីមួយនឹងនៅដដែល"។
ឧទាហរណ៍៖ ដំបូងគេមានកែវខ្លី២ ដែលមានទឹកស្មើគ្នា រួចគេផ្ទេរទឹកក្នុងកែវខ្លី ទៅក្នុងកែវវែង។ កុមារដឹងថា បរិមាណទឹកមិនប្រែប្រួលទេ។
ដូច្នេះដំណាក់កាលនេះ ទោះកុមារយល់ដឹងថា ទម្រង់នៃរូបធាតុប្រែប្រួលក៏ដោយ(កែវទឹក)ក៏ ចំណុះបរិមាណ(ទឹក) ឬទំងន់នៃវត្ថុនោះមិនប្រែប្រួលឡើយ។ ការយល់នេះ គេថាកុមារយល់ដឹង បែបរក្សាលក្ខណៈដដែលនៃចំណុះឬចំនួន។ កុមារអាយុ៧ឆ្នាំ អាចយល់ដឹងអំពីការរក្សាលក្ខណៈបែបបរិមាណ។ រីឯកុមារប្រហែលអាយុ៩ឆ្នាំ អាចយល់ដឹងអំពីការរក្សាលក្ខណៈបែបទម្ងន់។



*រូបភាព 33៖ដំណាក់កាលទី៣ ប្រតិបត្តិការជាក់លាក់ឬរូបីយ៍ (Concrete operational)*

- **ដំណាក់កាលទី៤៖ ប្រតិបត្តិការជាទម្រង់ឬអរូបីយ៍ (Formal operational)កុមារចាប់ពីអាយុ ១១ឆ្នាំ ឡើងទៅ**

នៅដំណាក់កាលទី៤នេះ កុមារអាចវែកញែកមិនត្រឹមតែអំពីវត្ថុ និងព្រឹត្តិការណ៍ជាក់ស្តែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពីសម្មតិកម្ម ឬការគិតតាមបែបអរូបីផងដែរ។ ដូច្នេះហើយ បានជាមានឈ្មោះថា ដំណាក់កាលប្រតិបត្តិជាទម្រង់ ឬអរូបីយ៍ ដែលជារយៈពេលនៃការគិតរបស់បុគ្គលអាច "ប្រតិបត្តិការ" លើ "ទម្រង់" ឬរូបតំណាង។ ជាមួយនេះផងដែរ គ្រូអាចបង្កើតចំណោទ ឬសម្មតិកម្មដែលផ្ទុយទៅនឹងការពិត ឱ្យសិស្សនៅកម្រិតនេះអនុវត្ត។ដើម្បីឆ្លើយសំណួរបែបនេះ សិស្សត្រូវប្រើហេតុផល ឬសម្មតិកម្ម មានន័យថាពួកគេត្រូវតែរៀបចំគំនិតដែលប្រែប្រួលតាមវិធីជាច្រើនក្នុងពេលតែមួយ ហើយពួកគេធ្វើដូច្នេះទាំងស្រុងនៅក្នុងការគិតរបស់ពួកគេ។
ឧទាហរណ៍៖ គ្រូដាក់ចំណោទបែបឧបមារទៅកាន់សិស្ស! (ប្រសិនស្រមោចធ្ងន់ជាងសត្វតោ, ហើយតោធ្ងន់ជាងត្រីបាឡែនក្នុងសមុទ្រ, តើស្រមោចនិងត្រីបាឡែន មួយណាធ្ងន់ជាង? តាមពិតប្រាកដ និងជាក់ស្តែងគឺ ស្រមោចស្រាលជាងតោ។ តែសិស្សអាចឆ្លើយថា ស្រមោចធ្ងន់ជាងតោ!(តាមចម្លើយបែបឧបមា)។



*រូបភាព 34៖ប្រតិបត្តិការជាទម្រង់ ឬអរូបីយ៍ (Formal operational)*

**លំហាត់អនុវត្ត៖**

ចូរអ្នកជ្រើសរើសរូបភាពនីមួយៗឱ្យបានត្រឹមត្រូវតាមដំណាក់កាលអភិវឌ្ឍពុទ្ធិទាំង៤




*រូបភាព 35៖ដំណាក់កាលអភិវឌ្ឍទាំង៤*

## ៦.៤សន្និដ្ឋាន

មេរៀននេះផ្តោតលើការអភិវឌ្ឍពុទ្ធិ យោងតាមទ្រឹស្តីរបស់ចិត្តវិទូ លោក Jean Piaget គឺបានលើកឡើងនូវការវិវត្តនៃពុទ្ធិរបស់កុមារ និងលក្ខណៈពិសេសដែលជាធាតុផ្សំនាំឆ្ពោះទៅរកភាពរីកលូតលាស់ ឬភាពរីកចម្រើនរបស់កុមារតូច ដែលក្នុងនោះដែរ យើងអាចកត់សម្គាល់ឃើញថាដំណើរការគិត និងការចងចាំ បង្ហាញអំពីការអភិវឌ្ឍន៍នៃការយល់ដឹងដែលតែងតែមានការផ្លាស់ប្តូរពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ ជាពិសេសវាមានអត្ថប្រយោជន៍ ចំពោះការសិក្សារបស់សិស្ស ដែលពួកគេប្រើប្រាស់បញ្ញា ស្មារតីនៅក្នុងការទំនាក់ទំនងដោយផ្សារភ្ជាប់ទៅនឹងបទពិសោធថ្មីៗដែលពួកគេកំពុងរៀនសូត្រ ដើម្បីអភិវឌ្ឍគំនិត និងបញ្ញារយៈពេលវែងផងដែរ។

### សំណួរត្រិះរិះ

១.តើអ្វីជាភាពខុសគ្នារវាងរបៀបគិតកុមារ និងមនុស្សពេញវ័យ?

២. តើអ្នក នឹងអនុវត្តការអភិវឌ្ឍពុទ្ធិនៅក្នុងបរិបទអប់រំបានយ៉ាងដូចម្តេច?

# មេរៀនទី៧ ដំណើរការរៀន

( Learning Process )

## ៧.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹងៈ

- ប្រាប់បានពីសញ្ញាណទូទៅនៃទ្រឹស្តីដែលជាមូលដ្ឋាននៃការរៀន យោងតាមការដាក់លក្ខខណ្ឌបុរាណ និងការដាក់លក្ខខណ្ឌប្រតិបត្តិ
- បកស្រាយបានច្បាស់លាស់ពីរបៀបរៀន ឬវិធីរៀនខុសគ្នាៗរបស់សិស្សម្នាក់ៗ
- ទទួលយកបទពិសោធដែលទាក់ទងទៅនិងរបៀបរៀនខុសៗគ្នារបស់សិស្សម្នាក់ៗ តាមរយៈការរៀនសង្កេត ដើម្បីយកទៅប្រើប្រាស់នៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ។

## ៧.២ សេចក្តីផ្តើម

ដំណើរការបង្រៀន និងរៀនអាចកំណត់ថាជាការផ្ទេរចំណេះដឹងពីគ្រូទៅសិស្ស ឬអាចជាការរួមបញ្ចូលគ្នានៃសមាសធាតុផ្សេងៗនៅក្នុងលំនាំនៃការបង្រៀន និងរៀនដែលគ្រូបានកំណត់ និង បង្កើតគោលបំណងសិក្សា ដើម្បីអភិវឌ្ឍធនធានមនុស្ស ឬសម្ភារឧបទ្ទេសសម្រាប់ការបង្រៀន រួមទាំងអនុវត្តវិធីសាស្រ្តបង្រៀន ដើម្បីឱ្យសិស្សទទួលបាននូវ ចំណេះដឹង បំណិន និងឥរិយាបថជាវិជ្ជមាន។ ចំពោះដំណើរការរៀនរបស់សិស្ស គឺជាកត្តាសំខាន់ដែលគ្រូចាំបាច់ត្រូវពិចារណានៅពេលដែលគ្រូបង្រៀនពួកគាត់។ តាមរយៈការសិក្សាស្រាវជ្រាវនានាៗ បានបង្ហាញឱ្យឃើញថា ការផ្តល់ទម្រង់អប់រំមានលក្ខណៈវិជ្ជមានជានិច្ច និងមានភាពប្រសើរឡើងលុះត្រាតែ មានមតិកែលម្អ ការអភិវឌ្ឍដែលគិតគូរដល់ឥទ្ធិពលជាវិជ្ជមានផ្តោតលើភាពមានទំនុកចិត្ត និងការគោរពខ្លួនឯងរបស់សិស្ស។ កត្តាទាំងនេះត្រូវបានគេមើលឃើញថា បរិយាកាសសិក្សាមានភាពសកម្មនៅក្នុងដំណើរការបង្រៀន និងរៀន នេះពិតជាគុណតម្លៃមួយដែលជួយលើកកម្ពស់គុណភាពនៅក្នុងវិស័យអប់រំឱ្យកាន់តែមានភាពល្អប្រសើរឡើង។

ដោយហេតុថាទ្រឹស្តីអប់រំនានាៗតែងតែផ្តោតទៅលើដំណើរការរៀន និងការអភិវឌ្ឍរបស់សិស្ស យើងក៏បានលើកយកទ្រឹស្តីរបស់អ្នកប្រាជ្ញពីររូបមកបង្ហាញ គឺលោក Ivan Pavlov (1849-1936) ជាសរីរៈវិទូ និងជាចិត្តវិទូជនជាតិរុស្សីដែលបានធ្វើពិសោធជាមួយសត្វឆ្កែ។នៅក្នុងបរិបទអប់រំគោលការណ៍

ជាមូលដ្ឋាននៃលក្ខខណ្ឌបុរាណរបស់លោកបានត្រូវគេយកមកប្រើប្រាស់នៅក្នុងបរិយាកាសសិក្សដើម្បីបង្កើនអាកប្បកិរិយាវិជ្ជមាន ឬកាត់បន្ថយអាកប្បកិរិយាមិនល្អ។ ដោយឡែក លោក Burrhus Frederic Skinner (1904-1990) ជាចិត្តវិទូ ជនជាតិអាមេរិកាំង លោកជឿថាការបង្រៀនដែលមានប្រសិទ្ធភាពត្រូវតែផ្តែកលើការពង្រឹងភាពជាវិជ្ជមាន ដែលនាំឱ្យមានប្រសិទ្ធភាពលើការផ្លាស់ប្តូរ ឬបង្កើតអាកប្បកិរិយាល្អជាជាងការដាក់ទណ្ឌកម្ម។

## ៧.៣ ខ្លឹមសារ

## ៧.៣.១ លក្ខខណ្ឌបុរាណក្នុងការអភិវឌ្ឍការសិក្សារបស់សិស្ស

(Classical Conditioning in student learning development)

### ក) លក្ខខណ្ឌបុរាណជាអ្វី? (Classical Conditioning)

គឺជាការបង្កើតការឆ្លើយតបតាមលក្ខខណ្ឌដែលលោក Ivan Pavlov បានធ្វើពិសោធជាមួយសត្វឆ្កែដោយការភ្ជាប់កណ្តឹងជាមួយនឹងទឹកមាត់របស់វា។




*រូបភាព 36៖ លក្ខខណ្ឌបុរាណ (Classical Conditioning) Ivan Pavlov*

លោក Ivan Pavlov លើកឡើងថា គោលការណ៍នៃការដាក់លក្ខខណ្ឌបុរាណ តាមរយៈលទ្ធផលសិក្សាគឺអាចសម្រេចបាននៅការឆ្លើយតបតាមលក្ខខណ្ឌ។ ការឆ្លើយតបតាមលក្ខខណ្ឌត្រូវបានបង្កើតឡើងជាសេរី និងបន្តបន្ទាប់គ្នាដោយសារការភ្ញោច (ការជំរុញ)។

- **គំនូសបំព្រួញទី១៖** ក្នុងលក្ខខណ្ឌធម្មតា ពន្លឺចង្កៀង ជារំញោចណឺត គ្មានប្រយោជន៍អ្វីទៅលើក្រពេញ ទឹកមាត់ឆ្កែទេ។
- **គំនូសបំព្រួញទី២៖** វត្ថុភ្លោច (សាច់) ដែលប៉ះនឹងអណ្តាតរបស់ឆ្កែ បង្កើតបានជាទឹកមាត់ ហើយនេះជា រ៉េផ្លិចឥតលក្ខខណ្ឌធម្មតា។
- **គំនូសបំព្រួញទី៣៖** ក្នុងពេលតែមួយ គេផ្តល់វត្ថុភ្លោចលើអណ្តាតរបស់វាផង និងលើភ្នែករបស់វាផង។ នៅពេលនេះ គេដឹងថានៅចន្លោះមណ្ឌលទាំងពីរនៃកំរតិច និងនៅចន្លោះសរីរាង្គវិភាគគឺ ជីវ្ហាវិញ្ញាណ និង ចក្ខុវិញ្ញាណ មានខ្សែបន្ទាត់មួយតភ្ជាប់គ្នារវាងមណ្ឌលទាំងពីរនោះជាបណ្តោះអាសន្ន។
- **គំនូសបំព្រួញទី៤៖** ក្រោយពីបានផ្តល់រំញោចទាំងពីរនោះជាច្រើនដងក្នុងពេលជាមួយគ្នា គេសង្កេតឃើញ ខ្សែភ្ជាប់បណ្តោះអាសន្ននោះស្ថិតនៅនឹងកំរតិចខួរក្នុងមួយរយៈពេលតែប៉ុណ្ណោះ ជាលទ្ធផលដែលគេទទួលបានគឺរំញោចដែលណឺត( ពន្លឺចង្កៀង )ចាប់ផ្តើមឱ្យឆ្កែចេញទឹកមាត់ (នេះជារ៉េផ្លិចមានលក្ខខណ្ឌរបស់ឆ្កែ)។

ដូច្នេះយើងឃើញថាសកម្មភាពនៃរ៉េផ្លិចមានលក្ខខណ្ឌគឺការបន្សាំសពាង្គកាយទៅនឹងស្ថានភាព ឬ មជ្ឈដ្ឋានជុំវិញហើយវាមានកម្រិតខ្ពស់ជាងរ៉េផ្លិចឥតលក្ខខណ្ឌ។ រ៉េផ្លិចមានលក្ខខណ្ឌបង្កើតឡើងដោយ កំរតិចខួរក្បាល ពោលគឺសកម្មភាពនៃសរសៃប្រសាទខាងលើ។

➢ គោលការណ៍នៃការដាក់លក្ខខ័ណ្ឌបុរាណៈ

**-ទូទៅកម្ម** (Generalization) ៖ ក្រោយពេលដាក់លក្ខខ័ណ្ឌ ការភ្លោចផ្សេងទៀតដែល ស្រដៀងគ្នាទៅនឹងការភ្លោចមានលក្ខខណ្ឌ អាចភ្លោចដោយឆ្លើយតប។ គេហៅថា ទូទៅកម្មនៃការភ្លោច។ ឧទាហរណ៍៖ គាត់មានប្រតិកម្មជាភាពភ័យខ្លាច មិនត្រឹមតែផ្កាពណ៌ផ្កាឈូកទេ ថែមទាំងខ្លាចផ្កាពណ៌ទឹកក្រូចនិងពណ៌លឿងផងដែរ។

**-ភាពរើសអើង** (Discrimination)៖ សមត្ថភាព ដើម្បីចំណាំ ភាពខុសគ្នារវាងវត្ថុមួយ ជាមួយ នឹងវត្ថុមួយទៀត ភាពរើសអើងក្នុងការភ្លោច កើតមានឡើងនៅពេលយើង រៀនឆ្លើយតបទៅនឹងការ ភ្លោចជាក់លាក់មួយ ប៉ុន្តែមិនឆ្លើយតបទៅនឹងការភ្លោចផ្សេងដែលស្រដៀងគ្នាឡើយ។
ឧទាហរណ៍៖ គាត់ប្រតិកម្ម ដោយភ័យខ្លាចទៅនឹងផ្កាស្រស់ (ផ្កាពិត) ប៉ុន្តែគាត់មិនខ្លាចជាមួយនឹងផ្កាជ័រឡើយ។

**-ភាពចុះខ្សោយ** (Extinction)៖ ភាពចុះខ្សោយនៃការឆ្លើយតបទៅនឹងលក្ខខណ្ឌ តាមរយៈការ ដកចេញនូវកម្លាំងជំរុញ។
ឧទាហរណ៍៖ នាងថយចុះនូវការភ័យខ្លាចផ្កាពណ៌ផ្កាឈូក ប្រសិនបើនាងមិនបានជួបសត្វឃ្មុំទៀត។

**-ភាពជាសះស្បើយដោយខ្លួនឯង** (Spontaneous Recovery)៖ ការកើតមានឡើងវិញនូវការ ឆ្លើយតបដែលបានរៀន បន្ទាប់ពីភាពចុះខ្សោយកើតមានឡើង។

ឧទាហរណ៍៖ នាងអាចប្រតិកម្មជាភាពភ័យខ្លាចម្តងទៀតនៅឆ្នាំក្រោយ នៅពេល រដូវផ្ការីកម្តងទៀត ទោះបីសត្វឃ្មុំមិនទិចនាងក៏ដោយ។

ដើម្បីបង្កើតរ៉េផ្លិចមានលក្ខខណ្ឌ ត្រូវមានលក្ខខណ្ឌដូចតទៅ៖

- **ចំពោះសត្វ៖** ត្រូវពឹងផ្អែកលើ រ៉េផ្លិចឥតលក្ខខណ្ឌមួយ ឬរ៉េផ្លិចមានលក្ខខណ្ឌដែលមានពីមុន ទើបសម្រេចបានរ៉េផ្លិចមានលក្ខខណ្ឌ។
- **ចំពោះមនុស្ស៖** ត្រូវពឹងផ្អែកលើបទពិសោធដែលគេធ្លាប់មានពីមុនមក។

**ឧទាហរណ៍ទី១៖** សិស្សស្តាប់គ្រូធ្វើអត្ថាធិប្បាយពីខ្លឹមសារមេរៀនមួយ សិស្សអាចកត់ត្រាបាននូវចំណុចសំខាន់ៗនៃមេរៀន មកពីសិស្សមានចំណេះដឹងទូទៅទូលំទូលាយ និងមានសមត្ថភាពមានស្រាប់ពីមុនរួចមកហើយ។

**ឧទាហរណ៍ទី២៖** នៅក្នុងថ្នាក់រៀនមួយ គ្រូអាចបង្កើតការឆ្លើយតបតាមលក្ខខណ្ឌដើម្បីឱ្យសិស្សមានបម្រុងប្រយ័ត្ននៅក្នុងថ្នាក់ ដោយគ្រូប្រកាសថាថ្នាក់រៀននឹងចេញមុនម៉ោងកំណត់ ប្រសិនបើមេរៀនសិស្សសរសេរចូលបានត្រឹមត្រូវ និងស្ទាត់ជំនាញ។ ហើយសិស្សដែលឆ្លើយសំណួរមេរៀនបានត្រឹមត្រូវអាចចេញមុនដប់ប្រាំនាទី។ រីឯសិស្សដែលឆ្លើយមិនបានត្រឹមត្រូវគឺតម្រូវឱ្យនៅដល់បញ្ចប់ម៉ោង ឬខកខានមិនបានឆ្លើយសំណួរគ្រូ។

តាមរយៈឧទាហរណ៍ទី២នេះជាការភ្ញោច( ការជំរុញ )គឺជាឱកាសដើម្បីចេញមុនម៉ោងកំណត់ហើយ ការឆ្លើយតបតាមលក្ខខណ្ឌ គឺមានបម្រុងប្រយ័ត្ន( យកចិត្តទុកស្តាប់គ្រូ )ដើម្បីបានចេញមុនម៉ោង។

**ឧទាហរណ៍ទី៣៖**

សំណួរទី១៖ តើនៅពេលអ្នកឃើញគេញ៉ាំក្រូចឆ្មារ ទោះជាខ្លួនមិនបានញ៉ាំក៏ចេញទឹកមាត់ដែរមែនទេ?

សំណួរទី២៖ ចុះហេតុអ្វីបានជាឃើញក្រូចឆ្មារ ស្រាប់តែយើងចេញទឹកមាត់?

ចម្លើយ៖ ចំពោះអ្នកដែលមិនធ្លាប់ញ៉ាំ ពេលឃើញក្រូចឆ្មារ ក៏មិនចេញទឹកមាត់ទេ! អ្នកដែលធ្លាប់ញ៉ាំក្រូចឆ្មារច្រើនដងគ្រាន់តែឃើញក៏ចេញទឹកមាត់ដែរ!។

**ការពន្យល់អំពីការដាក់លក្ខខណ្ឌបុរាណ (យោងតាមឧទាហរណ៍ទី២)**

- **ពេលគេញ៉ាំក្រូចឆ្មារចេញទឹកមាត់៖** ទឹកក្រូចឆ្មារ ដែលមានរសជាតិជូរនៅក្នុងមាត់




*រូបភាព 37៖លក្ខខណ្ឌបុរាណ(ការពិសោធរវាងមនុស្ស និងក្រូចឆ្មារ)*

គេហៅថា ជាការជំរុញឥតលក្ខខណ្ឌ ហើយការចេញទឹកមាត់ដែលកើតឡើងនោះ គេឱ្យឈ្មោះថាជាប្រតិកម្មឥតលក្ខខណ្ឌ (Unconditioned Response) ។

- **ពេលគេធ្លាប់ញ៉ាំក្រូចឆ្មារច្រើនដង គ្រាន់តែឃើញក្រូចឆ្មារក៏ចេញទឹកមាត់ដែរ៖** ផ្លែក្រូចឆ្មារ ជារូបភាពដែលជំរុញ ដែលគេហៅថាការជំរុញមានលក្ខខណ្ឌ (Conditioned Stimulus) ហើយប្រតិកម្មចេញជាទឹកមាត់គេឱ្យឈ្មោះប្រតិកម្មមានលក្ខខណ្ឌ (Conditioned Response)




*រូបភាព 38៖ការជំរុញមានលក្ខខណ្ឌ និង ប្រតិកម្មមានលក្ខខណ្ឌ*

នៅក្នុងការអប់រំ ការដាក់លក្ខខណ្ឌបុរាណ សិស្សយល់ឃើញថា វាជាជម្រើសមួយដែលត្រូវបានបង្កើតឡើងដើម្បីឆ្លោះទៅរកលទ្ធផលដែលពួកគេចង់បាន តាមរយៈការផ្សាំទៅនឹងការជំរុញនានា ដូចជាអាកប្បកិរិយាដែលគ្មានលក្ខខណ្ឌ ការចង់បានសេរីភាព(ចេញលេងមុនម៉ោង)ដែលត្រូវបានប្រើដើម្បីបង្កើតអាកប្បកិរិយាដែលមានលក្ខខណ្ឌថ្មី តាមរយៈការស្តាប់គ្រូដោយយកចិត្តទុកដាក់ជាដើម។ ជារួមទ្រឹស្តីរបស់លោក Ivan Pavlov ស្តីអំពីលក្ខខណ្ឌបុរាណ ដែលប្រើនៅក្នុងបរិបទអប់រំគឺជាការកំណត់លក្ខខណ្ឌជាក់លាក់ទៅកាន់សិស្ស អ្វីៗដែលសំខាន់បំផុតក្នុងការរៀនតាមទ្រឹស្តីលក្ខខណ្ឌបុរាណនេះគឺ

ត្រូវបានបន្តអនុវត្តជាប្រចាំ។ អាទិភាពនៅក្នុងទ្រឹស្តីនេះគឺការរៀនដែលបណ្តុះឡើងឱ្យមានស្វ័យសិក្សា ហើយទ្រឹស្តីនេះក៏បានបង្ហាញឱ្យឃើញថា អាកប្បកិរិយារបស់សិស្សចេញជាលទ្ធផល ដោយការលក្ខខណ្ឌ ដែលបានមកពីការរៀនសូត្រ ឬទម្លាប់នៃប្រតិកម្មទៅនឹងលក្ខខណ្ឌជាក់លាក់ ឬជាការជំរុញវិជ្ជមានដែលតែងតែកើតមានក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

## ៧.៣.២ លក្ខខណ្ឌប្រតិបត្តិក្នុងការអភិវឌ្ឍការសិក្សារបស់សិស្ស

(Instrumental/Operant Conditioning in student learning development)

ទ្រឹស្តីនៃការដាក់លក្ខខណ្ឌប្រតិបត្តិ គឺរកឃើញដោយចិត្តវិទូអាមេរិចកាំង គឺលោក Burrhus Frederic Skinner។ លោកSkinner មានជំនឿថាអាកប្បកិរិយារបស់បុគ្គលជាលទ្ធផលគឺជាប់ទាក់ទងជា នឹងមួយរង្វាន់ និងការដាក់ទណ្ឌកម្មនៅក្នុងមជ្ឈដ្ឋានរស់នៅ។ នៅក្នុងបរិបទអប់រំផ្តោតសំខាន់លើរចនាសម្ព័ន្ធនៃការបង្រៀន និងការរៀន គឺត្រូវបានរៀបចំឡើងយ៉ាងតឹងរ៉ឹង ដើម្បីបង្កើននូវអាកប្បកិរិយាជាវិជ្ជមានតាមរយៈការជុំរុញ (Reinforcement)។

ម្យ៉ាងវិញទៀតមនុស្សអាចរៀនពីគ្នាបានអំពីការដាក់ទណ្ឌកម្ម តើគេគួរធ្វើយ៉ាងណាដើម្បីជៀសវាងការការដាក់ទណ្ឌកម្ម?។ ឧទាហរណ៍៖ ប្រសិនបើសិស្សត្រូវបង្ខំឱ្យហាត់លេងឧបករណ៍ភ្លេង នោះគាត់មកចូលរួមហ្វឹកហាត់ជាមួយការដាក់ទណ្ឌកម្ម ដូច្នេះនាំឱ្យសិស្សគាត់មានអារម្មណ៍ភ័យខ្លាច និងមិនចង់ហាត់ឧបករណ៍ភ្លេងឡើយ ដែលនាំឱ្យមានផលប៉ះពាល់ចំពោះការអនុវត្តយ៉ាងទូលំទូលាយនៅក្នុងការរៀនសូត្រ និងការដាក់ទណ្ឌកម្មសម្រាប់ការអប់រំ។លោកSkinner បានលើកឡើងថាអាកប្បកិរិយារបស់សិស្សដែលស្ថិតក្រោមការគ្រប់គ្រងដ៏សមស្របមួយតាមរយៈការផ្តល់នូវការពង្រឹង(reinforcement)

តែងតែមានវត្តមាននៃការភ្ញោច(stimuli)ជាទូទៅច្រើនតែជាប់ទាក់ទងនឹងកិច្ចការសិក្សាតែប៉ុណ្ណោះពីព្រោះគាត់ជឿថា អាកប្បកិរិយារបស់សិស្សអាចទទួលឥទ្ធិពលមកពីការលំបាកតូចៗដែលតែងតែកើតមានឡើងជាបន្តបន្ទាប់ ដែលមានលក្ខណៈសាមញ្ញដូចជា ការទុកឱកាសជាពេលវេលាដែលនាំឆ្ពោះទៅមុខ បន្ទាប់ពីសម្រេចបានសកម្មភាពមួយជំហានម្តងៗ ហើយវាក៏ជាប់ទាក់ទង ផងដែរទៅនឹងអ្នកពង្រឹង (reinforcement) លោកបានបន្ថែមទៀតថា ដើម្បីរៀន សិស្សត្រូវតែចូលរួមធ្វើសកម្មភាព ឬអាកប្បកិរិយា ដែលមិនអសកម្មនូវការទទួលព័ត៌មាននោះឡើយ។

### តើអ្វីជាការដាក់លក្ខខណ្ឌប្រតិបត្តិ?

ការដាក់លក្ខខណ្ឌប្រតិបត្តិ គឺជាការប្រែប្រួលចំនួនដងរបស់សកម្មភាពទៅតាមលទ្ធផលនៃការធ្វើសកម្មភាពណាមួយនោះ។

កត្តាដែលធ្វើឱ្យផ្លាស់ប្តូរចំនួនដង នៃសកម្មភាព មាន២៖

**ក) ការពង្រឹង** (Reinforcement) ជាកត្តាបង្កើនសកម្មភាពមានដូចជា ការសរសើរ ការផ្តល់រង្វាន់។

- ការពង្រឹងមាន២៖

  - **ការពង្រឹងវិជ្ជមាន** (Positive Reinforcement)៖ គឺជាសកម្មភាពដែលធ្វើឱ្យគេសប្បាយរីករាយ ហើយសកម្មភាពក៏មានការកើនឡើង។

ឧទាហរណ៍៖ នៅពេលអ្នកទាំងអស់គ្នាបានអានសៀវភៅចិត្តវិទ្យា ដែលពិបាកយល់ ហើយគ្រូបានឃើញអ្នកអាន និងខិតខំស្វែងយល់ គាត់ក៏សរសើរ។ ពេលនោះចំនួនដងនៃការអានសៀវភៅក៏កើនឡើង។

  - **ការពង្រឹងអវិជ្ជមាន** (Negative Reinforcement)៖ គឺជាការដកចេញនូវរឿងមិនល្អ ហើយសកម្មភាពក៏មានការកើនឡើង។

ឧទាហរណ៍៖ ពេលឃើញអ្នកកំពុងខំរៀន បងប្រុសរបស់អ្នក ក៏បានជួយជូតសម្អាត កាតាបដែលអ្នកធ្វើឱ្យប្រឡាក់ចេញឱ្យស្អាត ឃើញដូចនោះអ្នកក៏កាន់តែខិតខំរៀនឡើង។

**ខ) ការដាក់ទណ្ឌកម្ម** (Punishment) គឺជាការប្រែប្រួលចំនួនដងរបស់សកម្មភាពទៅតាមលទ្ធផលនៃការធ្វើសកម្មភាពណាមួយនោះ។

ឧទាហរណ៍៖ សិស្សជជែកគ្នាពេលកំពុងរៀននៅក្នុងថ្នាក់ សិស្សត្រូវបានគ្រូស្តីបន្ទោសជាខ្លាំង។ ពេលនោះចំនួនដងនៃការជជែកគ្នាក៏ថយចុះ។

- ការដាក់ទណ្ឌកម្មមាន២៖
  - **ការដាក់ទណ្ឌកម្មវិជ្ជមាន (Positive Punishment)** ធ្វើរឿងដែលមិនល្អ នាំឱ្យសកម្មភាពរបស់យើងថយចុះ។ ឧទាហរណ៍៖ ការប្រៀនប្រដៅសិស្សដោយមានភាពម៉ឺងមាត់ កំឡុងពេលសិស្សឡូឡានៅក្នុងថ្នាក់ ពេលនោះការឡូឡារបស់សិស្សត្រូវបានថយចុះ។
  - **ការដាក់ទណ្ឌកម្មអវិជ្ជមាន(Negative Punishment)** គឺជាការដកចេញនូវរឿងសប្បាយរីករាយ ហើយសកម្មភាពថយចុះ។

ឧទាហរណ៍៖ បន្ថយបរិមាណអាហារសម្រន់ នោះការចំណាយក៏ថយចុះដែរ។

➢ ជារួមមកមានធាតុសំខាន់ពីរ ដែលទាក់ទងនឹងការដាក់លក្ខខ័ណ្ឌប្រតិបត្តិ៖

- ធាតុសំខាន់ទី១ គឺអាកប្បកិរិយាបែបប្រតិបត្តិ (Operant behavior) ឬអាកប្បកិរិយាដែលបញ្ចេញដោយឆន្ទៈរបស់នរណាម្នាក់ នៅពេលប្រតិបត្តិការនៅក្នុងមជ្ឈដ្ឋានជុំវិញខ្លួន។

- ធាតុសំខាន់ទី២ គឺលទ្ធផល (consequence) ជាប់ទាក់ទងនឹងអាកប្បកិរិយាប្រតិបត្តិ ។ នៅពេលដែលលទ្ធផលកើនឡើង នោះអាកប្បកិរិយាប្រតិបត្តិត្រូវបានគេសម្តែងចេញ វាត្រូវបានគេឱ្យឈ្មោះថា អ្នកជំរុញ (reinforcer)។ ហើយនៅពេលលទ្ធផលប្រឡងធ្លាក់ចុះ នោះអាកប្បកិរិយាប្រតិបត្តិត្រូវបានគេសម្តែងចេញ ឱ្យឈ្មោះថា អ្នកដាក់ទណ្ឌកម្ម (punisher)។

## ៧.៣.៣ ការរៀនតាមរយៈការសង្កេត (Observational learning)

តាមរយៈនៃការសង្កេតគម្រូមួយបុគ្គលអាច៖

- រៀនអំពីរបៀបឆ្លើយតបថ្មី
- រៀនធ្វើ ឬរៀនជៀសវាងការឆ្លើយតបដែលកើតមានកន្លងមក (ដោយផ្អែកលើអ្វីដែលកើតឡើងពីការធ្វើដដែលៗឬជាគម្រូដែលត្រូវអនុវត្តតាម)
- រៀនពីច្បាប់ទូទៅ ដែលអាចអនុវត្តបាននូវគ្រប់ស្ថានភាព

ចំពោះការរៀនតាមរយៈការសង្កេតក៏កើតមានឡើង អ្វីៗជាច្រើនត្រូវតែប្រព្រឹត្តទៅដូចជា៖

-ទី១៖ អ្នករៀន ត្រូវតែមានបំរុងប្រយ័ត្ន ចំពោះគម្រូនោះ។

-ទី២៖ យើងត្រូវចងចាំនូវគម្រូដែលបានធ្វើ ដើម្បីអនុវត្តតាម។ ប្រសិនបើ អាកប្បកិរិយាមួយដែលអាចចងចាំបាន នោះវានឹងមិនអាចរៀនបានឡើយ។

-ទី៣៖ យើងត្រូវតែខិតខំ ដើម្បីប្រែក្លាយពីអ្វីដែលយើងបានឃើញ ឱ្យទៅជាសកម្មភាព។ ប្រសិនបើយើងគ្មានការជំរុញលើកទឹកចិត្តនោះទេ អាកប្បកិរិយាដែលរៀនតាមរយៈការសង្កេតក៏មិនអាចកើតមានឡើង នឹងមិនអាចបង្ហាញពីអ្វីដែលយើងបានរៀននោះឡើយ។

ជាចុងក្រោយការជំរុញលើកទឹកចិត្តជាចំណុចសំខាន់ជានិច្ចជាកាលរាល់ការធ្វើសកម្មភាពដើម្បីទទួលបានលទ្ធផលល្អ ត្រូវតែផ្សារភ្ជាប់ នឹងអាកប្បកិរិយាដែលអាចសង្កេតបាន នោះវាតែងតែនាំមកនូវការផ្តល់ជារង្វាន់ ឬក៏ជាការដាក់ទណ្ឌកម្ម។

## ៧.៤ សន្និដ្ឋាន

ជារួមមកដំណើរការរៀនមានសារៈសំខាន់បំផុតសម្រាប់គ្រូបង្រៀនក្នុងការបង្កើនការចូលរួមរបស់សិស្សតាមរយៈការរៀនសូត្រសកម្ម និងដើម្បីលើកកម្ពស់ការរួមបញ្ចូលសិស្សតាមរយៈដំណើរការសិក្សា។ យោងតាមទ្រឹស្តីនៃដំណើរការរៀន ស្តីអំពីការដាក់លក្ខខណ្ឌបុរាណគឺផ្តោតសំខាន់ទៅលើគ្រូដែលជាអ្នកបង្ហាញការជំរុញដែលត្រូវបានប្រើដើម្បីបង្កើតអាកប្បកិរិយាដែលមានលក្ខខណ្ឌថ្មីៗ។ រីឯ

ការដាក់លក្ខខណ្ឌតាមបែបឧបករណ៍គឺត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងការអប់រំ ព្រោះវាត្រូវបានចាប់ផ្តើមចេញពីសិស្ស ទៅលើការចាត់ចែងរង្វាន់ ឬការដាក់ទណ្ឌកម្មទៅតាមទង្វើនោះ ហើយសិស្សត្រូវបានបង្ហាញថាវាជាឱកាសដើម្បីផ្លូផ្លងអាកប្បកិរិយារបស់ពួកគេដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមា។ នៅក្នុងដំណើរការបង្រៀន និងរៀនទទួលបានជោគជ័យ ដោយសារតែមានកត្តាជុំរុញការរៀនសូត្ររបស់សិស្សឆ្ពោះទៅមុខផងដែរ នៅក្នុងនោះមានដូចជាការសម្តែងចេញនូវអាកប្បកិរិយាដែលអាចផ្តល់នូវមតិកែលម្អទៅលើការអនុវត្តរបស់ពួកគេ ដូចជាការសរសើរ ការយល់ស្រប ឬព្រមព្រៀង និងការជំរុញលើកទឹកចិត្ត។ ទោះយ៉ាងណាក៏ដោយវាក៏មានសារៈសំខាន់ណាស់ក្នុងការផ្លាស់ប្តូរប្រភេទនៃការពង្រឹង( Reinforcement) ដូច្នេះនាំឱ្យអាកប្បកិរិយាជាវិជ្ជមានត្រូវបានរក្សា។ នេះមិនមែនជាកិច្ចការដែលមានភាពងាយស្រួលនោះទេ ព្រោះគ្រូអាចត្រូវការពេលវេលាដ៏ច្រើន នៅក្នុងដំណើរការនេះ។

### សំណួរត្រិះរិះ

១. ហេតុអ្វីស្រក់ទឹកមាត់ នៅពេលដែលអ្នកបានឃើញផ្លែក្រូចឆ្មារ ទោះវាមិនស្ថិតនៅក្នុងមាត់របស់អ្នកក៏ដោយ ?

២. តើរបៀបរៀនរបស់សិស្សម្នាក់ៗ មានភាពខុសគ្នាដូចម្តេចខ្លះ ?

# មេរៀនទី៨ លំនឹក

( Memory )

## ៨.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹង៖

- ប្រាប់បានពីសញ្ញាណនៃលំនឹក អំពីរបៀបរៀនរបស់សិស្សម្នាក់ៗដែលមានភាពខុសគ្នា
- ប្រើប្រាស់បំណិននៃការធ្វើលំនឹកកម្មនៅក្នុងដំណើរការការបង្រៀន និងរៀន
- មានទម្លាប់ប្រើប្រាស់ច្បាប់ទាំង៣នៃការរក្សាលំនឹកនៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ។

## ៨.២ សេចក្តីផ្តើម

យើងទាំងអស់គ្នាដឹងហើយថាលំនឹកដើរតួនាទីយ៉ាងសំខាន់ចំពោះយើងពេញមួយជីវិត។លំនឹកមានមុខងារដើម្បីរក្សាការចង់ចាំ និងបានបង្ហាញឱ្យដឹងថា តើយើងជានរណា? ជានិច្ចជាកាលចំពោះការរក្សាទំនាក់ទំនងរវាងបុគ្គលម្នាក់ៗ តែងតែជួយយើងនៅក្នុងការដោះស្រាយបញ្ហានានាៗ និងធ្វើការសម្រេចចិត្តបានយ៉ាងច្បាស់លាស់។លំនឹកក៏អាចជាចំណុចស្នូលនៃដំណើរការយល់ដឹងស្មើរទាំងស្រុងដូចជាការស្វែងយល់ ការគិត ។

ជារួមមកអ្នកចិត្តសាស្រ្ត និងអ្នកអប់រំបានព្យាយាមស្វែងយល់ពីរបៀបដែលទទួលបានព័ត៌មាននៅក្នុងយន្តការលំនឹកដែលត្រូវបានរក្សាទុកក្នុងរយៈពេលណាមួយ។

## ៨.៣ ខួរក្បាល

## ៨.៣.១ បញ្ញត្តិ

តើអ្វីជាលំនឹក?

លំនឹក ឬការចងចាំ គឺជាលំនាំចិត្ត ដែលថតយក ផ្ចិតយក រក្សាទុក ស្គាល់ឡើងវិញ និងបង្កើតឡើងវិញ នូវរូបភាពនៃវត្ថុ ឬបាតុភូត ដែលគេបានជួបប្រទះពីពេលមុន និងបទពិសោធទាំងឡាយ ដែលមនុស្សម្នាក់ៗបានឆ្លងកាត់នៅក្នុងអតីតកាល។

លំនឹក គឺជាលំនាំចិត្តដែលឆ្លុះបញ្ចាំងពីបទពិសោធកន្លងមករបស់បុគ្គលក្រោមទម្រង់រូបតំណាង។

- បទពិសោធ៖ អាចជា រូបភាពរូបីយ ការត្រិះរិះពិចារណា ការគិតទាំងពួង ចិត្តរំភើប និងសញ្ចេតនា និងអំពើទាំងឡាយ។
- រូបតំណាង៖ ជារូបភាពនៃវត្ថុ ឬបាតុភូត ដែលលេចឡើងក្នុងខួរក្បាល កាលណាគ្មានវត្ថុ ឬបាតុភូតប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍។

ជារួមលំនឹករបស់មនុស្ស គឺជាបែបបទនៃសំណុំចិត្តសាស្ត្រ និងលក្ខណៈចិត្តរបស់បុគ្គលដែលវិវត្តទៅតាម បទពិសោធ សមត្ថភាពនៃការចងចាំ ការរក្សាទុកព័ត៌មាន និងការបង្កើតឡើងវិញ។

ឧទាហរណ៍៖ ខ្ញុំមើលសៀវភៅ។ រូបភាពសៀវភៅបានឆ្លុះបញ្ចាំង ចូលក្នុងខួរក្បាលរបស់ខ្ញុំ។ ឥឡូវខ្ញុំយកសៀវភៅចេញ សៀវភៅមិនបានធ្វើអំពើមកលើភ្នែកខ្ញុំទេ ប៉ុន្តែរូបភាពសៀវភៅ នៅតែស្ថិតនៅក្នុងខួរក្បាលរបស់ខ្ញុំ។ បាតុភូតនេះហៅថាលំនឹក។

## ៨.៣.២ លំនាំលំនឹក

មូលដ្ឋានគ្រឹះនៃលំនឹក វាជាសកម្មភាពដែលមានលក្ខណៈស្មុគស្មាញ ត្រូវបានបែងចែកជា៖

**ក) លំនឹកនីយកម្ម៖** គឺជាការកត់ត្រារូបភាព ការផ្ចិតនូវស្នាមគំនូសទាំងឡាយដែលបានកត់ត្រាទុកនៅក្នុងខួរក្បាល។ ដើម្បីរំឭកនូវការចងចាំរូបភាពអ្វីមួយ គេត្រូវតែបានឃើញ ឮ ស្ទាប ប៉ះផ្ទាល់វត្ថុនោះសិន មានន័យថា មនុស្សអាចកសាង រូបភាពដែលជាតំណាងរបស់លំនឹក លុះត្រាតែគេបានទទួលឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍ពីលក្ខណៈរបស់រូបភាពនោះជាមុនសិន។



*រូបភាព 39៖លំនឹកនឹយកម្ម*

ឧទាហរណ៍ទី១៖ ពេលយើងនិយាយឈ្មោះលោក Isaac Newton យើងនឹកឃើញដល់ច្បាប់នៃទំនាញផែនដី។

ឧទាហរណ៍ទី២៖ យើងអាចចងចាំអាស័យដ្ឋានរបស់មិត្តរួមថ្នាក់ ប្រសិនបើយើងធ្លាប់មានអាស័យដ្ឋាននោះ ឬក៏ធ្លាប់បានឮ ឬបានទៅដល់ទីនោះ។

**ខ) ការរក្សាទុកព័ត៌មាន Encode៖** គឺជាលំនាំនៃការរក្សាទុកព័ត៌មាន ដែលត្រូវ បានគេ បណ្ដុះ

បណ្ដាលរួចមកហើយនៅលើសំបកខួរក្បាល ក្រោយពីធ្វើលំនឹកកម្ម។ នៅក្នុងការសិក្សាការរក្សាទុកព័ត៌មានមានសារៈសំខាន់ណាស់ សម្រាប់ឱ្យយើងរំឭកឡើងវិញនៅពេលដែលយើងត្រូវការវា។ ការរក្សាទុកព័ត៌មានមានពីរប្រភេទគឺ តាមបែបសកម្ម ជាការរំឭកឡើងវិញនូវឯកសារដែលគេបានចងចាំរួចមកហើយ។ម្យ៉ាងវិញទៀតការរក្សាទុកបែបអកម្មដែលផ្អែកលើមូលដ្ឋាននៃការថាឡើងវិញដោយផ្ទួនៗដង។



*រូបភាព 40៖**ការរក្សាទុកព័ត៌មាន** Encode*

**គ) ការនឹកឃើញព័ត៌មានឡើងវិញ** Storage៖ គឺជាលទ្ធផលរបស់លំនាំនៃលំនឹកកម្ម និងការរក្សាទុកព័ត៌មានត្រូវបានស្ដែងចេញឱ្យឃើញនៅក្នុងលំនាំនៃការនឹកឃើញព័ត៌មានឡើងវិញនិងការបង្កើតព័ត៌មានឡើងវិញ។ ការនឹកឃើញព័ត៌មានឡើងវិញ គឺជាការរំឭកឡើងវិញទៅលើវត្ថុណាមួយកាលណាគេមានអារម្មណ៍មួយទទួលដឹងទៅលើវត្ថុនោះសារជាថ្មី។វាប្រព្រឹត្តទៅបានលុះត្រាណាដែលគេធ្លាប់ឃើញវាពីមុននោះផុសចេញភ្លាមនូវឥន្ទ្រីយារម្មណ៍មួយដោយឡែកហើយយ៉ាងស្និទ្ធស្នាលផង។ នេះជាឥន្ទ្រីយារម្មណ៍ដែលជាមូលដ្ឋាននៃការនឹកឃើញឡើងវិញ។



*រូបភាព 41៖ការនឹកឃើញព័ត៌មានឡើងវិញ Storage*

**ឃ)ការបង្កើតព័ត៌មានឡើងវិញRetrieval៖**គឺរូបភាពដែលបានរក្សាទុកពីមុនមានជីវិតរស់ឡើងវិញដោយម្ចាស់ខ្លួនមិនបាច់ទទួលដឹងអារម្មណ៍សារជាថ្មី ទៅលើវត្ថុដែលផ្តល់រូបភាពនេះក្នុងខួរក្បាល។ ការបង្កើតព័ត៌មានឡើងវិញអាចមានលក្ខណៈ(ជាឆន្ទៈ និងអឆន្ទៈ)។

ឧទាហរណ៍៖ ដើម្បីដោះស្រាយ លំហាត់ធរណីមាត្រគេត្រូវយល់ ឱ្យបានច្បាស់ពីអត្ថន័យរបស់

លំហាត់នោះសិនទើបអាចដោះស្រាយ និងចងចាំបានយូរអង្វែង។

## ៨.៣.៣ ការរក្សាទុកលំនឹក៖

### ក) ច្បាប់ទាំងបីនៃការរក្សាទុកលំនឹក

ដោយយោងតាមទ្រឹស្តី The Atkinson-Shiffrin Theory បានបង្កើតឡើងដោយលោក Richard Atkinson and Richard Shiffrin នៅក្នុងឆ្នាំ១៩៦៨ លោកទាំងពីរបានលើកឡើងអំពីច្បាប់បីនៃការរក្សាទុកលំនឹកទៅតាមលំដាប់ដូចខាងក្រោម៖

- **ការរក្សាទុកដោយឥន្ទ្រីយារម្មណ៍** (sensory store) មានលក្ខណៈដូចជា៖

ទី១. មានទំនាក់ទំនងនឹងសរីរាង្គឥន្ទ្រីយ៍ ដែលទទួលបានពីមជ្ឈដ្ឋានជុំវិញ។

ទី២. ព័ត៌មានដែលទទួលបានពីឥន្ទ្រីយារម្មណ៍បានបាត់បង់ទៅវិញនូវរយៈពេលខ្លី។

ទី៣. ព័ត៌មានតិចតួចប៉ុណ្ណោះដែលបានរក្សាទុក ហើយបញ្ជូនទៅសមាសភាពបន្ទាប់ដែលហៅថាលំនឹករយៈពេលខ្លី។



*រូបភាព 42៖ការរក្សាទុកដោយឥន្ទ្រីយារម្មណ៍ )sensory*

ខ) ការរក្សាទុករយៈពេលខ្លី (short term memory) មានលក្ខណៈដូចជា៖

ទី១. បុគ្គលសម្គាល់ដឹងថា ខ្លួនមានស្មារតី (Consciousness)។

ទី២. ព័ត៌មានអាចទាញយកមកប្រើប្រាស់បាន ហើយវាប្រើនៅក្នុងការសម្រេចចិត្ត ឬក៏ការធ្វើ

កិច្ចការភ្លាមៗ ឬក៏រយៈពេលខ្លី។

ទី៣. ព័ត៌មាននៅក្នុងលំនឹករយៈពេលខ្លីនេះអាចរលុបបាត់ទៅវិញឬភ្លេចក្នុងរយៈពេលប្រហែល ២០វិនាទី។

ទី៤. ព័ត៌មានអាចនឹងការពារមិនឱ្យរលុបបាត់ បើគេធ្វើវារំឭកវាឡើងវិញ(rehearsed)។

ទី៥. ព័ត៌មានដែលរំឭកឡើងវិញច្រើនដង ឬជាបទពិសោធន៍ដែលបង្កើតជាទម្រង់នៃដំណើរ

ការរួមគ្នាមួយដែលគេស្គាល់ថា ការរៀបចំព័ត៌មានតាមលំដាប់លំដោយ (elaboration)

ដែលវាបញ្ជូនព័ត៌មានពីលំនឹករយៈពេលខ្លីនេះ ទៅការរក្សាទុករយៈពេលវែង។




*រូបភាព 43៖ការរក្សាទុករយៈពេលខ្លី )short term memory)*

### គ) ការរក្សាទុករយៈពេលវែង (long term store)

ត្រូវបានកំណត់ថាជាការរក្សាទុកព័ត៌មានដ៏ធំ សម្រាប់យើងប្រើប្រាស់។ វាមានលក្ខណៈដូចជា៖

ទី១.ព័ត៌មានដែលរក្សាទុកនៅដំណាក់កាលនេះត្រូវបានឆ្លងកាត់និងរៀបចំដំណើរតាមលំដាប់លំដោយ ដែលកើតចេញពីការរក្សាទុករយៈពេលខ្លី។

ទី២. ទំហំនៃការរក្សាទុករយៈពេលវែងគ្មានដែនកំណត់ឡើយ។

ទី៣. ព័ត៌មានដែលទាមទារចេញពីការរក្សាទុករយៈពេលវែង ឆ្លងកាត់នូវដំណើរការបង្កើតព័ត៌មានឡើងវិញនោះ ហើយក៏បញ្ជូនវាត្រឡប់ទៅការរក្សាទុករយៈពេលខ្លីវិញ ដែលអាចជាការធ្វើឱ្យមានអធន្ទះ ឬប្រើព័ត៌មាននោះដើម្បីដោះស្រាយបញ្ហាភ្លាមៗ។



*រូបភាព 44៖ការរក្សាទុករយៈពេលវែង (long term store)*

## ៨.៤ ការរក្សាទុកលំនឹកដោយប្រើល្បិចចងចាំ ( chunking )

ជាការបង្កើតទំនាក់ទំនងនៃខ្លឹមសារ ដើម្បីឱ្យមានអត្ថន័យមួយសមរម្យទៅលើអ្វីដែលគ្មានអត្ថន័យ ដើម្បីងាយស្រួលចងចាំ (ការផ្តុំ ការចាត់ចំណាត់ថ្នាក់ ការកាត់ចេញ ការបែងចែកលេខតាមខ្ទង់)។

ឧទាហរណ៍៖ គ្រូហៅលេខឱ្យសិស្សចងចាំ 19932018 ដូច្នេះយើងអាចប្រើវិធី (chunking) ដោយហៅលេខទាំងនោះជាឆ្នាំ ១៩៩៣ និងឆ្នាំ ២០១៨វិញ។

១. ពិសោធន៍ពាក់ព័ន្ធបរិមាណ( ចំនួន )លំនឹករយៈពេលខ្លី ( short-term memory )

២. ពេលគ្រូហៅលេខ១២ដង ទើបអនុញ្ញាត្តិឱ្យកត់ត្រាចូលសន្លឹកកិច្ចការ៖ គ្រូចាប់ផ្តើមហៅ

1. 5
2. 38
3. 174
4. 2538
5. 60956
6. 257098
7. 9752387
8. 19932018
9. 423879538
10. 2987589728
11. 78531985610

12. 628097526785

- តើអ្នកទាំងអស់គ្នាបានចងចាំដល់ត្រឹមណាដែរ?
- ការចងចាំរយៈពេលខ្លីនេះ ត្រូវគេសន្មត់ថា ប្រហែល7±2ខ្ទង់។

## ៨.៥ សន្និដ្ឋាន

លំនឹកមានតួនាទីយ៉ាងសំខាន់ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសគឺនៅក្នុងការបង្រៀន និងរៀន។ បើគ្មានលំនឹកទេ នោះយើងម្នាក់ៗក៏គ្មានបទពិសោធដែរ។ លំនឹកជាលក្ខខណ្ឌមួយក្នុងកាប្រែក្លាយចំណេះដឹងឥន្ទ្រិយ៍ ឱ្យក្លាយទៅជាចំណេះដឹងវិចារ ហើយក៏ជាផ្នែកមួយដែលស្ថិតនៅក្នុងសមាសភាពរបស់បុគ្គលិកលក្ខណៈផងដែរ។ ការបណ្ដុះបណ្ដាលលំនឹកឱ្យដល់សិស្ស និងហ្វឹកហាត់សិស្សឱ្យមានលំនឹកល្អ គឺជាភារៈកិច្ចសំខាន់របស់គ្រូ។

### សំណួរត្រិះរិះ

១. តើមានវត្ថុ ឬព្រឹត្តិការណ៍អ្វីដែលអ្នកធ្លាប់ចាំ?

២. តើអ្នកអាចចងចាំ(លេខទូរស័ព្ទ)បានយូរប៉ុន្មាន?

៣. ដើម្បីកុំឱ្យភ្លេចតើអ្នកត្រូវធ្វើដូចម្ដេចខ្លះ?

# មេរៀនទី៩ ការជំរុញលើកទឹកចិត្ត
( Motivation )

## ៩.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹងៈ

- ប្រាប់បានពីបញ្ញត្តិនៃការជំរុញលើកទឹកចិត្ត
- ជ្រើសរើស និងជំរុញលើកទឹកចិត្តក្នុងការសិក្សាឱ្យបានលទ្ធផលល្អ
- មានស្មារតីជួយបង្កើននូវការជំរុញលើកទឹកចិត្តដល់សិស្ស

## ៩.២ សេចក្តីផ្តើម

សិស្សដែលទទួលបានការជំរុញលើកទឹកចិត្តអាច នឹងសម្រេចបានសក្តានុពលរបស់ពួកគេនិងឆ្ពោះទៅរកភាពជោគជ័យនៅក្នុងការសិក្សា បន្ថែមលើសពីនេះការជំរុញលើកទឹកចិត្ត គឺជាធាតុផ្សំដ៏សំខាន់ក្នុងការបង្រៀន និងការរៀនប្រកបដោយប្រសិទ្ធភាព។ វាមិនត្រឹមតែផ្តល់នូវអាកប្បកិរិយាវិជ្ជមានចំពោះសិស្សប៉ុណ្ណោះទេ ប៉ុន្តែវាក៏រួមចំណែកបង្កើនដល់សុខុមាលភាពរបស់គ្រូ និងសិស្សផងដែរ។ ការស្វែងយល់ពីរបៀបជំរុញទឹកចិត្តសិស្សគឺជារឿងសំខាន់ ប្រសិនបើយើងចង់ផ្តល់ឱ្យពួកគេនូវការចាប់ផ្តើមដ៏ល្អបំផុតក្នុងជីវិត ក៏ដូចជានៅក្នុងការសិក្សាផងដែរ។

## ៩.៣ ខ្លឹមសារ

### ៩.៣.១. បញ្ញត្តិ ៖ តើអ្វីជាការជំរុញលើកទឹកចិត្ត?

គឺជាកម្លាំងជំរុញដែលធ្វើឱ្យបុគ្គលចាប់ផ្តើមធ្វើសកម្មភាព។

ម្យ៉ាងទៀតការជំរុញលើកទឹកចិត្តគឺជាដំណើរការនៃអន្តរកម្មរវាងគ្រូ សិស្ស និងមជ្ឈដ្ឋានជុំវិញ ដែលត្រូវបានកត់សម្គាល់ដោយការ ការចាប់ផ្តើម ការជ្រើសរើស ការកើនឡើងសកម្មភាព ឬការរក្សាភាពជាប់លាប់នៃអាកប្បកិរិយាប្រកបដោយការតម្រង់ទិស។ ឬអាចមានអត្ថន័យថា ជាលក្ខខណ្ឌដែលផ្តល់នូវថាមពលទៅលើអាកប្បកិរិយា ដើម្បីឆ្ពោះទៅរកទិសដៅជាក់លាក់ណាមួយ។ វាក៏ជាបទពិសោធរបស់

បុគ្គលដែលដឹងខ្លួនឯងថា មានតម្រូវការចាំបាច់មួយចំនួនដូចជា៖ ម្ហូបអាហារ សម្លៀកបំពាក់ ជម្រក រួមភេទ។ល។ បុគ្គលម្នាក់ៗមានជម្រើសថា តើការធ្វើសកម្មភាពទាំងអស់នេះគឺដើម្បីបំពេញនូវចំណង់របស់ខ្លួនដែរឬអត់?។ ជម្រើសនៃសតិសម្បជញ្ញៈ ត្រូវបានលេចឡើងជាលទ្ធផល ជាជាងការគិតទៅរកមូលហេតុដែលជា សភាពនៃការជំរុញលើកទឹកចិត្តរបស់បុគ្គល។ ដូច្នេះ តើអ្វីទៅជាការគ្រប់គ្រងការជំរុញលើកទឹកចិត្ត ប្រសិនបើគ្មានបំណងជ្រើសរើសទេ?យើងអាចមើលឃើញអំពីមូលហេតុនៃការជំរុញលើកទឹកចិត្ត ដែលផ្តើមចេញពី តម្រូវការជីវៈសាស្ត្រនៅក្នុងខួរក្បាល សរីរាង្គកាយ និងវប្បធម៌របស់យើង រហូតដល់អន្តរទំនាក់ទំនងនៅក្នុងសង្គម។




*រូបភាព 45៖ការជំរុញលើកទឹកចិត្ត*

ម្យ៉ាងទៀតយោងតាមលោក Maslow ចិត្តវិទូអាមេរិកាំង លោកបែងចែកតម្រូវការជា៥ប្រភេទ។




*រូបភាព 46៖តម្រូវការ Maslow*

❖ គំរូមួយអំពីកម្លាំងជំរុញជាមូលដ្ឋាន៖

មជ្ឈដ្ឋានខាងក្រៅគឺជាកត្តាមួយដែលជួយក្អោចឧទាហរណ៍៖ដូចជាចំណីអាហារ ឬព្រឹត្តិការណ៍ដែលបុគ្គលបាននឹកឃើញដល់រង្វាន់ដែលទទួលបានកាលពីអតីតកាល។ខណៈពេលនោះ សញ្ញាស្រេកឃ្លានពីរាងកាយបានបង្ហាញចេញ ហើយក៏ និងបំពេញឱ្យខ្លួនបានឆ្អែត ឬបង្កើននូវគុណតម្លៃនៃរង្វាន់នោះភ្លាមៗ។ ព័ត៌មានទាំងពីរនេះ (សញ្ញាស្រេកឃ្លាន និងការចងចាំអំពីរង្វាន់) បានរួមបញ្ចូលគ្នា ដើម្បីបង្កើតបានជារង្វាន់ចុងក្រោយនៃការជំរុញលើកទឹកចិត្តចំពោះកត្តាក្អោចខាងក្រៅ ដែលបញ្ចេញជាអាកប្បកិរិយា និងធ្វើឱ្យបុគ្គលដឹងពីបទពិសោធរបស់ខ្លួន។




*រូបភាព 47៖គំរូមួយអំពីកម្លាំងជំរុញជាមូលដ្ឋាន*

## ៩.៣.២ ប្រភេទនៃការជំរុញលើកទឹកចិត្ត៖

យោងតាមសាស្ត្រាចារ្យចិត្តវិទ្យាអាមេរិកាំង លោក Edward L. Deci, ដែលសិក្សាតាមរយៈការជំរុញលើកទឹកចិត្ត ត្រូវបានបែងចែកជាពីរប្រភេទគឺការលើកទឹកចិត្តខាងក្នុង និងការលើកទឹកចិត្តខាងក្រៅ ត្រូវបានសិក្សាយ៉ាងទូលំទូលាយពិសេសវាមានទំនាក់ទំនងជាមួយនិងការអភិវឌ្ឍ និងការអប់រំ។




*រូបភាព 48៖ការជំរុញលើកទឹកចិត្តខាងក្នុង និងការការជំរុញលើកទឹកចិត្តខាងក្រៅ*

### ក) ការលើកទឹកចិត្តខាងក្នុង (Intrinsic motivation)

ការលើកទឹកចិត្តខាងក្នុងត្រូវបានកំណត់ថាជា ការធ្វើសកម្មភាពជាប់ទាក់ទងនិងការពេញចិត្តជាជាងដើម្បីបានតែលទ្ធផល។ ការជំរុញលើកទឹកចិត្តខាងក្នុងជំរុញឱ្យបុគ្គលធ្វើសកម្មភាពសម្រាប់តែភាពសប្បាយរីករាយ ឬក៏តម្រូវឱ្យមានការប្រកួតប្រជែងគ្នា ជាជាងការបង្ខំពីខាងក្រៅ សម្ពាធ ឬរង្វាន់។ វាជាការតស៊ូដ៏ស្វិតស្វាញក្នុងការដោះស្រាយបញ្ហា។ ហើយបាតុភូតនៃការលើកទឹកចិត្តខាងក្នុងនេះត្រូវបានទទួលស្គាល់ថាជា អាកប្បកិរិយាដែលជំរុញក្នុងការរុករក ការលេងសើច និងការចង់ដឹង សូម្បីតែគ្មានរង្វាន់ក្តី វាមានទំនោរជាការលើកទឹកចិត្តបែបធម្មជាតិ ដែលជាធាតុសំខាន់ក្នុងការអភិវឌ្ឍ រាងកាយ ពុទ្ធិ និងសង្គម ព្រោះវាផ្តើមចេញពីការប្រព្រឹត្តទៅដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលបុគ្គល រីកចម្រើននៅក្នុងផ្នែកចំណេះដឹងនិងជំនាញ។

- ការធ្វើពិសោធន៍ជាមួយកុមារ នៅថ្នាក់មត្តេយ្យដោយ លោកសាស្ត្រាចារ្យចិត្តវិទ្យា អាមេរិកាំង Mark Lepper៖ ឱ្យកុមារគូររូបភាព

  - ករណីទី១៖លក្ខខណ្ឌរំពឹងថា និងទទួលបានរង្វាន់ (The Expected Award Condition)

  គេប្រាប់ទៅកុមារខ្លះនៅមុនពេលគូររូបភាពថា បើកូនគូរបានស្អាត គ្រូនឹងឱ្យប័ណ្ណសរសើរ។

  - ករណីទី២៖ លក្ខខណ្ឌមិនរំពឹងថា និងទទួលបានរង្វាន់ (Unexpected Award Condition)

  ចំពោះកុមារដ៏ទៃទៀត គ្រូមិនបានសន្យាបែបនេះទេ តែពេលគូររូបភាពរួចហើយឱ្យប័ណ្ណសរសើរ។

  - ករណីទី៣៖ លក្ខខណ្ឌមិនរំពឹងថា និងទទួលបានរង្វាន់(No- Reward Condition) ចំពោះកុមារផ្សេងទៀត ក៏មិនបានសន្យាថាឱ្យប័ណ្ណសរសើរហើយក៏មិនមានឱ្យប័ណ្ណសរសើរដែរ។

  - ១ ទៅ ២ សប្តាហ៍ក្រោយ គេសង្កេតមើល៖ ប្រសិនបើមានម៉ោងទំនេរ កុមារមិនចាំបាច់គូររូបឡើយ។ តើពេលម៉ោងទំនេរ កុមារគូររូបភាពបានប៉ុន្មាននាក់?

  ប៉ុន្តែ! ប្រសិនមានម៉ោងទំនេរ បើកុមារណាម្នាក់គូររូប វាគឺជាការជម្រុញលើកទឹកចិត្តពីខាងក្នុង!

  - *តាមរយៈករណីសិក្សាទាំងបីនោះ! សូមសាកល្បងគិតមើលថាតើ កុមារក្នុងករណីមួយណាដែលមិនបានគូររូបភាព។*

  - គឺកុមារស្ថិតនៅក្នុងករណីទី១៖ កុមារនោះនឹងគិតថា ដំបូងខ្ញុំបានគូររូបដោយសារចង់បានរង្វាន់ ឬប័ណ្ណសរសើរ។ តែពេលទំនេរ ទោះបីជាខំគូររូបភាពក៏ដោយប្រហែល មិនបានរង្វាន់នោះយើងអាចសន្និដ្ឋានបានថាការជម្រុញលើកទឹកចិត្តពីខាងក្នុងបានធ្លាក់ចុះ។



*រូបភាព 49៖ករណីសិក្សាដែលទាក់ទងនិងការគូររូប*

➤ *សូមសាកល្បងគិត! ហេតុអ្វីការជំរុញលើកទឹកចិត្តពីខាងក្នុងរបស់កុមារ(ករណីទី២) មិនថយចុះ?*

○ ដោយសារមិនបាន សន្យាជាមុនថានឹងអោយរង្វាន់ ឬប័ណ្ណសរសើរប្រសិនបើមិន សន្យាបែបនេះ ទោះបីជានឹងបានរង្វាន់នៅក្រោយពេលគូររូបភាពដោយ កុមារនោះមិនគិតថា ចង់បានរង្វាន់ ហើយបានគូររូបភាពនៅម៉ោងទំនេរដែរ។



*រូបភាព 50៖ការជំរុញទឹកចិត្តខាងក្នុង*

តាមរយៈការធ្វើពិសោធជាមួយកុមារមកក្រុមការងាររបស់លោក Lepper បានធ្វើការសន្និដ្ឋានថារង្វាន់ដែលរំពឹងទុក( Expected Reward ) ធ្វើឱ្យមានផលប៉ះពាល់ ដល់ការលើកទឹកចិត្តខាងក្នុងរបស់បុគ្គលនៅក្នុងការធ្វើសកម្មភាពដែល គួរឱ្យរីករាយ ឬមានប្រយោជន៍កាលពីពេលមុន។ ការរកឃើញនេះមានសារៈសំខាន់សម្រាប់គ្រូបង្រៀន អំពីការជំរុញទឹកចិត្តខាងក្នុង ដែលត្រូវជួយ ដល់សិស្សរបស់ខ្លួន។ សិស្សគួរតែពឹងផ្អែកលើការលើកទឹកចិត្តខាងក្នុង និងរក្សាអារម្មណ៍នៃស្វ័យភាព ( feeling of autonomy ) និងសមត្ថភាពតាមអ្វីៗដែលអាចធ្វើទៅបាន។

**ខ ) ការលើកទឹកចិត្តខាងក្រៅ ( Extrinsic motivation )**

ការលើកទឹកចិត្តខាងក្រៅ គឺទាក់ទងនិងសកម្មភាពធ្វើឡើងដើម្បីទទួលបានលទ្ធផលដាច់ពីគ្នា

ឧទាហរណ៍៖ សិស្សធ្វើកិច្ចការផ្ទះរបស់គាត់ដែលគ្រូដាក់ឱ្យ ដោយសារតែគាត់ខ្លាចការធ្លាក់ពិន្ទុ វាគឺជាការលើកទឹកចិត្តពីខាងក្រៅដោយសារតែគាត់កំពុងធ្វើកិច្ចការតាមលំដាប់ ដើម្បីសម្រេចបានលទ្ធផលដាច់ពីគ្នានៃការចៀសវាងធ្លាក់ពិន្ទុ។ដោយសារតែអាកប្បកិរិយាបែបលើកទឹកចិត្តពីខាងក្រៅ គឺមិនជាប់ទាក់ទងនិងភាពរីករាយ ឬចំណាប់អារម្មណ៍ក្នុងខ្លួនរបស់បុគ្គល ជាជាងការឱ្យតម្លៃទៅលើរង្វាន់ ហេតុដូច្នេះហើយ ជាដំបូងគេឃើញបុគ្គលត្រូវបានជម្រុញពីខាងក្រៅដែលជាមូលហេតុចម្បងរបស់ខ្លួន ដែលមានឆន្ទៈក្នុងការសម្តែងចេញថាពួកគេត្រូវបានអ្នកនៅជុំវិញឱ្យតម្លៃ។ ទិដ្ឋភាពនេះបង្ហាញថាការបំពេញកិច្ចការគួរ ផ្តល់ឱ្យសិស្សទទួលបាននូវអារម្មណ៍នៃភាពជាកម្មសិទ្ធិ និងការមានទំនាក់ទំនងជាមួយមិត្តរួមថ្នាក់ ឬវប្បធម៌ដែលអាចចែករំលែកបាននូវគោលដៅរួមមួយ។

## ៩.៤ សន្និដ្ឋាន

ការជំរុញលើកទឹកចិត្តមានតួនាទីសំខាន់ក្នុងដំណើរការបង្រៀន និងរៀន ហើយវាក៏ជាតម្រូវការផ្លូវចិត្តជាមូលដ្ឋានផងដែរ ព្រោះយើងបានឃើញថាលក្ខខណ្ឌបរិបទសង្គមដែលជួយគាំទ្រដល់សិស្សឱ្យទទួលបានអារម្មណ៍ថាពួកគេសមត្ថភាព មានស្វ័យភាព និងភាពផ្សារភ្ជាប់គ្នាគឺជាមូលដ្ឋានសម្រាប់ការរក្សាក្នុងការជម្រុញទឹកចិត្តខាងក្នុង ពិសេសជួយឱ្យសិស្សអាចរៀនកំណត់នូវដែនផ្ទាល់ខ្លួនដែលជាប់ទាក់ទង នឹងការលើកទឹកចិត្តពីខាងក្រៅ។ ម្យ៉ាងទៀតសាលារៀនក៏ចូលរួមចំណែកក្នុងការសម្របសម្រួលដល់ការសិក្សារបស់សិស្ស ដោយផ្តល់នូវការពេញចិត្តនៃតម្រូវការមូលដ្ឋានដូចជាការអភិវឌ្ឍផ្លូវកាយ បញ្ញា ស្មារតី និងអារម្មណ៍ថាវាមានភាពផ្សារភ្ជាប់គ្នារវាង គ្រូ និងសហគមន៍របស់សិស្ស ដើម្បីទទួលបាននូវចំណេះដឹង ជំនាញ និងគំនិតថ្មីៗ។

## សំណួរត្រិះរិះ

១. ហេតុអ្វីបានជាអ្នកត្រូវបន្តការរៀនសូត្រ?

២. តើអ្វីដែលអ្នកគួរធ្វើ ក្នុងការព្យាយាមរៀនសូត្រ និងការរៀនដោយពេញចិត្ត?

# មេរៀនទី១០ វិធីសាស្ត្របង្រៀន

( Methods of Teaching )

## ១០.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់ គរុនិស្សិតនឹង៖

- រៀបរាប់បានពីភាពខ្លាំង និងភាពខ្សោយ នៅក្នុងវិធីបង្រៀននីមួយៗ
- មានបំណិនជ្រើសរើសវិធីបង្រៀនសមស្របតាមវត្ថុបំណងមេរៀន
- ប្រែក្លាយទ្រឹស្តីទៅជាបទពិសោធសម្រាប់ការងារបង្រៀន និងរៀន។

## ១០.២ សេចក្តីផ្តើម

នាពេលកន្លងមកលោកគ្រូ អ្នកគ្រូធ្លាប់បានជួបប្រទះនូវបញ្ហាប្រឈមក្នុងការជ្រើសរើសយកនូវវិធីសាស្ត្របង្រៀនឱ្យបានសមស្រប ដើម្បីផ្តល់នូវឱកាសសិក្សាដ៏ល្អបំផុតសម្រាប់សិស្ស។ហេតុដូច្នេះ ការសិក្សាអំពីវិធីសាស្ត្របង្រៀន វាគឺជាជំនាញមួយដែលមានភាពចាំបាច់សម្រាប់លោកគ្រូ អ្នកគ្រូ។ ពិសេសមានសារៈសំខាន់ក្នុងការសិក្សាអំពីវិធីសាស្ត្រនីមួយៗ សម្រាប់មុខវិជ្ជាចិត្តវិទ្យាអប់រំ១មានតម្រូវការកាន់តែច្រើនសម្រាប់អ្នកអប់រំដើម្បីបង្កើននូវចំណេះដឹង និងជំនាញអំពីវិធីសាស្ត្របង្រៀន រួមទាំងបន្តការយល់ដឹងនិងការស្រាវជ្រាវប្រកបដោយគុណភាព រួមទាំងផ្សារភ្ជាប់បទពិសោធជាមួយនឹងទម្រង់នានានៃវិធីសាស្ត្របង្រៀន។

## ១០..៣ ខ្លឹមសារ

### ១០.៣.១ បញ្ញត្តិ

តើវិធីសាស្ត្របង្រៀនជាអ្វី ?

- ជាវិធីនៃសកម្មភាព ដែលទាក់ទងគ្នារវាងគ្រូ និងសិស្សក្នុង គោលបំណងដោះស្រាយបញ្ហាស្មុគស្មាញនៃដំណើរការអប់រំ។

- អត្ថន័យម្យ៉ាងទៀតវិធីសាស្ត្របង្រៀនគឺជាមធ្យោបាយធ្វើឱ្យការងារបង្រៀន និងរៀនដោយស្ថិតនៅក្រោមការដឹកនាំរបស់គ្រូ សិស្ស នឹងទទួលនូវចំណេះដឹង បំណិនប្រសប់ ឥរិយាបថចេះរស់នៅជាមួយគ្នា ព្រមទាំងពង្រីក សតិបញ្ញាស្មារតី របស់សិស្ស សំដៅទៅលើការប្រតិបត្តិនៅគ្រប់ភារកិច្ចនៃការបង្រៀន។

(សៀវភៅវិធីសាស្ត្របង្រៀន ឆ្នាំ២០១៩ ដោយ ប៉ូ ប៊ុន្នន ឡុចចាន់ថន ឃិន វណ្ណី)។

## ១០.៣.២ វិធីសាស្ត្របង្រៀនទាំង៥ប្រភេទ

ដំណើរការបង្រៀនអាចប្រព្រឹត្តទៅបានជោគជ័យ គឺមានកត្តារួមផ្សំពីការប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីឲ្យសិស្សចូលរួមរៀនយ៉ាងសកម្ម និងមានភាពរស់រវើក ដូចនេះនៅក្នុងខ្លឹមសារមេរៀននេះយើងនិងលើកឡើងនូវវិធីសាស្ត្របង្រៀនទាំង៥ រួមទាំងគុណសម្បត្តិ និងគុណវិបត្តិរបស់វិធីសាស្ត្រនីមួយៗមកបង្ហាញ។

១.ការសិក្សានៅក្នុងថ្នាក់ទាំងមូល (Whole-class learning)
២.ការសិក្សាជាក្រុមតូច (Small-group learning)
៣..ការសិក្សាតាមបែបដោះស្រាយបញ្ហា (Project-based learning)
៤.ការសិក្សាតាមបែបស្វែងរក (Discovery learning)
៥.ការសិក្សាតាមវិធីសាស្ត្រ Jigsaw (Jigsaw technique)

## ១០.៣.៣ ការសិក្សានៅក្នុងថ្នាក់ទាំងមូល (Whole-class learning)

គឺជាការបង្រៀនក្នុងថ្នាក់ទាំងមូល នៅក្នុងនោះផងដែរ គ្រូប្រើប្រាស់ការពន្យល់ខ្លឹមសារមេរៀនទូទៅជាមុនសិនទៅកាន់សិស្ស រួមទាំងគ្រូបង្កើតសំណួរសម្រាប់សួរទៅសិស្ស ដើម្បីឱ្យពួកគេត្រិះរិះពិចារណា ដកស្រង់បទពិសោធនៅក្នុងថ្នាក់រៀនជាមួយគ្នា ក្នុងការស្វែងរកចម្លើយ។



*រូបភាព 51៖ការសិក្សានៅក្នុងថ្នាក់ទាំងមូល (whole-class learning)*

*(រូបភាពដកស្រង់ពី:https://www.irishtimes.com/news/science/the-reason-why-modern-teaching-methods-don-t-work-1.2115219)*

| ១ .ការសិក្សានៅក្នុងថ្នាក់ទាំងមូល (whole-class learning) | |
|---|---|
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| • មានប្រសិទ្ធភាពល្អ អាចពន្យល់ខ្លឹមសារបានយ៉ាងល្អ<br>• អាចចែករំលែកខ្លឹមសារដែលបានពិភាក្សាគ្នា ឬធ្វើការរំឭកឡើងវិញជាដើម។ | • ពិបាកដោះស្រាយគម្លាតសិស្ស( សិស្សពូកែ និងសិស្សខ្សោយ )។<br>ឧទាហរណ៍៖ បើគ្រូពន្យល់សិស្សពូកែ នោះសិស្សខ្សោយ តាមមិនទាន់។បើគ្រូពន្យល់សិស្សខ្សោយ នោះ សិស្សពូកែថាងាយពេកគាត់និងធុញទ្រាន់។ |

### ១០.៣.៤ ការសិក្សាក្រុមតូច (Small-group learning)

គឺជាវិធីសាស្ត្រមួយដែលគ្រូ បង្កើតបរិយាកាសរៀនសូត្រមួយ ដោយផ្ដោតសំខាន់ទៅលើការរៀនរបស់សិស្សនៅក្នុងក្រុមតូច តាមរយៈការបង្កើតក្រុមតូចៗរបស់សិស្ស ពួកគេរៀនអាចស្វែងរកចម្លើយដោយខ្លួនឯង រួចជួយបង្រៀនគ្នាទៅវិញទៅមក។

ឧទាហរណ៍៖ គ្រូបង្រៀនខ្លឹមសារអំពី មេរៀនការគិតស៊ីជម្រៅ។បន្ទាប់ពីសិស្សបានស្វែងយល់អំពីបញ្ញតិការគិតស៊ីជម្រៅរួច គ្រូបានដាក់សំណួរឱ្យសិស្សពិភាក្សានៅក្នុងក្រុមតូច តើការគិតស៊ីជម្រៅមានអត្ថប្រយោជន៍អ្វីខ្លះនៅក្នុងការសិក្សា? ។



*រូបភាព 52៖ការសិក្សាក្រុមតូច (Small-group learning)*

(រូបភាពដកស្រង់ពី:https://www.globalpartnership.org/blog/instituting-school-based-support-cambodias-early-grade-teachers

| ២.ការសិក្សាជាក្រុមតូច (Small-group learning) | |
|---|---|
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| • បង្កើនសមត្ថភាពទំនាក់ទំនង(ចែករំលែកអ្នករៀនពូកែ និងអ្នករៀនខ្សោយ)។ | • មានសិស្សខ្លះមិនអាចធ្វើសកម្មភាពនៅក្នុងថ្នាក់បាន។<br>ឧទាហរណ៍៖ សិស្សពូកែចូលរួមពិភាក្សាច្រើន នោះអ្នកផ្សេងនិយាយបានតិច ឬមិនធ្វើសកម្មភាពនៅក្នុងថ្នាក់ រួចក៏ដល់ម៉ោងត្រូវបញ្ចប់។ |

### ១០.៣.៥ ការសិក្សាតាមបែបដោះស្រាយបញ្ហា ( Problem-based, project-based and resource-based learning )

គឺជាការសិក្សាដែលសិស្សធ្វើកិច្ចការ និងសហការគ្នាដោយ សេចក្តីព្យាយាម ដើម្បីដោះស្រាយបញ្ហានានា ដែលតែងតែកើតមានឡើង (ដោយលោក John Dewey អ្នកទស្សនៈវិទូផ្នែកអប់រំជនជាតិអាមេរិកាំង)។ វិធីសាស្ត្រនេះអាចជាទម្រង់មួយនៃគោលវិធីបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល ដែលត្រូវបានគេប្រើប្រាស់ជាជំហានៗដើម្បីឱ្យសិស្សរៀនស្វែងរកដំណោះស្រាយនៃបញ្ហានិងឧបសគ្គនានានៅក្នុងបញ្ញត្តិ ឬខ្លឹមសារដែលបានចោទសួរតាមរយៈការសាកល្បង ម្តងហើយម្តងទៀត ដោយប្រើវិធីផ្សេងៗរហូតដល់ពួកគេទទួលបានជោគជ័យ។ វាជាការចាំបាច់ណាស់សម្រាប់ឱ្យសិស្សទាំងអស់ចេះពីរបៀបដោះស្រាយបញ្ហានានា ឬគណនាលំហាត់នៅក្នុងចំណោទបញ្ហា ណាមួយរបស់ខ្លឹមសារមេរៀន។

(ដកស្រង់ៈ សៀវភៅវិធីសាស្ត្របង្រៀន ដោយវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំយុវជននិងកីឡាបោះពុម្ពឆ្នាំ ២០១៨)

- សិស្សជាអ្នកចូលរួមចំណែកទទួលខុសត្រូវក្នុងការសិក្សារបស់ខ្លួន
- ប្រធានបទ ឬសកម្មភាពត្រូវតែផ្សារភ្ជាប់នឹងជីវភាពរស់នៅប្រចាំថ្ងៃ
- ស្វ័យវាយតម្លៃត្រូវធ្វើឡើងរាល់ការបញ្ចប់សកម្មភាពនីមួយៗ ថាតើការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់រួចរាល់ហើយឬនៅ?
- គ្រូដើរតួនាទីជាអ្នកសម្របសម្រួល ឬជាអ្នកផ្តល់ពត៌មានត្រឡប់ទៅកាន់សិស្ស

ឧទាហរណ៍ៈ គ្រូផ្លុំប៉េងប៉ោង រួចបង្កើតឃ្លាចំនួន៣(១. ប៉េងប៉ោងកាន់តែធំ វាកាន់តែធ្ងន់ ២. ខ្យល់ស្រាល ដូច្នេះផ្លុំខ្យល់ចូល ធ្វើឱ្យប៉េងប៉ោងកាន់តែស្រាល ៣. ដោយសារខ្យល់មិនមានទម្ងន់ ដូច្នេះនាំឱ្យប៉េងប៉ោងរក្សាទម្ងន់ដដែល)។ គ្រូទុកឱ្យសិស្សគិត ពិចារណា និងសហការគ្នា ស្រាវជ្រាវ និងធ្វើការបកស្រាយដើម្បីដោះស្រាយនូវចំណោទរបស់គ្រូ។

| ៣.ការសិក្សាតាមបែបដោះស្រាយបញ្ហាៈ(project-based learning) | |
|---|---|
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| • សិស្សដើរតួនាទីសំខាន់ក្នុងដំណើរការរៀន<br>• លើកកម្ពស់ការសហការ ការទំនាក់ទំនង<br>• លើកកម្ពស់ជំនាញដោះស្រាយបញ្ហា និងការគិតស៊ីជម្រៅ<br>• លើកកម្ពស់ឱ្យដឹកនាំស្វ័យសិក្សា | • មានគម្លាតក្នុងការសហការរបស់សិស្ស<br>• សិស្សខ្វះបទពិសោធន៍<br>• មានភាពមានៈក្នុងការផ្លាស់ប្តូរ |




*រូបភាព 53៖ការសិក្សាតាមបែបដោះស្រាយបញ្ហា( project-based learning )*

*(រូបភាពដកស្រង់ពី:http://makara.ligeracademyblog.org/2016/04/04/project-based-learning-pbl/ )*

## **១០.៣.៦ ការសិក្សាតាមបែបស្វែងរក** ( Discovery learning )

គឺជាវិធីបង្រៀនមួយដែលគ្រូដឹកនាំ ការរៀនរបស់សិស្សឱ្យប្រព្រឹត្ត ទៅនៅក្នុងស្ថានភាពបញ្ហា ដែលសិស្សអាចទាញបាននូវចំណេះដឹង និងបទពិសោធនផ្ទាល់ខ្លួន ក្នុងការទំនាក់ទំនងនឹងមជ្ឈដ្ឋាន រស់នៅរបស់ពួកគេ តាមរយៈការរុករក ការសួរសំណួរ និងការធ្វើពិសោធ ដោយលោក Jerome Bruner ចិត្តវិទូ ជនជាតិអាមេរិចកាំង។

ឧទាហរណ៍៖ គ្រូរៀបចំក្រដាសចតុកោណកែង ការេ ចតុកោណព្នាយ ប្រលេឡូក្រាម រួចបន្ទាប់មកគ្រូប្រាប់ឱ្យ សិស្សកាត់រូបភាពទាំងនោះចេញពីគ្នា។ ជាចុងក្រោយគ្រូប្រាប់ឱ្យសិស្សផ្គុំរូបភាពទាំងអស់នោះ ឱ្យបានមុំ៣៦០ដឺក្រេ។




*រូបភាព 54៖ការសិក្សាតាមបែបស្វែងរក (Discovery learning)*

*(រូបភាពដកស្រង់ពី:https://prezi.com/p/wp6ctnoacvef/jerome-bruner/)*

| ៤.ការសិក្សាតាមបែបស្វែងរក (Discovery learning) | |
|---|---|
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| • សិស្សដើរតួនាទីយ៉ាងសកម្មក្នុងដំណើរការរៀន<br>• សិស្សមានបម្រុងប្រយ័ត្ន<br>• សិស្សមានឱកាសដកស្រង់បទពិសោធ និងស្វែងយល់អ្វីៗដោយខ្លួនឯង<br>• បង្កើនចំណេះដឹង ការយល់ដឹងរបស់សិស្សទុកជាមុន<br>• សិស្សទទួលពត៌មានត្រឡប់មុនការយល់ដឹងរបស់ខ្លួន | • ប្រើពេលច្រើនក្នុងការរៀន<br>• សិស្សអាចកន្លំច្រលំ បើគ្មានការតម្រង់ទិស<br>• គ្រូត្រូវមានការត្រៀមច្រើន(ទាក់ទងនិងដំណើរការមួយនេះ) |

## ១០.៣.៧ ការសិក្សាតាមវិធីសាស្ត្រ ជីកសស (Jigsaw technique)

ការសិក្សាតាមវិធីJigsaw គឺជាគំរូមួយនៃការរៀនតាមបែបសហការណ៍ ដែលជួយឱ្យសិស្សរៀននៅក្នុងថ្នាក់ទទួលបានប្រសិទ្ធភាពខ្ពស់ ដោយសិស្សបានធ្វើកិច្ចការនៅក្នុងក្រុម ហើយពួកគេបានក្លាយជាក្រុមជំនាញ ដែលអាចមើលឃើញពីទិដ្ឋភាពផ្សេងៗនៃខ្លឹមសារមេរៀន រួចចែករំលែកខ្លឹមសារនោះទៅក្រុមដើមរបស់ខ្លួនវិញ។

❖ *របៀបអនុវត្តវិធីសាស្ត្របង្រៀនតាមរយៈ Jigsaw*

- គ្រូផ្ដល់សំណួរគន្លឹះ(សំណួររួម)ឱ្យទៅកាន់សិស្ស
- ឱ្យសិស្សឆ្លើយចម្លើយប៉ានស្មាន
- បែងចែកសិស្សជា៤នាក់/១ក្រុម(ក្រុមដើម)
- ឱ្យសិស្សបង្កើតក្រុមដោយ រាប់លេខពី១ ដល់៤ រួចចូលក្រុមថ្មី(ក្រុមជំនាញ)ដោយលេខ១ ចូលតាមក្រុមលេខ១ លេខ២ ចូលតាមក្រុមលេខ២...រហូតដល់លេខ៤ (គ្រូចែកសំណួរខុសគ្នាៗតាមក្រុមនីមួយៗ)
- គ្រូឱ្យសំណួរខុសគ្នាៗនោះ ទៅកាន់ក្រុមជំនាញដើម្បីពិភាក្សា និងស្រាវជ្រាវ
- ក្រោយពីការពិភាក្សាត្រូវបានបញ្ចប់ក្រុមជំនាញត្រូវចូលមកក្រុមដើមវិញ ដើម្បីចែករំលែកចម្លើយទៅសមាជិកគ្រប់គ្នាៗ
- គ្រូផ្ដល់ពត៌មានត្រឡប់



**រូបភាព 55៖ការបែងចែកក្រុមតាមរបៀបជីកស** (Jigsaw

*(រូបភាពដកស្រង់ពី:*[https://cft.vanderbilt.edu/guides-sub-pages/setting-up-and-facilitating-group-work-using-cooperative-learning-groups-effectively/](https://cft.vanderbilt.edu/guides-sub-pages/setting-up-and-facilitating-group-work-using-cooperative-learning-groups-effectively/) *)*

## ១០.៤ សន្និដ្ឋាន

ជារួមខ្លឹមសារមេរៀន ស្តីពី វិធីសាស្ត្របង្រៀនអាចចាត់ទុកថាជាកញ្ចក់ សម្រាប់ឆ្លុះបញ្ចាំងទៅលើទិដ្ឋភាពជាក់ស្តែងនៅក្នុងការបង្រៀន និងរៀន ដើម្បីទទួលបានគុណភាព និងប្រសិទ្ធភាព តាមរយៈការបង្ហាញចេញនូវលក្ខណៈសម្បត្តិនៃវិធីសាស្ត្រនីមួយៗ។ ក្នុងនោះផងដែរ វិធីសាស្ត្រទាំង៥ក៏បានពន្លេចនូវអត្ថន័យ គោលបំណង ដើម្បីឱ្យការបណ្តុះបណ្តាលកាន់តែមានភាពប្រសើរសម្រាប់មុខវិជ្ជារបស់លោកគ្រូ អ្នកគ្រូ។ ខ្លឹមសារនៃមេរៀននេះ ក៏បានគិតគូរដល់សិស្សានុសិស្ស ដើម្បីឱ្យពួកគេទទួលបាននូវឧត្តមប្រយោជន៍ និងភាពជោគជ័យក្នុងការសិក្សា តាមរយៈការចូលរួមបំពេញនូវកិច្ចការនានានៅក្នុងវិធីសាស្ត្របង្រៀនទាំងនេះស្របតាមខ្លឹមសារមេរៀន ដើម្បីទទួលបាននូវចំណេះដឹង ជំនាញ និងឥរិយាបថដ៏ប្រពៃសម្រាប់សង្គម។

## សំណួរត្រិះរិះ

១. តើគ្រូធ្លាប់ឱ្យអ្នកសង្កេតអ្វីមួយដែរឬទេ ?

២. ប្រសិនបើមាន ហេតុអ្វីគាត់ឱ្យអ្នកសង្កេត ?

# មេរៀនទី១១ ឥទ្ធិពលនៃការរំពឹងទុក

( Pygmalion effects )

## ១១.១ វត្ថុបំណង

ចុងបញ្ចប់នៃមេរៀន គរុនិស្សិតនឹងៈ

- ពិពណ៌នាបានពីឥទ្ធិពលនៃការរំពឹងទុករបស់គ្រូទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស ចេញពីទិដ្ឋភាពនៃចិត្តវិទ្យា
- កំណត់បាននូវការរំពឹងទុកជាវិជ្ជមានរបស់គ្រូចំពោះការបង្រៀន និងរៀន
- ឱ្យតម្លៃខ្ពស់ និងយកចំណេះដឹងដែលទទួលបានពីការរំពឹងទុកទៅប្រើប្រាស់នៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។

## ១១.២ សេចក្តីផ្តើម

សិស្សអាចបំពេញកិច្ចការរបស់ខ្លួនបានល្អនៅពេល ដែលគ្រូមានការរំពឹងទុកបែបវិជ្ជមាន។ ជាពិសេស នៅក្នុងការអប់រំត្រូវបានគេហៅថាឥទ្ធិពលនៃការរំពឹងទុក ( Pygmalion effects ) ។ បន្ទាប់ពីការសិក្សាស្រាវជ្រាវលទ្ធផលបានបង្ហាញឱ្យឃើញថាវាមានសារៈសំខាន់ណាស់សម្រាប់ការអប់រំ។

តាមរយៈការស្រាវជ្រាវមុខវិជ្ជានេះមានមេរៀនមួយ ផ្តោតសំខាន់ទៅលើឥទ្ធិពលនៃការរំពឹងទុក ( Pygmalion effects ) ដែលបានចាប់ផ្តើមឡើងជាមួយចិត្តវិទូពីររូបគឺ លោក Robert Rosenthal និងលោក Lenore Jacobson ដែលសិក្សាតាមបែបបុរាណ។

❖ ការស្រាវជ្រាវទៅលើឥទ្ធិពលនៃការរំពឹងទុកនៅក្នុងថ្នាក់រៀនPygmalion in the Classroom

អ្នកទាំងពីរបានពិពណ៌នាអំពីការពិសោធមួយ ដែលគ្រូមួយចំនួនត្រូវបានជូនដំណឹងថាពួកគេមានសិស្សដែលពូកែ និង ឆ្លាតវៃបានចុះឈ្មោះចូលរៀន។ លោកRobert Rosenthal និងលោក Lenore Jacobson បានធ្វើការស្រាវជ្រាវមួយ ដែលទាក់ទងជាមួយគ្រូបង្រៀននៅសាលាបឋមសិក្សាត្រូវបានគេជូនដំណឹងថា ២០ភាគរយ នៃសិស្សនៅក្នុងសាលារៀនបានបង្ហាញពីសក្តានុពលយ៉ាងខ្លាំងក្លាសម្រាប់ការលូតលាស់បញ្ញា ហើយពួកគេនឹងរីកចម្រើនក្នុងការសិក្សារបស់ខ្លួនមួយឆ្នាំសិក្សាពេញតែ

ម្តង។ ជាការពិត សិស្សទាំងនេះត្រូវបានជ្រើសរើសដោយចៃដន្យ (selected randomly) ដោយមិនទាក់ទងទៅនឹងការធ្វើតេស្តដំបូង ឡើយ។ នៅពេលដែលសិស្សត្រូវបានធ្វើតេស្ត រយៈពេល៨ខែក្រោយមក គេបានរកឃើញថាសិស្សដែលបានជ្រើសរើសដោយចៃដន្យ ដោយសារគ្រូគិតថាគាត់ជាសិស្សពូកែ និងមានសក្តានុពលនោះ នឹងទទួលបានពិន្ទុខ្ពស់ជាងគេ។

ហេតុដូច្នេះដំណើរការរៀនរបស់សិស្សមានទំនាក់ទំនងទៅ នឹងការចង់ចេះ ចង់ដឹង ចង់រៀនរបស់ពួកគេ។ ការរៀនចាប់ផ្តើមដោយការយល់ឃើញរបស់សិស្សអំពីដំណើរការសិក្សា។ ការជំរុញលើកទឹកចិត្តសិស្ស និងការរំពឹងទុករបស់គ្រូទៅលើសិស្សវាតែងតែមានឥទ្ធិពលទៅលើដំណើរការបង្រៀន និងរៀន។ លើសពីនេះទៅទៀតសិស្សក៏ទទួលឥទ្ធិពលពីបរិយាកាសក្នុងការរៀនរបស់ខ្លួនផងដែរ។

## ១១.៣ ខ្លឹមសារ

### ១១.៣.១ បញ្ញត្តិ ៖

តើអ្វីជាឥទ្ធិពលនៃការរំពឹងទុកនៅក្នុងការសិក្សា (Pygmalion effects)?

គឺជាបាតុភូតចិត្តរបស់គ្រូដែលមានការរំពឹងទុកកាន់តែច្រើនទៅលើសិស្ស នោះពួកគេអាចបំពេញកិច្ចការបានកាន់តែល្អប្រសើរជាងមុន។

ការសិក្សាបានបង្ហាញថាឥទ្ធិពលនៃការរំពឹងទុកនៅក្នុង ការសិក្សា (Pygmalion effects) គឺជាប្រភេទនៃការទស្សន៍ទាយការសម្រេចចិត្តរបស់ខ្លួន (Self-fulfilling prophecy) ប្រសិនបើបុគ្គលខ្លួនឯងគិតថានឹងមានអ្វីកើតឡើងនោះបុគ្គលអាចនឹងបង្កើតវាឡើងដោយអញ្ញាណតាមរយៈសកម្មភាពរបស់ខ្លួន។




*រូបភាព 56៖ឥទ្ធិពលនៃការរំពឹងទុក*

❖ ការទស្សន៍ទាយការសម្រេចចិត្តរបស់ខ្លួន (Self-fulfilling prophecy)

ការទស្សន៍ទាយការសម្រេចចិត្តរបស់ខ្លួនត្រូវបានកំណត់ឡើងជាលើកដំបូងដោយសង្គមវិទូ លោក Robert K. Merton (1948) ។ លោកបានបង្ហាញអំពីជំហានទាំង៥ ដែលជាការទស្សន៍ទាយការសម្រេចចិត្តរបស់ខ្លួននៅក្នុងដំណើរការខាងក្រោម៖

- គ្រូបង្កើតទម្រង់នៃការរំពឹងទុករបស់ខ្លួនទៅលើសិស្ស
- គ្រូបញ្ចេញឥរិយាបថផ្សេងៗ ដោយយោងតាមការរំពឹងទុកទាំងនោះ
- តាមរយៈការផ្តល់ឱ្យរបស់គ្រូ អាចប្រាប់សិស្សបានអំពីអាកប្បកិរិយា និងសមិទ្ធិផលដែលគ្រូរំពឹងទុក
- បើការផ្តល់ឱ្យរបស់គ្រូមានភាពទៀងទាត់ វានឹងមានទំនោរក្នុងការជួយរៀបចំអាកប្បកិរិយា និងសមិទ្ធិផលរបស់សិស្សបានល្អ
- ជាបន្តបន្ទាប់ អាកប្បកិរិយា និងសមិទ្ធិផលរបស់សិស្សនឹងប្រព្រឹត្តទៅតាមអ្វីដែលជាការរំពឹងទុករបស់ខ្លួន និងសិស្សកាន់តែច្រើនឡើងៗ។

## ១១.៣.២ ប្រភេទឥទ្ធិពលនៃការរំពឹងទុកនៅក្នុងការសិក្សា (Pygmalion effects)៖

### ក) ឥទ្ធិពលនៃការរំពឹងទុកវិជ្ជមាន (រវាងគ្រូនិងសិស្ស)

ប្រសិនបើគ្រូមានការរំពឹងទុកថា (សិស្សរៀនពូកែ ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់ ផ្ចិតផ្ចង់ និងសកម្ម) នោះសិស្ស នឹងបង្ហាញការផ្លាស់ប្តូរជាវិជ្ជមាន ហើយប្រែក្លាយជាសិស្សរៀនពូកែ និងសកម្ម (ការរំពឹងទុកវិជ្ជមាន)។




*រូបភាព 57៖ឥទ្ធិពលនៃការរំពឹងទុកវិជ្ជមាន (រវាងគ្រូនិងសិស្ស)*

សំណួរ៖ ហេតុអ្វីបានជាគ្រូមានការរំពឹងទុកវិជ្ជមាន នាំឱ្យលទ្ធផលសិក្សារបស់សិស្សកើនឡើង?
សូមពិនិត្យមើលឧទាហរណ៍ខាងក្រោមអំពី៖ ការរំពឹងទុកវិជ្ជមាន (រវាងគ្រូA គ្រូB និងសិស្សC)




*រូបភាព 58៖ឥទ្ធិពលនៃការរំពឹងទុកវិជ្ជមាន (រវាងគ្រូនិងសិស្ស)*

សរុបសេចក្ដី៖

- អត្ថន័យចំពោះការរំពឹងទុក៖ គ្រូAគិតថាលទ្ធផលការសិក្សារបស់សិស្សCនឹងកើនឡើងខ្លាំង។ ដោយសារគាត់បានទទួលព័ត៌មានពីគ្រូស្គាល់គ្នា ទើបមានការរំពឹងទុកដូចនេះ។
- ការផ្លាស់ប្ដូរសកម្មភាព៖ របស់គ្រូA សួរសំណួរទៅសិស្សCក្នុងថ្នាក់ ទោះជាសិស្សCឆ្លើយសំណួរមិនបានល្អ ក៏គ្រូAព្យាយាមពន្យល់មួយៗរហូតដល់គាត់យល់។
- ការកើតឡើងនូវការរំពឹងទុក៖ សិស្ស )Cយល់មេរៀនបានល្អ ហើយអាចយកពិន្ទុបានខ្ពស់នៅពេលប្រលង។(

**ខ) ឥទ្ធិពលនៃការរំពឹងទុកអវិជ្ជមាន (Golem effect)**

ប្រសិនបើមានការគិតទុកបែបអវិជ្ជមាននេះ វា នឹងមានឥទ្ធិពលទៅលើការរំពឹងទុក ដែលជាប់ទាក់ទងជាមួយអាកប្បកិរិយា និងលទ្ធផលនៃការសិក្សារបស់សិស្ស ហើយក៏អាចជាផលអវិជ្ជមានដូចជាការផ្ដោតទៅលើបញ្ហាក្នុងការប្រាស្រ័យទាក់ទង ឬការរើសអើងជាដើម។




*រូបភាព 59៖ដ្ដឥទ្ធិពលនៃការរំពឹងទុកអវិជ្ជមាន (Golem effect)*

សូមពិនិត្យមើលឧទាហរណៃការរពងទុកអរជ្ជមានខាងក្រោម៖ អពសមាជកកឡ្បាករ២រូបច្មចូលមកនៅក្នុងក្រុម!

















*រូបភាព 60៖ឥទ្ធិពលនៃការរំពឹងទុកអវិជ្ជមាន (រវាងគ្រូនិងសិស្ស)*

សរុបសេចក្តី៖

- អត្ថន័យចំពោះការរំពឹងទុក៖ សមាជិកគិតថាប្អូនB ជាកូនកសិករ ជាសមាជិកថ្មី។ គាត់គិតទុកមុនដោយយោងតាមពត៌មានដែលធ្លាប់ទទួលបាន នោះនាំឱ្យសមាជិកក្រុមក៏មានការរំពឹងទុកបែបនេះដែរ។

- ការផ្លាស់ប្តូរសកម្មភាព៖ សូម្បីតែបច្ចេកទេសទូទៅ ក៏សមាជិកមិនជួយបង្រៀនទៅប្អូនB ដែរ។

- ការកើតឡើងនូវការរំពឹងទុក៖ ប្អូនBអត់ទទួលបានការបង្រៀនអ្វីទាំងអស់ ហើយក៏មិនបានហ្វឹកហ្វាត់គ្រប់គ្រាន់ ដូចនេះសមត្ថភាពមិនមានការកើនឡើងឡើយ។

## ១១.៤ សន្និដ្ឋាន

សរុបមកខ្លឹមសារមេរៀនដែលស្ដីពីអំពីឥទ្ធិពលនៃការរំពឹងទុកនៅក្នុងបរិបទសិក្សាជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធក្នុងទិដ្ឋភាពនៃជំនឿ ឬការរំពឹងទុក អាកប្បកិរិយារបស់គ្រូចំពោះសិស្ស ដែលមានឥទ្ធិពលទៅឥរិយាបថ និងការបំពេញកិច្ចការរបស់ខ្លួនដើម្បីទទួលបានលទ្ធផលល្អក្នុងការសិក្សា។ ហេតុដូច្នេះ ដើម្បីជួយដល់ការរៀនរបស់សិស្សឱ្យទទួលបានសមិទ្ធិផលដ៏ល្អ គឺផ្ដើមចេញពីទំនាក់ទំនងរវាងគ្រូ និងសិស្សដែលជាកត្តាចាំបាច់ក្នុងការគាំទ្រ និងការជុំរុញលើកទឹកចិត្តសិស្ស។ ពិសេសនៅខណៈពេលដែលគ្រូរំពឹងទុកថាសិស្សនឹងបង្ហាញការអភិវឌ្ឍផ្នែកបញ្ញា ស្មារតីកាន់តែល្អប្រសើរ នោះសិស្សនិងទទួលបានការរៀនសូត្រកាន់តែខ្លាំងផងដែរ។

### សំណួរត្រិះរិះ

១. តើអ្នកធ្លាប់មានបទពិសោធន៍ពីការរំពឹងទុកដែលវាបានក្លាយជាការពិតដែរឬទេ? ចូររៀបរាប់។

## ឯកសារយោង៖


- Educational Psychology, An Asia edition. Oon-Seng Tan, Yen-Leng Stefanie Chye. Kek-Joo Lim, Bee-Leng Cheu, Bruce W. Tuckman, David M. Monetti. page: 22-44.
- សៀវភៅចិត្តវិទ្យាសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៦ ទំព័រទី១ ដល់ទី៧។
- ស្លាយមេរៀនសញ្ញាណទូទៅនៃចិត្តវិទ្យាអប់១ (ឆ្នាំទី១ ឆមាសទី១) ឆ្នាំសិក្សា២០២១-២០២២។
- Atkinson and Hilgards introduction to psychology, 16 edition, page: 89-90
- John Bowlby and Attachment Theory, Jeremy Holmes, First published 1993.(p.69-73)
- The New Science of Adult Attachment, 2010 by Amir Levine and Rachel Heller.(p.39-45)
- រូបភាពចំណងក្តីស្រឡាញ់ទាំង៣ ដកស្រង់ចេញពី google, http://ardacigin.blogspot.com/2016/
- រូបភាពការពិសោធន៍ប្រអប់ស្ករគ្រាប់ដកស្រង់ចេញពី google, https://www.simplypsychology.org/theory-of-mind.html
- ចិត្តវិទ្យា សម្រាប់បង្រៀនកម្មវិធីបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិ មេរៀនចិត្តរំភើប (២០០៣)
- ឯកសារចិត្តវិទ្យា សម្រាប់បំប៉នសមត្ថភាពគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មេរៀនសីលធម៌ (២០០៦)
- Nolen-Hoeksema, S. et al. (2014). *Atkinson & Hilgard's Introduction to Psychology 16th edition*. Cengage Learning.
- The Science of Emotion: Exploring the Basics of Emotional Psychology: Posted June 27, 2019 by UWA https://sproutsschools.com/kohlbergs-6-stages-of-moral-development/
- ស្លាយបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី៦៖ ការអភិវឌ្ឍប្រត្យក្សារម្មណ៍។
- កិច្ចតែងការបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ មេរៀនទី៦៖ ការអភិវឌ្ឍប្រត្យក្សារម្មណ៍។
- Susan Nolen-Hoeksema, S. et al. (2014). *Atkinson & Hilgard's Introduction to Psychology 16th edition*. Cengage Learning. Page:144-193.

- https://www.coursehero.com/study-guides/boundless-psychology/introduction-to-perception/
- រូបភាពគំនូរចេញពី google.com
- ឯកសារចិត្តវិទ្យា សម្រាប់បំប៉នសមត្ថភាពគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ២០០៦
- ស្លាយបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី៧៖ ការអភិវឌ្ឍពុទ្ធិ។
- កិច្ចតែងកាបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី៧៖ ការអភិវឌ្ឍពុទ្ធិ
- https://open.library.okstate.edu/foundationsofeducationaltechnology/chapter/2-cognitive-development-the-theory-of-jean-piaget/
- រូបភាពគំនូរចេញពី google.com

- ចិត្តវិទ្យា សម្រាប់បង្រៀនកម្មវិធីបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិ ២០១៦។ មេរៀនទី២៖ មូលដ្ឋានសរីរៈនៃបាតុភូតចិត្ត។
- ស្លាយបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១នៃវិទ្យាស្ថានគរុកោសល្យរាជធានី(២០២១) ភ្នំពេញ។ មេរៀនទី៩៖ ដំណើរការរៀន។
- កិច្ចតែងការបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១នៃវិទ្យាស្ថានគរុកោសល្យរាជធានី(២០២១) ភ្នំពេញ។ មេរៀនទី៩៖ ដំណើរការរៀន។
- Introduction to Psychology, 16th edition, Susan Nolen-Hoeksema, S. et al. (2014). Atkinson & Hilgard's. page៖ 227-228, 234-236, 224-242.
- International Journal of Humanities and Innovation (IJHI) Vol. 4 No. 1, 2021 pp. 1-4, "Teaching and learning process to enhance teaching effectiveness: a literature review".
- NATIONAL FORUM OF TEACHER EDUCATION JOURNAL VOLUME 22, NUMBER 3, 2012. "Theories of Learning and Student Development".
- រូបភាពគំនូរចេញពី google.com
- សៀវភៅចិត្តវិទ្យា សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ។ នាយកដ្ឋានបណ្តុះបណ្តាលវិក្រិតការ ឆ្នាំ២០១៦។ មេរៀនទី៦៖លំនឹក ទំព័រទី៣១-៣៧។
- ស្លាយបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី១០៖ លំនឹក និងការជំរុញលើកទឹកចិត្ត។

- Introduction to Psychology, 16th edition, Susan Nolen-Hoeksema, S. et al. (2014). Atkinson & Hilgard's. page៖ 258-271.
- រូបភាពដកស្រង់ចេញពី៖ google.com
- ដកស្រង់៖ ពីសៀវភៅចិត្តវិទ្យា សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ។ នាយកដ្ឋានបណ្តុះបណ្តាលវិក្រិតការ ឆ្នាំ២០១៦។ ។ មេរៀនចលករសិក្សា ទំព័រ ១២០-១២៧។
- ស្លាយបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី១០៖ លំនឹក និងការជំរុញលើកទឹកចិត្ត។
- កិច្ចតែងការបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី១០៖ លំនឹក និងការជំរុញលើកទឹកចិត្ត។
- Introduction to Psychology, 16th edition, Susan Nolen-Hoeksema, S. et al. (2014). Atkinson & Hilgard's. page៖ 342-375.
- Intrinsic and Extrinsic Motivations, Classic Definitions and New Directions, Richard M. Ryan and Edward L. Deci (2000).
- រូបភាពដកស្រង់ចេញពី៖ google.com
- ដកស្រង់៖ ពីសៀវភៅចិត្តវិទ្យា សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ។ នាយកដ្ឋានបណ្តុះបណ្តាលវិក្រិតការ ឆ្នាំ២០១៦។ ។ មេរៀនចលករសិក្សា ទំព័រ ១២០-១២៧។
- ស្លាយបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី១០៖ លំនឹក និងការជំរុញលើកទឹកចិត្ត
- Introduction to Psychology, 16th edition, Susan Nolen-Hoeksema, S. et al. (2014). Atkinson & Hilgard's. page៖ 342-375.
- Intrinsic and Extrinsic Motivations, Classic Definitions and New Directions, Richard M. Ryan and Edward L. Deci (2000).
- រូបភាពដកស្រង់ចេញពី៖ google.com
- ស្លាយបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី១៣៖ ឥទ្ធិពលនៃការរំពឹងទុក។
- កិច្ចតែងការបង្រៀន៖ មុខវិជ្ជាចិត្តវិទ្យាអប់រំ១ ឆ្នាំទី១(២០២១)នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ មេរៀនទី១៣៖ ឥទ្ធិពលនៃការរំពឹងទុក។
- រូបភាពដកស្រង់ចេញពី៖ google.com. Pygmalion in classroom, teacher expectation and pupil's intellectual development, Robert Rosenthal and Lenore Jacobson,

http://people.wku.edu/steve.groce/RosenthalJacobson-PygmalionintheClassroom.pdf.

- The Application of Pygmalion Effect in Classroom Education, International Conference on Arts, Design and Contemporary Education (ICADCE 2016).
- The Power of the Pygmalion Effect, Teachers Expectations Strongly Predict College Completion, Ulrich Boser, Megan Wilhelm, and Robert Hanna (2014).
- រូបភាពដកស្រង់ចេញពី៖ google.com. https://web.facebook.com/sromorchkh/photos/a.114345014199497/166903862276945/?paipv=0&eav=AfZZ5EtYW-vF5e-Ch9qbcLjwIBc2CNzA35TJoSPv32xH6NAEs1okmLxBm0Evl8878UA&_rdc=1&_rdr
- រូបភាពគំនូរចេញពី https://practicalpie.com/formal-operational-stage/